Prepared By: The EC-FAO Food Security Programme | កម្មវិធីសន្តិសុខស្បៀងនៃអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

**CAMBODIA**

# FOOD AND NUTRITION SECURITY WORKING GLOSSARY

# សន្ទានុក្រមស្តីពីសន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ



With the generous support of the European Union through the EC-FAO Food Security Programme

*Linking Information and Decision-Making to Improve Food Security (GCP/RAS/247/EC)*

**SEPTEMBER 2012** ខែកញ្ញា ឆ្នាំ២០១២

# PREFACE

It is with great pleasure that we present the following Food and Nutrition Security Working Glossary, a compendium of more than 150 terms related to food and nutrition security. The Glossary is intended for people from all sectors and disciplines that contribute to food and nutrition related analysis, activities and policy discussions. Its purpose is to provide simple and easy to understand definitions of key technical terms so that we can collectively discuss food and nutrition security, and identify common solutions using a common language.

As part of the EC-FAO Food Security Programme on Linking Information and Decision-Making to Improve Food Security in Selected Countries of the Greater Mekong Sub-Region, project staff at the country level compiled lists of key words and phrases pertinent to food security, and developed bilingual dictionaries in Khmer, Lao and Myanmar languages, with English equivalents. These word lists have been freely available on the project website and have been transferred to national food security websites for wider access.

During the course of the project, national partners, stakeholders and other users of the bilingual food security dictionaries noted the need to have a common set of frequently used terms and their definitions, as well as cross referencing these to additional relevant terms. Working from the lists developed in Cambodia, Lao PDR and Myanmar, a master list was developed and definitions sourced from internationally accepted references. The result is this Glossary.

The Glossary does not intend to provide a comprehensive overview of each topic: this is after all a glossary, not an encyclopaedia. In addition, in order to make this book as widely accessible as possible, we have conscientiously tried to avoid highly technical terms, and have in all cases presented the definitions in plain English, with simple and understandable translations.

Similarly, the Glossary does not intend to be definitive, which is why we have called it a “working” glossary. Food and nutrition security remains a vibrant field of endeavour, and as our understanding grows the meaning of many of these terms will also evolve, depending on particular contexts and uses. For this reason, following the definition of each term, we have provided space for you to add your own notes or alternative definitions that work for you. The definitions contained in this book are therefore offered as proposed starting points for your use, rather than as definitive statements.

We hope this is of use to you in your ongoing work.

# អារម្ភកថា

ជាមោទនភាពយ៉ាងខ្លាំង ដែលយើងអាចបង្ហាញ និងផ្តល់ជូននូវឯកសារសន្ទានុក្រមស្តីពី ការងារសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ ដែលមានដែលមានពាក្យបច្ចេកទេសច្បាស់លាស់ចំនួន ជាង១៥០ពាក្យពាក់ព័ន្ធទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ សន្ទានុក្រមនេះ មានបំណងផ្តល់ជូនដល់អ្នកបច្ចេកទេសដែលពាក់ព័ន្ធទាំងអស់មកពីគ្រប់វិស័យ និងគ្រប់ជំនាញផ្សេងៗដែលរួមចំណែកដល់ការធ្វើវិភាគនានាពាក់ព័ន្ធទៅនឹងការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងរាល់សកម្មភាព និងពិភាក្សាផ្សេងៗដែលពាក់ព័ន្ធគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ គោលបំណងនៃសន្ទានុក្រមនេះ គឺដើម្បីផ្តល់នូវភាពសាមញ្ញ និងភាពងាយស្រួលក្នុងការស្វែងយល់នូវនិយមន័យរបស់ពាក្យបច្ចេកទេសគន្លឹះសំខាន់ៗ ដើម្បីឱ្យយើងអាចធ្វើការពិភាក្សាបានរួមគ្នា អំពីបញ្ហាសន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ និងអាចកំណត់បានពីដំណោះស្រាយជារួម ដោយប្រើប្រាស់ភាសាជារួមតែមួយដូចៗគ្នា ។

ជាផ្នែកមួយនៃកម្មវិធីសន្តិសុខស្បៀងនៃអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប ស្តីពី ការផ្សារភ្ជាប់ព័ត៌មានទៅនឹងការធ្វើសេចក្តីសំរេចចិត្តដើម្បីកែលំអសន្តិសុខស្បៀង នៅបណ្តាប្រទេស ដែលបានជ្រើសរើសមួយចំនួននៅក្នុងមហាអនុតំបន់ទន្លេរមេគង្គ មន្រ្តីគម្រោងនៅតាម ប្រទេសនីមួយៗបានធ្វើការចងក្រងនូវបញ្ជីនៃពាក្យគន្លឹះសំខាន់ៗ និងឃ្លាប្រយោគដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងបានបង្កើតជាវចនានុក្រមទ្វិភាសា ជាភាសាខ្មែរ ឡាវ ភូមា ( មីយ៉ាន់ម៉ា) ដែលមានន័យ ត្រឹមត្រូវស្របតាមភាសាអង់គ្លេស ។ បញ្ជីពាក្យទាំងអស់នេះ ត្រូវបានបានដាក់ផ្សព្វផ្សាយនៅលើគេហទំព័ររបស់គម្រោង ដែលបានក្លាយជាគេហទំព័រសន្តិសុខស្បៀងរបស់ប្រទេសនីមួយៗដើម្បងាយស្រួលដល់ការប្រើប្រាស់បានកាន់តែទូលំទូលាយ ។ នៅក្នុងអំឡុងមានវគ្គរបស់គម្រោងកម្មវិធី ដៃគូថ្នាក់ជាតិ បណ្តាអ្នកពាក់ព័ន្ធ និងអ្នកប្រើប្រាស់ទ្វិវចនានុក្រមស្តីពីសន្តិសុខស្បៀងផ្សេងៗបានបង្ហាញពីតំរូវការ និងការប្រើប្រាស់ជាញឹកញាប់នូវពាក្យគន្លឹះរួម និង និយមន័យរបស់វា ព្រមទាំងកំណត់ទុកពាក្យទាំងអស់នោះ ដើម្បីបញ្ចូលបន្ថែមទៅក្នុងបញ្ជីពាក្យគន្លឹះដែលពាក់ព័ន្ធ ។ ដោយផ្អែកលើបញ្ជីពាក្យគន្លឹះដែលបានបង្កើតឡើងដោយក្រុមការងារនៅក្នុងប្រទេសនីមួយៗ មានប្រទេសកម្ពុជា ឡាវ ភូមា ( មីយ៉ាន់ម៉ា) នោះ បញ្ជីពាក្យគន្លឹះមេ (master list) មួយត្រូវបានរៀបចំឡើង ហើយនិយមន័យទាំងឡាយគឺមានប្រភពពីឯកសារយោងដែលទទួលស្គាល់ជាអន្តរជាតិ ។ ជាលទ្ធផលសន្ទានុក្រម នេះត្រូវបានចងក្រងឡើង ។ សន្ទានុក្រមនេះមិនមានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅនៃប្រធានបទនិមួយៗឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ វាគ្រាន់តែជាសន្ទានុក្រមតែប៉ុណ្ណោះ តែវាមិនមែនជាសព្វវចនាធិប្បាយ (encyclopaedia) នោះទេ ។ លើសពីនេះទៅទៀត ដើម្បីធ្វើឱ្យសៀវភៅនេះអាចអោយអ្នកគ្រប់ៗគ្នាអាចប្រើប្រាស់បានទូលំទូលាយតាមលទ្ធភាពដែលអាចធ្វើទៅបាន នោះក្រុមការងារយើងបានព្យាយាមដោយប្រុងប្រយ័ត្នជៀសវាងនូវការប្រើពាក្យពេជន៏បច្ចេក-

ទេសមានលក្ខណៈស្មុគ្រស្មាញពេក និងគ្រប់ករណីទាំងអស់ យើងបានផ្តល់ជូននូវនិយមន័យ ជាភាសាអង់គ្លេស ងាយយល់ដោយមានការបកប្រែយ៉ាងសាមញ្ញៗ និងងាយយល់ ។

ជាមួយគ្នានេះដែរ សន្ទានុក្រមនេះ មិនមែនជាឯកសារចុងក្រោយនោះទេ ដែលហេតុនេះហើយបានជាយើងនៅតែចាត់ទុកថាជាសន្ទានុក្រមរស់ (working glossary) ។ សន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ នៅតែជាវិស័យមួយដ៏រស់រវើកដែលតំរូវឱ្យមានការខិតខំប្រឹងប្រែង ហើយនៅពេលដែលការយល់ដឹងរបស់យើង មានការកើនឡើងនោះអត្ថន័យជាច្រើននៃពាក្យទាំងអស់នេះ ក៏នឹងមានការវិវត្តន៍ទៅតាមនោះផងដែរ ដោយអាស្រ័យទៅលើបរិបទពិសេស និងការប្រើប្រាស់ជាក់លាក់នៃពាក្យគន្លឹះនីមួយៗ ។ ដោយហេតុនេះហើយ នៅបន្ទាប់ពីនិយមន័យនៃពាក្យនិមួយៗក្រុមការងារយើងបានផ្តល់កន្លែងទំនេរ (ចំហរចោល) ទុក សំរាប់លោកអ្នកធ្វើការកត់ចំណាំបន្ថែមផ្ទាល់ខ្លួន ឬ ក៏និយមន័យណាមួយដែលងាយយល់សម្រាប់លោកអ្នក ផ្ទាល់ ។ ហេតុនេះហើយ និយមន័យទាំងឡាយដែលបានចងក្រងនៅក្នុងសៀវភៅនេះ ត្រូវបានផ្តល់ជូនទុកជា ចំណុចចាប់ផ្តើមដែលបានស្នើឡើងសំរាប់ការប្រើប្រាស់របស់លោកអ្នក ជាជាងជាខ្លឹមសារចុងក្រោយ ។

ក្រុមការងារសង្ឃឹមថា សន្ទានុក្រមនេះនឹងមានប្រយោជន៏ដល់ឯកឧត្តម លោក និងលោកស្រី ទាំងអស់នៅក្នុងដំណើរការការងាររបស់លោកអ្នក ។

កម្មវិធីសន្តិសុខស្បៀងនៃអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិក្រោមជំនួយ ឧបត្ថម្ភរបស់សហភាពអឺរ៉ុប ស្តីពី ការផ្សារភ្ជាប់ព័ត៌មានទៅនឹងការធ្វើការសំរេចចិត្តដើម្បីកែលំអសន្តិសុខស្បៀងនៅបណ្តាប្រទេស ដែលបានជ្រើសរើសមួយចំនួននៅក្នុងមហាអនុតំបន់ទន្លេរមេគង្គ ។

គម្រោង GCP/RAS/247/EC

បាងកក ថៃឡង់

ខែកញ្ញា ឆ្នាំ២០១២

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# ACCESS

The degree to which available food can be sourced through markets, own production, or other means. Households or individuals' ability to secure adequate resources for acquiring appropriate foods (in terms of macronutrients, micro nutrients and cultural acceptability) for a nutritious diet.

Related Terms: food access, food access gap, Livelihoods

## លទ្ធភាពទទួលបាន

កម្រិតនៃស្បៀងដែលមាន និងអាចរកបាន តាមរយៈទីផ្សារ ផលិតកម្មផ្ទាល់ខ្លួន ឬតាម រយៈមធ្យោបាយផ្សេងៗទៀត ។ លទ្ធភាពរបស់គ្រួសារ/ខ្នងផ្ទះនិមួយៗ ឬ បុគ្គលដើម្បីធានាធនធានគ្រប់គ្រាន់សម្រាប់ទទួលបានស្បៀងសមស្រប ( ក្នុងន័យដែលអាចទទួលយកបានទាំងផ្នែកម៉ាក្រូសារជាតិ ពពួកមីក្រូសារជាតិ និងខាងផ្នែកវប្បធម៌) ដើម្បីឱ្យបានរបបអាហារមួយដែលសំបូរទៅដោយសារជាតិចិញ្ចឹម ។

ពាក្យដែលទាក់ទងគ្នា : លទ្ធភាពទទួលបានស្បៀង  គំលាតក្នុងការទទួលបានស្បៀង  ការចិញ្ចឹមជីវិត ។

*NOTES...*

# ACUTE MALNUTRITION

Acute malnutrition is the manifestation of low weight in relation to the height of children and/or the presence of oedema.  The key indicator for acute malnutrition is the proportion of children under-five with weight less than two standard deviations below the median.  In its most severe form (> 3 standard deviations) is known as wasting.

Related Terms:  malnutrition, nutritional status, wasting, therapeutic feeding, oedema, z-scores.

## កង្វះអាហារូបត្ថម្ភស្រួចស្រាវ

កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាការស្តែងចេញឱ្យ ឃើញនូវការមានទម្ងន់ទាបធៀបទៅនឹងកំពស់របស់កុមារ និង/ឬមានហើមមានស្នាមទ្រុតនៅជើងទាំងសង ខាង។ សុច្ចនាករគន្លឹះសំរាប់កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាសមាមាត្រនៃកុមារអាយុក្រោម៥ឆ្នាំដែល មានទំងន់តិចជាង ២SD ដែលស្ថិតនៅក្រោមខ្សែមេដ្យាន។ នៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតរបស់បញ្ហានេះ (តូចជាង -៣SD) ត្រូវបានគេដឹងថាជាបញ្ហាស្គមស្គាំង។

ពាក្យដែលទាក់ទងគ្នា : កង្វះអាហារូបត្ថម្ភ  ស្ថានភាពអាហារូបត្ថម្ភ  ស្គមស្គាំង ការផ្តល់អាហារព្យាបាល  ហើម ពិន្ទុ-ហ្សៀត។

*NOTES...*

# AGRICULTURE

All activities pertaining to the cultivation of natural resources to produce crops for human consumption, animal consumption, commercial and/or industrial uses.  Agriculture often includes livestock rearing.  Agriculture practiced at the household level is referred to as small-scale or subsistence agriculture, compared with industrial or commercial agriculture involving large land holdings.

Related Terms:  agricultural household, agricultural production, agricultural productivity, food production, garden crops

## កសិកម្ម

រាល់សកម្មភាពទាំងអស់ដែលទាក់ទងទៅនឹងធ្វើកសិកម្ម នៃធនធានធម្មជាតិ ដើម្បីផលិតដំណាំសំរាប់មនុស្សបរិភោគជាចំណីអាហារសត្វ និងការប្រើប្រាស់ផ្សេងៗសំរាប់ផ្នែកផ្សេងៗទៀត ទាំងផ្នែកពាណិជ្ជកម្ម និង/ឬឧស្សាហកម្ម ។ ជារឿយៗកសិកម្ម គឺមានរាប់បញ្ចូលទាំងការចិញ្ចឹមសត្វផងដែរ ។ កសិកម្មដែលអនុវត្តន៏នៅកំរិតគ្រួសារ គឺតែងតែសំដៅទៅដល់កសិកម្មកំរិតខ្នាតតូច ឬកសិកម្មត្រឹមសម្រាប់ ចិញ្ចឹមក្រពះ ដោយប្រៀបធៀបទៅនឹងកសិកម្មសំរាប់ឧស្សាហកម្ម ឬពាណិជ្ជកម្ម ដែលពាក់ព័ន្ធទៅនឹងការកាន់កាប់ដីធ្លីទំហំធំៗ ។

ពាក្យដែលទាក់ទងគ្នាៈ គ្រួសារប្រកបរបរកសិកម្ម/គ្រួសារកសិករ   ផលិតកម្មកសិកម្ម   ផលិតភាពកសិកម្ម   ផលិតកម្មស្បៀង   ដំណាំក្នុងសួន។

*NOTES...*

# AGRICULTURAL EXTENSION

Training, services and resources provided to agricultural households and rural population which aim to support improved agricultural practices.  This tends to emphasize improved crop and livestock production, and may also include support to improve other livelihood skills such as marketing, food safety, good nutrition, access to credit and business management and administration.

Related Terms:  agriculture

## ការផ្សព្វផ្សាយកសិកម្ម

ការបណ្តុះបណ្តាលសេវាផ្សេងៗ និងធនធានដែលផ្តល់ដល់គ្រួសារប្រកបរបរកសិកម្ម (ឬកសិករ) និងប្រជាជននៅជនបទ មានគោលបំណងដើម្បីគាំទ្រការ ងារផលិតកម្មកសិកម្មឱ្យបានល្អប្រសើរ ។ ទង្វើនេះគឺមានបំណងសំដៅផ្តោតធ្ងន់ទៅលើការធ្វើឱ្យប្រសើរនូវផលិតកម្មដំណាំ និងការចិញ្ចឹមសត្វ ហើយនឹងក៏អាចរាប់បញ្ចូលផងដែរចំពោះរាល់ការគាំទ្រ ដើម្បីកែលម្អនូវជំនាញ របរចិញ្ចឹមជីវិតផ្សេងៗទៀត ដូចជា ការរកទីផ្សារសុវត្ថិភាពស្បៀង អាហារូបត្ថម្ភល្អ លទ្ធភាពភាពទទួលបាន ឥណទាន និងការគ្រប់គ្រងផ្នែកធុរកិច្ច និងរដ្ឋបាល ។

ពាក្យដែលទាក់ទងគ្នា : កសិកម្ម ។

*NOTES...*

# AGRICULTURAL HOUSEHOLD

Any household for which the primary livelihood activity, and/or the largest source of income is derived from agriculturally based activity.

Related Terms: agriculture, agricultural production, agricultural productivity, garden crops, livelihoods

## **គ្រួសារកសិករ**

គ្រួសារណាមួយដែលមានសកម្មភាពចិញ្ចឹមជីវិតបឋម និង/ ឬប្រភពចំណូលសំខាន់បានមកពីសកម្មភាពដែលផ្អែកទៅលើកសិកម្ម។

ពាក្យដែលទាក់ទងគ្នា ៖ កសិកម្ម ផលិតកម្មកសិកម្ម ផលិតភាពកសិកម្ម ដំណាំក្នុងសួន ការចិញ្ចឹមជីវិត។

*NOTES...*

# AGRICULTURAL PRODUCTION

The sum total of all agricultural outputs, expressed in tonnages or economic values. Usually measured in terms of unprocessed raw commodities, aggregated at the district, province or national level.

Related Terms: agriculture, agricultural productivity, food production

## ផលិតកម្មកសិកម្ម

ចំនួនសរុបទាំងអស់នៃលទ្ធផលបានមកពីកសិកម្មដែល បញ្ជាក់ជាតោន ឬក៏តំលៃផ្នែកពាណិជ្ជកម្ម។ តាមធម្មតាលទ្ធផលត្រូវបានគេវាស់វែងក្នុងលក្ខខណ្ឌនៃទំនិញ ឆៅដែលមិនទាន់កែច្នៃ ដែលប្រមូលបានពីថ្នាក់ស្រុក ខេត្ត ឬថ្នាក់ជាតិ។

ពាក្យដែលទាក់ទងគ្នា : កសិកម្ម  ផលិតភាពកសិកម្ម  ផលិតកម្មស្បៀង។

*NOTES...*

# AGRICULTURAL PRODUCTIVITY

For all agricultural products, the ratio of the value of the output compared to the value of the inputs. This indicates the cost-benefit ratio of the farming method applied vs. the market value of the crop produced. An important determinant of competitiveness.

Related Terms: agriculture, agricultural production, food production.

## ផលិតភាពកសិកម្ម

ចំពោះផលិតផលកសិកម្មទាំងអស់ ដែលអ៊ាត្យូនៃតំលៃ លទ្ធផលប្រៀបធៀបនឹងតំលៃនៃធនធានប្រើប្រាស់ (ទុន) ។ ចំនុចនេះចង្អុលបង្ហាញថា អត្រាអ៊ាត្យូនៃតំលៃប្រាក់ ចំណេញនៃវិធីសាស្ត្រដាំដុះដែល បានអនុវត្តនឹ៍ ប្រៀបធៀបនឹងតំលៃទីផ្សារនៃដំណាំដែលបានផលិត ។ វាគឺជា លក្ខខណ្ឌកំនត់ដ៏សំខាន់នៃការ ប្រកួតប្រជែង ។

ពាក្យដែលទាក់ទងគ្នា ៖ កសិកម្ម   ផលិតកម្មកសិកម្ម  ផលិតកម្មស្បៀង ។

*NOTES...*

# ANAEMIA

A common, widespread and serious micronutrient deficiency, a condition in which the haemoglobin concentration (the number of red blood cells) is lower than normal due to disease or as a result of a deficiency of one or more nutrients such as iron and vitamin B12.

Related Terms: malnutrition, micronutrient deficiencies (vitamins and minerals), micronutrients: iron and vitamin a

## ភាពស្លេកស្លាំង

បញ្ហាកង្វះមីក្រូសារជាតិដែលកើតមានជាទូទៅ និងធ្ងន់ធ្ងរ គឺជាលក្ខខណ្ឌដែល កំហាប់អេម៉ូក្លូប៊ីន (ចំនួនគ្រាប់ឈាមក្រហម) មានកំរិតទាបជាងកំរិតធម្មតា ដោយសារតែមានជំងឺ ឬក៏ជាលទ្ធផលនៃបញ្ហាកង្វះសារជាតិចិញ្ចឹមមួយ ឬលើសពីមួយ ដូចជា កង្វះជាតិដែក និងកង្វះវីតាមីនបេ១២ ។

ពាក្យដែលទាក់ទងគ្នា : កង្វះអាហារូបត្ថម្ភ កង្វះមីក្រូសារជាតិ (ជីវជាតិ និងរ៉ែខនិជ) មីក្រូសារជាតិ : ជាតិដែក និងជីវជាតិអា។

*NOTES...*

# ANTHROPOMETRY

The physical measurement of the size, weight, height and proportions of the human body.  A process necessary for accurate nutritional surveys, for which the Middle Upper Arm Circumference (MUAC) test is frequently utilized, although collecting height, weight and age data for individuals is also common. Most often, children under five years of age and women of child-bearing age (estimated at 15-49) are measured using anthropometry.

Related Terms:  BMI, indicators, malnutrition, nutritional status, nutrition survey, quantitative data

## មនុស្សមាត្រ

ការវាស់វែងផ្នែករាងកាយនូវទំហំ ទំងន់ កំពស់ និងសមាមាត្រនៃ រាងកាយរបស់មនុស្ស ។ មនុស្សមាត្រ គឺជាដំណើរការមួយដែលចាំបាច់សំរាប់ធ្វើការអង្កេតពីអាហារូបត្ថម្ភ ឱ្យបានត្រឹមត្រូវឥតខ្ចោះ ចំពោះការធ្វើតេស្ដរង្វាស់ជុំវិញពាក់កណ្ដាលដើមដៃ (MUAC) គឺត្រូវបានគេប្រើជាញឹកញាប់ តែទោះជាយ៉ាងណាក៏ដោយ ក៏ការប្រមូលទិន្នន័យពីកំពស់ ទំងន់ និងអាយុរបស់បុគ្គលម្នាក់ៗទាំងអស់ត្រូវបានប្រើប្រាស់ជាទូទៅផងដែរ ។ ញឹកញាប់បំផុតនោះ កុមារអាយុ៥ឆ្នាំ និងស្ត្រីក្នុងវ័យបន្តពូជ (តាមការ ប៉ាន់ស្មានពី អាយុ ១៥ ដល់ ៤៩ឆ្នាំ) ត្រូវបានវាស់វែងដោយប្រើរង្វាស់មនុស្សមាត្រ ។

ពាក្យដែលទាក់ទងគ្នាៈ សន្ទស្សន៍ម៉ាស់រាងកាយ សូចនាករ កង្វះអាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ ការអង្កេត ពីអាហារូបត្ថម្ភ ទិន្នន័យបែបបរិមាណ។

*NOTES...*

# AVAILABILITY

Adequate quantities of food, supplied through domestic production, stocks, imports and food aid to ensure that the minimum nutritional requirements of the population can be met.  Food availability addresses the “supply side” of food security.

Related Terms:  access, food availability, stability, stocks, utilization

## ភាពមាន

បរិមាណគ្រប់គ្រាន់នៃស្បៀងដែលផ្គត់ផ្គង់តាមរយៈផលិតកម្មក្នុងស្រុក  ការស្តុកទុក ការនាំចូល និងជំនួយជាស្បៀងអាហារ ដើម្បីធានាថាតំរូវការអាហារូបត្ថម្ភក្នុងកិរិតអប្បបរមារបស់ប្រជាជនអាចនឹងឆ្លើយតបបាន។ ភាពមានស្បៀង គឺចង់សំដៅទៅលើ (ការផ្គត់ផ្គង់) នៃសន្តិសុខស្បៀង។

ពាក្យដែលទាក់ទងគ្នា : លទ្ធភាពទទួលបាន  ភាពមានស្បៀង  ស្ថេរភាព  ការស្តុក  ការបឺតស្រូបចំណីអាហារ។

7

*NOTES...*

A
**B**
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# BALANCED DIET

A diet in which all nutritional requirements of the individual are fully met. In terms of the proportionate share of macronutrients in the total diet, this is equivalent to: proteins at 10 to 15 percent, fats from 15 to 30 percent and carbohydrates from 55 to 75 percent, as well as a wide range of micronutrients.

Related Terms: diet, diet composition, dietary diversity, dietary energy consumption, food consumption, nourishment, nutrition, nutritional diversity

## តុល្យភាពនៃរបបអាហារ

គឺជារបបអាហារដែលតំរូវការអាហារូបត្ថម្ភទាំងអស់របស់បុគ្គលម្នាក់ៗត្រូវបានឆ្លើយតបទាំងស្រុង។ នៅក្នុងលក្ខខណ្ឌនៃការចែករំលែកដែលមានសមាមាត្រនៃម៉ាក្រូសារជាតិនៅក្នុងរបបអាហារទាំងអស់នេះ គឺសមមូលទៅនឹងជាតិប្រូតេអ៊ីន ក្នុងអត្រា ១០-១៥% ខ្លាញ់ពី ១៥-៣០% និងពួកកាបូអ៊ីដ្រាត ពី ៥០-៥៥% ព្រមទាំងមីក្រូសារជាតិក្នុងមួយលំដាប់ ធំផងដែរ។

ពាក្យដែលទាក់ទងគ្នា : របបអាហារ  សមាសភាពរបបអាហារ  ភាពសំបូរបែបនៃរបបអាហារ  ការបរិភោគ/ប្រើប្រាស់របបអាហារដែលសំបូរថាមពល  ការបរិភោគ/ប្រើប្រាស់ចំណីអាហារ  អាហារសំបូរសារជាតិចិញ្ចឹម  អាហារូបត្ថម្ភ  ភាពសំបូរបែបនៃអាហារូបត្ថម្ភ។

*NOTES...*

# BODY MASS INDEX (BMI)

Body Mass Index (BMI) is an index of weight-for-height that is commonly used to classify underweight, overweight and obesity in adults.  It is defined as the weight in kilograms divided by the square of the height in meters (kg/m2).

Related Terms:  anthropometry, diet, diet composition, indicators, lifestyle practices, malnutrition, obesity, overnutrition, overweight, undernourishment, underweight, utilization

## សន្ទស្សន៍ម៉ាស់រាងកាយ

សន្ទស្សន៍ម៉ាស់រាងកាយ គឺជាសន្ទស្សន៍នៃទំងន់ធៀបនឹងកំពស់ ដែលជាទូទៅត្រូវបានគេប្រើដើម្បីធ្វើចំណាត់ថ្នាក់ទំងន់ក្រោមស្តង់ដារ លើសទំងន់ និងជំងឺធាត់ចំពោះមនុស្សពេញវ័យ។ សន្ទស្សន៍ម៉ាស់រាងកាយត្រូវបានកំនត់យកទំងន់គិតជាគីឡូក្រាម ចែកជាមួយកំពស់គិតជា ម៉ែត្រ (Kg/m2) ។

ពាក្យដែលទាក់ទងគ្នា : មនុស្សមាត្រ  របបអាហារ  សមាសភាពរបបអាហារ  សូចនាករ  ការប្រតិបត្តិអំពីរបៀបរបបរស់នៅ  កង្វះអាហារូបត្ថម្ភ  ជម្ងឺធាត់  លើសអាហារូបត្ថម្ភ  លើសទម្ងន់  កង្វះសារជាតិចិញ្ចឹមទម្ងន់ក្រោមស្តង់ដារ  ការបឺតស្រូបចំណីអាហារ។

*NOTES...*

# CHRONIC FOOD INSECURITY

A long-term or persistent inability to meet minimum food requirements. Poverty and chronic food insecurity often go hand-in-hand.

Related Terms: Food Insecurity, Food Security, Food Stability, Temporary Food Insecurity

## អសន្តិសុខស្បៀងរ៉ាំរ៉ៃ

អសមត្ថភាពរយៈពេលយូរអង្វែង ឬជាប់បន្តដើម្បីឆ្លើយតបទៅនឹងតំរូវការស្បៀងក្នុងកំរិតអប្បបរមា។ ភាពក្រីក្រ និងអសន្តិសុខស្បៀងរ៉ាំរ៉ៃ តែងតែដើរទន្ទឹមព្រមគ្នា ។

ពាក្យដែលទាក់ទងគ្នា : អសន្តិសុខស្បៀង សន្តិសុខស្បៀង ស្ថេរភាពស្បៀង អសន្តិសុខស្បៀងក្នុងរយៈពេលមួយជា បណ្តោះអាសន្ន។

*NOTES...*

# CHRONIC MALNUTRITION

Chronic malnutrition (also known as 'stunting') is the result of prolonged or temporary nutritional deficiencies (macro and/or micronutrients) during critical periods of cognitive and physical development.  It can also be the result of repeated exposure to infections, generally poor living conditions, or a combination of these factors.  The result is substandard physical and cognitive growth.  It is measured by height for age, with a score below 1, 2 or 3 Standard Deviations from the reference population representing mild, moderate and severe stunting respectively.

Related Terms:  chronic food insecurity, diet, diet composition, food consumption, food consumption gap, food deprivation, malnutrition, nourishment, nutrition, nutritional status, severe stunting, stunting, undernourishment, utilization, z scores

# កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ

កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក៏ត្រូវបានគេស្គាល់ផងដែរថាជា ភាពក្រិន) គឺជាលទ្ធផលនៃបញ្ហាកង្វះអាហារូបត្ថម្ភរយៈពេលយូរ ឬក៏បណ្តោះអាសន្ន (ម៉ាក្រូសារជាតិ និង/ឬ មីក្រូសារជាតិ) នៅក្នុងអំឡុងរយៈពេលដ៏ស្រួចស្រាវនៃការអភិវឌ្ឍន៍ផ្នែក សតិបញ្ញា និងរាងកាយ ។ កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃក៏អាចជាលទ្ធផលនៃការប្រឈមផ្ទួនៗគ្នាទៅនឹងការឆ្លងរោគ លក្ខខណ្ឌរស់នៅមានភាពអន់ខ្សោយជាទូទៅ ឬ ក៏ជាការរួមផ្សំនៃកត្តាទាំងពីរនេះតែម្តង ។ លទ្ធផលនេះ គឺជាការលូតលាស់ក្រោម ស្តង់ដារនៃសតិបញ្ញា និងរាងកាយ ។ គេវាស់វែងកង្វះអាហារូបត្ថម្ភរ៉ាំរៃដោយប្រើសូចនាករកំពស់ធៀបនឹងអាយុ ដោយ មានពិន្ទុក្រោម -១, - ២ ឬក៏ -៣SD ពី ប្រជាជនយោង/សំអាងដែលតំណាងឱ្យភាពក្រិនកំរិតស្រាល កំរិតមធ្យម និង ធ្ងន់ធ្ងរ តាមលំដាប់លេខរៀងខាងលើ ។

ពាក្យដែលទាក់ទងគ្នា : អសន្តិសុខស្បៀងរ៉ាំរ៉ៃ  របបអាហារ  សមាសភាពរបបអាហារ   ការបរិភោគ/ប្រើប្រាស់ចំណីអាហារ  គំលាតក្នុងការបរិភោគ/ប្រើប្រាស់ចំណីអាហារ  ការបង្អត់អាហារ  កង្វះអាហារូបត្ថម្ភ អាហារសំបូរសារជាតិ ចិញ្ចឹម  អាហារូបត្ថម្ភ  ស្ថានភាពអាហារូបត្ថម្ភ ក្រេះក្រិនធ្ងន់ធ្ងរ ក្រេះក្រិន កង្វះសារជាតិចិញ្ចឹម  ការបឺតស្រូបចំណី អាហារ  ពិន្ទុ- ហ្សែត ។

*NOTES...*

# CLIMATE CHANGE

The combination of geographic, environmental and socio-economic factors which result in greater variability in weather patterns, noted in terms of temperature fluctuations (referred to as 'global warming'), irregular rainfall, increased frequency of extreme weather events, and less predictability in weather patterns.  Responses to climate change include adaptation, mitigation, and reducing emissions.

Related Terms:  Cross Cutting Issues

## បំរែបំរួលអាកាសធាតុ

ជាការរួមផ្សំនៃកត្តាភូមិសាស្ត្រ បរិស្ថាន និងសង្គមសេដ្ឋកិច្ច ដែលបណ្តាលឱ្យមានការប្រែប្រួលយ៉ាងខ្លាំងនៃស្ថានភាពអាកាសធាតុក្នុងលក្ខខណ្ឌនៃការប្រែប្រួលសីតុណ្ហភាព (យោងទៅលើការឡើងកំដៅនៃពិភពលោក) ការធ្លាក់ភ្លៀងខុសប្រក្រតី ការកើនឡើងនូវចំនួនដងនៃព្រឹត្តិការណ៍អាកាសធាតុធំៗ និងការមិនអាចទស្សន៍ទាយជាមុនបាននូវអាកាសធាតុ ។ ការឆ្លើយតបទៅនឹងបំប្រែបម្រួលអាកាសធាតុនេះរួមមាន ការបន្សុំាំ ការបន្ធូរ និងការកាត់បន្ថយការបញ្ចេញនៃ សំណល់ ឧស្ម័ន ។

ពាក្យដែលទាក់ទងគ្នា : បញ្ហាពហុវិស័យ ។

*NOTES...*

# CLIMATE VARIABILITY

Shifts of weather patterns occurring over short time frames (such as a 12 month period, in the case of monsoons), over longer periods of observation (i.e. decades), or even longer. Climate variability is distinguished from climate change by being predictable and largely cyclical, and is a function of natural forces and patterns.

Related Terms: climate change

## ការផ្លាស់ប្តូរអាកាសធាតុ

ការផ្លាស់ប្តូរស្ថានភាពអាកាសធាតុដែលកើតមាននៅក្នុងរយៈពេលខ្លី (ដូចជារយៈពេល ១២ខែ នៅក្នុងករណីនៃអាកាសធាតុមូសុង) ការសង្កេតរយៈវែង (ឧ. ច្រើនទសវត្សន៏) ឬក៏កាន់តែយូរវែងជាងនេះទៅទៀត ។ ការផ្លាស់ប្តូរអាកាសធាតុ គឺត្រូវបានបែងចែកឱ្យដាច់ពីគ្នា រវាងការផ្លាស់ប្តូរអាកាសធាតុ ដែលអាចព្យាករណ៏បាន និងអាចកើតឡើងយាងទៀងទាត់ ហើយនឹងជាមុខងារនៃកំលាំង និងលំនាំនៃធម្មជាតិ ។

ពាក្យដែលទាក់ទងគ្នា : ការប្រែប្រួលអាកាសធាតុ ។

*NOTES...*

# COMMODITY

In general economics, refers to any good or service which has monetary value. In agriculture, refers to any crops which are internationally traded on spot, or derivatives markets. Important commodities grown across the SE Asia region include rice, maize, soybeans, edible oil, and coffee.

Related Terms: agricultural production, agricultural productivity, comparative advantage.

## ទំនិញ

ជាទូទៅនៅក្នុងន័យសេដ្ឋកិច្ច ទំនិញគឺសំដៅទៅដល់ទំនិញទាំងឡាយណា ឬសេវាណាមួយដែលមានតំលៃគិតជារូបិយវត្ថុ ។ នៅក្នុងវិស័យកសិកម្ម គឺយោងទៅលើដំណាំទាំងឡាយណាមួយដែលត្រូវបានគេជួញដូរជាអន្តរជាតិនៅនឹងកន្លែង ឬ ក៏នៅទីផ្សារដោះដូរទំនិញភ្លាមៗនៅនឹងកន្លែង ដោយគិតជាទឹកប្រាក់ ។ ទំនិញសំខាន់ៗដែលត្រូវបានដាំដុះនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍រួមមាន អង្ករ ពោត សណ្តែក សៀង ប្រេងដែលអាចហូបបាន និងកាហ្វេ ។

ពាក្យដែលទាក់ទងគ្នា : ផលិតកម្មកសិកម្ម ផលិតភាពកសិកម្ម អត្ថប្រយោជន៏ដោយប្រៀបធៀប ។

*NOTES...*

# COMPLEX EMERGENCY

Complex emergencies combine internal conflict with large-scale displacements of people, mass famine or food shortage, and fragile or failing economic, political, and social institutions.  Often, complex emergencies are also exacerbated by natural disasters (WHO 2012)

## ស្ថានភាពបន្ទាន់ដ៏ស្មុគ្រស្មាញ

ស្ថានភាពបន្ទាន់ដ៏ស្មុគ្រស្មាញ គឺរួមផ្សំជាមួយនឹងទំនាស់ផ្ទៃក្នុងដែលមានការធ្វើចំណាកស្រុករបស់ប្រជាជនក្នុងរូបភាពធំ ភាពទុរ្ភិក្សខ្លាំងឬក៏ការខ្វះស្បៀង និងការប្រេះស្រាំ ឬការដួលរលំនៃស្ថាប័នទាំងសេដ្ឋកិច្ច នយោបាយ និង ស្ថាប័នសង្គម ។ ជារឿយៗស្ថានភាពបន្ទាន់ដ៏ស្មុគ្រស្មាញ ក៏ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរថែមទៀតផងដែរ ដោយសារគ្រោះមហន្តរាយ ធម្មជាតិ（WHO 2012）។

*NOTES...*

# COMPREHENSIVE FOOD SECURITY AND VULNERABILITY ASSESSMENT (CFSVA)

A study that describes the food security status of various segments of the population over various parts of a country or region, with the purposes of identifying the underlying causes of food insecurity and vulnerability, and appropriate interventions to deal with problems identified.  Usually conducted and/or led by World Food Programme.

Related Terms:  household budget survey, household income and expenditure survey

## ការវាយតម្លៃដ៏ទូលំទូលាយអំពីសន្តិសុខស្បៀង និងភាពងាយរងគ្រោះ

គឺជាការសិក្សាដែលរៀបរាប់អំពីស្ថានភាពសន្តិសុខស្បៀងរបស់ផ្នែកផ្សេងៗនៃស្រទាប់ប្រជាជន ទៅលើផ្នែកផ្សេងៗគ្នានៃប្រទេសមួយ ឬក៏តំបន់មួយដោយមានគោលបំណងធ្វើការកំណត់អំពីមូលហេតុមូលដ្ឋាន់នៃភាពអសន្តិសុខស្បៀង និងភាព ងាយរងគ្រោះហើយ និងការធ្វើអន្តរាគមន៍សមស្របដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ ។ តាមធម្មតា ការសិក្សានេះត្រូវបានដឹកនាំធ្វើ និង/ឬនាំមុខដោយកម្មវិធីស្បៀងអាហារពិភពលោក ។

ពាក្យដែលទាក់ទងគ្នា : ការអង្កេតពីផែនការចំណាយនៅក្នុងគ្រួសារ ការអង្កេតពីការចំណាយ និងចំណូលនៅក្នុងគ្រួសារ ។

*NOTES...*

# COMPARATIVE ADVANTAGE

The relative financial and economic advantage of producing one commodity instead of another, often determined by the relative rate of return.  This should determine household and country level production choices.

Related Terms:  agricultural productivity

## **អត្ថប្រយោជន៍ដោយប្រៀបធៀប**

អត្ថប្រយោជន៍ដែលមានទំនាលទំនងគ្នារវាងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៃការផលិតទំនិញ/ស្បៀងមួយជំនួសឱ្យទំនិញ/ស្បៀងមួយផ្សេងទៀត ដែលតែងតែត្រូវបានកំនត់ដោយអត្រានៃផលចំណេញផ្សេងៗដែលពាក់ព័ន្ធ។ ទាំងនេះគួរកំណត់ទៅលើ ជំរើស ផលិតកម្មក៏រិតគ្រួសារ និងប្រទេស ។

ពាក្យដែលទាក់ទងគ្នា :  ផលិតភាពកសិកម្ម។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# CONSUMER

In food security contexts, refers to any person reliant on purchases to meet their basic requirements. Usually considered the opposite of ‘producer’, although in practice most households are both consumers and producers of the overall set of basic requirements needed for the household. Households that produce part of their food requirements and purchase part, may be considered a “net consumer” or “net producer”.

Related Terms: consumption

# អ្នកប្រើប្រាស់

នៅក្នុងបរិបទនៃសន្តិសុខស្បៀង គឺសំដៅទៅបុគ្គលណាមួយដែលពឹងពាក់ទៅលើការទិញ ដើម្បីឆ្លើយតបទៅនឹងតំរូវការជា មូលដ្ឋានរបស់ពួកគាត់ ។ តាមធម្មតា អ្នកប្រើប្រាស់ត្រូវបានគេចាត់ទុកថាផ្ទុយគ្នាទៅនឹង "អ្នកផលិត ឬ ផលិតករ" ទោះបីជាក្នុងការអនុវត្តន៏ជាក់ស្តែង គ្រួសារភាគច្រើនបំផុតអាចដើរតួជាអ្នកប្រើប្រាស់/បរិភោគផង និងជាផលិតករផង នៃតំរូវការជាមូលដ្ឋានសរុបដែលចាំបាច់សំរាប់គ្រួសារ ។ គ្រួសារទាំងឡាយណាដែលផលិតផ្នែកខ្លះៗនៃតំរូវការស្បៀងរបស់ពួក គេផង និងទិញផ្នែកខ្លះៗ ថែមទៀតផង អាចនឹងត្រូវបានគេចាត់ទុកថាជា "អ្នកប្រើប្រាស់ផង" និងជា "អ្នកផលិតផង" ។

ពាក្យដែលទាក់ទងគ្នា ៈ ការប្រើប្រាស់/ការបរិភោគ ។

*NOTES...*

# CONSUMPTION

In food security, consumption refers to food consumed by individuals, households, communities and nations. In economics, consumption is typically contrasted with production.

Related Terms: diet, diet composition, dietary diversity, dietary energy consumption, food consumption, food consumption pattern, food consumption score

## ការប្រើប្រាស់

ក្នុងន័យសន្តិសុខស្បៀង ការប្រើប្រាស់គឺសំដៅទៅលើស្បៀង ដែលត្រូវបានបរិភោគដោយបុគ្គល គ្រួសារទាំងសហគមន៍ និងដោយប្រជាជាតិទាំងមូល ។ ក្នុងផ្នែកសេដ្ឋកិច្ចវិញ ពាក្យនេះគឺ មានការផ្ទុយគ្នាទាំងស្រុងតែម្តងជាមួយនឹងពាក្យផលិតកម្ម ។

ពាក្យដែលទាក់ទងគ្នា : របបអាហារ សមាសភាពរបបអាហារ ភាពសំបូរបែបនៃរបបអាហារ ការបរិភោគ/ប្រើប្រាស់ របបអាហារដែលសំបូរថាមពល ការបរិភោគ/ប្រើប្រាស់ចំណីអាហារ លំនាំនៃការបរិភោគ/ការប្រើប្រាស់ស្បៀង ក៏រិតនៃការបរិភោគ/ការប្រើប្រាស់ស្បៀង ។

*NOTES...*

# CRITICAL FOOD POVERTY

An income level below which an individual or household will be unable to meet its minimum nutritional requirements, usually >2 standard deviations below the WHO international standard of 2100 Kcal/day, or the nationally applied equivalent.

Related Terms:  food poverty, food poverty line

## កង្វះស្បៀងធ្ងន់ធ្ងរ

កំរិតចំណូលដែលស្ថិតនៅក្រោមចំណូលដែលបុគ្គលម្នាក់ ឬ គ្រួសារមួយមិនអាចរកបាន ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការអាហារូបត្ថម្ភកំរិតអប្បបរមារបស់ខ្លួនបានតាមធម្មតាគឺតូចជាង -២ SD ក្រោមស្តង់ដារអន្តរជាតិរបស់អង្គការសុខភាពពិភពលោកដែលកំនត់យក ២១00 kcl/១ថ្ងៃ ឬក៏តាមកំរិតសមមូលរបស់ប្រជាជាតិមួយៗ ។

ពាក្យដែលទាក់ទងគ្នា :  កង្វះស្បៀង  បន្ទាត់នៃភាពកង្វះស្បៀង។

*NOTES...*

# CROP PRODUCTION

All activities related to the cultivation and harvest of plants for food or non-food uses.  May be expressed in terms of harvest yields per crop, total amount produced per unit of area or monetary equivalent.

Related Terms:  agriculture, agricultural production

## ផលិតកម្មដំណាំ

សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងការដាំដុះ និងការប្រមូលផលនៃរុក្ខជាតិទាំងឡាយសំរាប់ប្រើប្រាស់ជាស្បៀង ឬមិនមែនជាស្បៀង។ ផលិតកម្មដំណាំ អាចនឹងសម្តែងក្នុងលក្ខខណ្ឌនៃទិន្នផលដែលប្រមូលផលបាននៃដំណាំមួយមុខ បរិមាណសរុបដែលបានផលិតបានក្នុងមួយឯកតានៃតំបន់មួយ ឬក៏ជាថវិកាដែលមាសមមូល ។

ពាក្យដែលទាក់ទងគ្នា :   កសិកម្ម   ផលិតកម្មកសិកម្ម។

*NOTES...*

# CROSS-CUTTING ISSUES

Topics considered to be of common interest or relevant across a wide range of subjects, not limited to a single discipline or area of responsibility.  Examples include climate change, gender and HIV/AIDS.

Related Terms:  climate change

## បញ្ហាពហុវិស័យ

ប្រធានបទដែលត្រូវបានគេចាត់ទុកថាជាប្រយោជន៏រួម ឬក៏ពាក់ព័ន្ធទៅនឹងវិស័យច្រើនទៀត មិនកំនត់ចំពោះវិស័យណាមួយ ឬ ក៏ការទទួលខុសត្រូវ ។ គំរូឧទាហរណ៏ រួមមានការផ្លាស់ប្តូរអាកាសធាតុ យ៉េនឌ័រ មេរោគអេដស៏ ។

ពាក្យដែលទាក់ទងគ្នា :  ការប្រែប្រួលអាកាសធាតុ ។

*NOTES...*

# DEFICIT

The gap between what is available and what is required.  In food security contexts, may refer to an overall lack of food availability, based on national per capita requirements.  Also has application in economics.

Related Terms:  agricultural production, availability, food availability

## ឱនភាព

ឱនភាពគឺគំលាតរវាងអ្វីដែលមាន និងអ្វីដែលជាតំរូវការ ។ ក្នុងបរិបទនៃសន្តិសុខស្បៀង អាចនិយាយសំដៅទៅរកកង្វះ ស្បៀងជាទូទៅដោយផ្អែកទៅលើតំរូវការសម្រាប់បុគ្គលម្នាក់នៅកំរិតជាតិ ។ ឱនភាពក៏ត្រូវបានយកទៅអនុវត្តនៅក្នុងបរិបទសេដ្ឋកិច្ចផងដែរ ។

ពាក្យដែលទាក់ទងគ្នា ៖  ផលិតកម្មកសិកម្ម   លទ្ធភាពមាន   ភាពមានស្បៀង ។

*NOTES...*

# DIET

The combined total intake of food (in any form) from all sources by an individual.

Related Terms: consumption, diet composition, dietary diversity, dietary energy consumption, food consumption, food consumption pattern, food consumption score

## របបអាហារ

របបអាហារ គឺជាការបរិភោគសរុបនៃស្បៀង (ទោះជានៅក្នុងទំរង់បែបណាក៏ដោយ) ដែលបានមកពីប្រភពផ្សេងៗដោយ បុគ្គលម្នាក់ ។

ពាក្យដែលទាក់ទងគ្នា : ការបរិភោគ/ប្រើប្រាស់ សមាសភាពរបបអាហារ ភាពសំបូរបែបនៃរបបអាហារ ការបរិភោគ/ប្រើប្រាស់របបអាហារដែលសំបូរថាមពល ការបរិភោគ/ប្រើប្រាស់ចំណីអាហារ លំនាំនៃការបរិភោគ/ការប្រើប្រាស់ស្បៀង ក៏រិតនៃការបរិភោគ/ការប្រើប្រាស់ស្បៀង។

*NOTES...*

# DIETARY DIVERSITY

The sum of the number of different foods or food groups consumed by an individual or household over a specific time period. This is sometimes weighted by frequency of consumption. More diverse diets tend to be more nutritious.

Related Terms: food consumption, food consumption pattern, food consumption score

## ភាពសំបូរបែបនៃរបបអាហារ

ការបូកចំនួនស្បៀងខុសៗគ្នា ឬក៏ក្រុមអាហារដែលបរិភោគដោយមនុស្សម្នាក់ ឬ គ្រួសារមួយក្នុងរយៈពេលមួយជាក់ លាក់ ។ ជួនកាលចំនុចនេះក៏អាចនឹងត្រូវធ្វើការថ្លឹងថ្លែង ដោយគិតពីចំនួនដងនៃការបរិភោគផងដែរ ។ របបអាហារផ្សេងៗ គ្នាច្រើនមាននិន្នាការទទួលបានអាហារូបត្ថម្ភខ្ពស់ ។

ពាក្យដែលទាក់ទងគ្នា : ការបរិភោគ/ប្រើប្រាស់ចំណីអាហារ លំនាំនៃការបរិភោគ/ការប្រើប្រាស់ស្បៀង ក៏រិតនៃការ បរិភោគ/ការប្រើប្រាស់ស្បៀង ។

*NOTES...*

# DIETARY ENERGY CONSUMPTION

Based on national-level data on food availability and requirements, the average consumption in dietary energy expressed in Kcal/person/day.

Related Terms: dietary energy deficit, dietary energy unit cost, undernourishment.

## ការបរិភោគរបបអាហារមានថាមពល

ផ្អែកទៅលើទិន្នន័យថ្នាក់ជាតិ ស្តីអំពីភាពមានស្បៀង និងតម្រូវការស្បៀង។ ការបរិភោគរបបអាហារមានថាមពលក៏រិតមធ្យម ត្រូវបានគិតជាគីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ។

ពាក្យដែលទាក់ទងគ្នា : កង្វះថាមពលនៅក្នុងរបបអាហារ តម្លៃឯកតាថាមពលនៅក្នុងរបបអាហារ កង្វះសារជាតិចិញ្ចឹម។

*NOTES...*

# DISADVANTAGED GROUP

Any population group that is unable to meet its basic needs and requirements for any reason or combination of reasons.

Related Terms:  vulnerability, vulnerable groups

## ក្រុមជនងាយរងគ្រោះ

ប្រជាជនមួយក្រុមដែលមិនអាចទទួលបានតំរូវការអាហារជាមូលដ្ឋានដោយសារហេតុផលណាមួយ ឬ ដោយសារការរួមផ្សំគ្នានៃហេតុការទាំងអស់នោះ ។

ពាក្យដែលទាក់ទងគ្នា : ងាយរងគ្រោះ  ក្រុមងាយរងគ្រោះ ។

*NOTES...*

# DIVERSIFICATION OF PRODUCTION

Expansion of agricultural activities beyond traditional or core livelihood activities. Can function as a livelihood strategy at the household level or as a business model at the commercial level.

Related Terms: agriculture, agricultural production, agricultural productivity, comparative advantage, food production, garden crops

## ពិពិធកម្មដំណាំ

ការពង្រីកសកម្មភាពកសិកម្មឱ្យលើសអំពីសកម្មភាពបែបបុរាណ ឬ ក៏សកម្មភាពចិញ្ចឹមជីវិតស្នូល ។ ពិពិធកម្មដំណាំអាចមានមុខងារជាយុទ្ធសាស្ត្រនៃរបរចិញ្ចឹមជីវិតនៅកំរិតគ្រួសារ ឬ ក៏ជាគំរូនៃជំនួញធម្មតាមួយនៅកំរិតពាណិជ្ជកម្មទ្រង់ទ្រាយធំ ។

ពាក្យដែលទាក់ទងគ្នា : កសិកម្ម ផលិតកម្មកសិកម្ម ផលិតភាពកសិកម្ម ឧត្តមភាពប្រៀបធៀប ផលិតកម្មស្បៀង ដំណាំក្នុងសួន ។

*NOTES...*

# EMERGENCY

A situation that causes widespread human, material, economic or environmental damage, threatening human lives and/or livelihoods, which exceeds the coping capacities of the affected communities and/or government.

Related Terms:  complex emergency, emergency response.

## ស្ថានភាពបន្ទាន់

ស្ថានភាពមួយដែលបង្កឱ្យមានការខូចខាតរាលដាលធំធេងទៅលើមនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ដែលបណ្តាលឱ្យមានការគំរាមកំហែងដល់អាយុជីវិតរបស់មនុស្ស និង/ឬ ជីវភាពរស់នៅដែលលើសហួសពីសមត្ថភាពដោះស្រាយរបស់មនុស្សនៃសហគមន៍ និង/ឬ រដ្ឋាភិបាលដែលទទួលរងនូវការប៉ះពាល់នោះ ។

ពាក្យដែលទាក់ទងគ្នា :  ស្ថានភាពបន្ទាន់ដ៏ស្មុគ្រស្មាញ   ការឆ្លើយតក្នុងស្ថានភាពបន្ទាន់ ។

*NOTES...*

# EMERGENCY RESPONSE

Any and all actions taken in order to meet needs arising from an emergency.

Related Terms:  emergency response, response analysis

## ការឆ្លើយតបក្នុងស្ថានភាពបន្ទាន់

សកម្មភាពមួយ និងសកម្មភាព ទាំងឡាយដែលប្រកាន់យកដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការដែលកើតឡើងក្នុង ស្ថានភាព បន្ទាន់ ។

ពាក្យដែលទាក់ទងគ្នា :   ការឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់  ការវិភាគពីស្ថានភាពបន្ទាន់ ។

*NOTES...*

# FOOD ACCESS

The ability of individual households to acquire food, either by producing it themselves, hunting, fishing or gathering from wild sources, through purchase, exchanges or as gifts.  Purchasing power is a key determinant of access in most settings.  Food access depends on household purchasing power, which varies in relation to market integration, market access, price policies, and local economies (in terms of employment and livelihoods)

Related Terms:  access, accessibility, access to sufficient food, food access gap

## លទ្ធភាពទទួលបានស្បៀង

លទ្ធភាពនៃគ្រួសារដើម្បីទទួលបាននូវស្បៀង ទោះជាដោយ សារការផលិតស្បៀងដោយខ្លួនឯង ការបរបាញ់ ការនេសាទ ឬក៏ប្រមែប្រមូលអំពីប្រភពដែលមាននៅក្នុងព្រៃ តាមរយៈការទិញ-ដូរគ្នា ឬជារង្វាន់ផ្សេងៗ។ អំណាចនៃការទិញគឺជា កត្តាគន្លឹះនៃលទ្ធភាពដែលទទួលបានស្បៀងនៅក្នុងគ្រប់រូបភាព។ លទ្ធភាពទទួលបានស្បៀងអាស្រ័យទៅលើអំណាចនៃ ការទិញរបស់គ្រួសារនីមួយៗ ដែលប្រែប្រួលផ្សេងៗគ្នា ទាក់ទងទៅនឹងសមាហរណ-កម្មទីផ្សារ លទ្ធភាពចូលដល់ទីផ្សារ គោលនយោបាយនៃតំលៃស្បៀង និងសេដ្ឋកិច្ចក្នុងមូលដ្ឋាន (ក្នុងលក្ខខណ្ឌនៃការងារ និងរបរចិញ្ចឹមជីវិតផ្សេងៗ)។

ពាក្យដែលទាក់ទងគ្នា៖  លទ្ធភាពទទួលបាន  ភាពទទួលបាន  ការមានលទ្ធភាពទទួលបានស្បៀងគ្រប់គ្រាន់ គំលាតក្នុង ការទទួលបានស្បៀង។

*NOTES...*

A B C D E **F** G H I J K L M N O P Q R S T U V W X Y Z

# FOOD ACCESS GAP

This measures the extent to which a household is able to meet the minimum consumption level required for an adequate diet. The difference between what households can access vs. the minimum consumption level is referred to as the access gap.

Related Terms: consumption, diet composition. access, access to sufficient food, food access, food gap

## ភាពខ្វះចន្លោះក្នុងការទទួលបានស្បៀង

ភាពខ្វះចន្លោះក្នុងការទទួលបានស្បៀង គឺវាស់វែងស្ថានភាពនៃគ្រួសារមួយដែលអាចនឹងឆ្លើយតបទៅនឹងកំរិតបរិភោគអប្បបរមាដែលតំរូវឱ្យមានសំរាប់របបអាហារគ្រប់គ្រាន់មួយ ។ ភាពផ្សេងៗគ្នារវាងអ្វីដែលគ្រួសារអាចទទួលបានធៀបទៅនឹងកំរិតបរិភោគអប្បបរមា គឺចង់និយាយសំដៅលើគំលាតនៃការទទួលស្បៀង ។

ពាក្យដែលទាក់ទងគ្នា : ការបរិភោគ/ប្រើប្រាស់ សមាសភាពរបបអាហារ លទ្ធភាពទទួលបាន ការមានលទ្ធភាពទទួលបានស្បៀងគ្រប់គ្រាន់ លទ្ធភាពទទួលបានស្បៀង គំលាត/ភាពខ្វះចន្លោះក្នុងការទទួលបានស្បៀង ។

*NOTES...*

# FOOD AID

Foods provided on a free or nearly-free basis, usually in the aftermath of a crisis event.  Within the United Nations, food aid is provided by the World Food Programme, but local organizations may also undertake food aid operations on an ad hoc basis.  Commodities included in food aid baskets are usually the culturally appropriate basic staple foods required for survival.

Related Terms:  food assistance, food for work

## ជំនួយឧបត្ថម្ភស្បៀង

ស្បៀងដែលផ្តល់ឱ្យដោយមិនយកប្រាក់ ឬក៏ស្មើរតែមិនយកកម្រៃតាមធម្មតាជំនួយស្បៀងអាហាររៀបចំឡើងក្នុង លក្ខខណ្ឌបន្ទាប់ពីមានវិបត្តិអ្វីមួយ ។ នៅក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ ជំនួយជាស្បៀងត្រូវបានផ្តល់ជូនដោយកម្មវិធីស្បៀងអាហារពិភពលោក ក៏ប៉ុន្តែអង្គការ ក្នុងស្រុកក៏អាចធ្វើការផ្តល់ជំនួយជាស្បៀងសំរាប់ជំនួយសង្គ្រោះបន្ទាន់ នេះបានដែរ ដោយឈរនៅលើមូលដ្ឋានជាក់ស្តែង ។ ស្បៀងដែលរួមមានកញ្ចប់ស្បៀងជំនួយ（food aid basket）តាម ធម្មតាគឺជាអាហារមូលដ្ឋាន ដែលមានលក្ខណៈសមស្របទៅតាមប្រពៃណីវប្បធម៌ ដែលជាតំរូវការចាំបាច់សំរាប់ជួយ ជីវិត ។

ពាក្យដែលទាក់ទងគ្នា :  ជំនួយជាស្បៀងអាហារ  ស្បៀងពលកម្ម ។

*NOTES...*

A
B
C
D
E
**F**
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# FOOD AND NUTRITION SECURITY

Food and nutrition security exists when all people, at all times, have physical, social and economic access to food which is consumed in sufficient quantity and quality to meet their dietary needs and food preferences, and is supported by an environment of adequate sanitation, health services and care, allowing for a healthy and active life (Committee for World Food Security, July 2012).

Related Terms: food insecurity, food security, nutrition security

## សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

សន្តិសុខស្បៀងកើតមាននៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្ត នៅគ្រប់ពេលវេលាទាំងអស់សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន។ (គណៈកម្មាធិការទទួលបន្ទុក សន្តិសុខ ស្បៀងពិភពលោក ខែកក្កដា ឆ្នាំ ២០១២)។

ពាក្យដែលទាក់ទងគ្នា៖ អសន្តិសុខស្បៀង សន្តិសុខស្បៀង សន្តិសុខអាហារូបត្ថម្ភ។

*NOTES...*

# FOOD ASSISTANCE

Refers to the overall portfolio of the World Food Programme, and includes food aid, food for work, cash and voucher programs, insurance programs, and nutrition programming.

Related Terms: food aid, food for work

## ជំនួយជាស្បៀងអាហារ

ជំនួយស្បៀងអាហារ គឺសំដៅទៅលើសកម្មភាពរួមនៃកម្មវិធីស្បៀងអាហារពិភពលោក ហើយរួមមានជំនួយជាស្បៀង ស្បៀងពលកម្ម កម្មវិធីផ្តល់សាច់ប្រាក់ និងឥណទាន កម្មវិធីធានារ៉ាប់រង និងកម្មវិធីអាហារូបត្ថម្ភ ។

ពាក្យដែលទាក់ទងគ្នា ៖ ជំនួយជាស្បៀងអាហារ ស្បៀងពលកម្ម ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# FOOD AVAILABILITY

The total quantity of food that is physically present in the area of concern, through domestic production, commercial imports and food aid. This may be aggregated at the regional, national, district or community level. Food availability alone is not enough to ensure food security.

Related Terms: access, availability, stability, utilization.

## លទ្ធភាព/ភាពមានស្បៀង

បរិមាណសរុបនៃស្បៀងដែលបង្ហាញឱ្យឃើញមាននៅក្នុងតំបន់តាមផ្នែករូបវន្តនៃការបារម្ភ តាមរយៈផលិតផលក្នុងស្រុក នាំចូលតាមផ្នែកពាណិជ្ជកម្ម និងជំនួយជាស្បៀង ។ នេះអាចជាការប្រមូលរួមគ្នានៅក៏រិតតំបន់ ជាតិ ស្រុក ឬសហគមន៍ ។ ភាពមានស្បៀងតែឯកឯងគឺមិនគ្រប់គ្រាន់ក្នុងការធានារ៉ាប់រងដល់សន្តិសុខស្បៀងឡើយ ។

ពាក្យដែលទាក់ទងគ្នា : លទ្ធភាពទទួលបាន លទ្ធភាពមាន/ភាពមាន ស្ថេរភាព ការស្តុក ការបឺតស្រូបចំណីអាហារ ។

*NOTES...*

# FOOD BALANCE SHEET

Food balance sheets (FBS) are an accounting of food availability versus requirements for selected commodities. A balance sheet includes: the quantity of food production plus imports plus opening-year food stocks, minus food exports, minus end of year closing food stocks, minus all non-food use (animal feed, industrial use, seed, wastage and other non-food use). This is then compared with an estimation of food requirements (total population times average caloric requirement) to give a rough indication of the food gap or surplus. This then serves to guide import/export plans, food aid planning and other food security planning. Food balance sheets may be for a single commodity (such as rice) or for multiple commodities. They are usually prepared annually at the national level, but depending on data availability, could be prepared on a seasonal basis and/or at sub-national levels.

Related Terms: agriculture, agricultural productivity, food production

## តារាងតុល្យភាពស្បៀង

តារាងតុល្យភាពស្បៀង គឺជាតណេទាននៃភាពមានស្បៀង ធៀបទៅនឹងតំរូវការស្បៀងដែលបានជ្រើសរើស ។ តារាងតុល្យភាពរួមមានបរិមាណនៃផលិតកម្មស្បៀង បូកនឹងការនាំចូល បូកនឹងស្តុកស្បៀងប្រចាំឆ្នាំ ដកការនាំស្បៀងចេញ ដក ស្តុកស្បៀងនៅពេលបញ្ចប់ចុងឆ្នាំ ដកការប្រើប្រាស់អ្វីៗទាំងអស់ដែលមិនមែនជាស្បៀង ( ចំណីអាហារសត្វ ការប្រើប្រាស់ សំរាប់ឧស្សាហកម្ម គ្រាប់ពូជ កាកសំណល់ និងការប្រើប្រាស់អ្វីៗផ្សេងទៀតដែលមិនមែនជាស្បៀង) ។ ដូចនេះគឺជាការប្រៀបធៀបនូវចំនួនប៉ាន់ស្មាននៃតំរូវការស្បៀង ( ប្រជាជនសរុប ខ តំរូវការកាឡូរីគិតជាមធ្យម) ដើម្បីផ្តល់នូវសញ្ញា បង្ហាញ ដោយគ្រួសៗនៃគំលាតស្បៀងអាហារ ឬក៏ការលើសស្បៀង ។ ដូចនេះគឺប្រើដើម្បីបង្ហាញផ្លូវអំពីគំរោងផែនការ នាំចេញស្បៀង ការធ្វើផែនការជំនួយជាស្បៀង និងការធ្វើសន្តិសុខស្បៀងផ្សេងៗទៀត ។ តារាងតុល្យភាពស្បៀងអាច បញ្ជាក់តែមុខស្បៀងតែមួយគត់ ( ដូចជាអង្ករ) ឬក៏សំរាប់មុខស្បៀងចំរុះតែម្តងក៏បាន ។ តាមធម្មតា វាត្រូវបានគេរៀបចំប្រចាំឆ្នាំតែម្តងនៅថ្នាក់ជាតិ ក៏ប៉ុន្តែវាអាស្រ័យទៅលើភាពមានទិន្នន័យ គេអាចនឹងរៀបចំ បានដោយផ្អែកទៅតាមរដូវ កាលនីមួយៗ ឬនៅកំរិតថ្នាក់ក្រោមជាតិ ។

ពាក្យដែលទាក់ទងគ្នា : កសិកម្ម   ផលិតភាពកសិកម្ម   ផលិតកម្មស្បៀង ។

*NOTES...*

# FOOD BANK

A mechanism at the community level for holding food reserves for communal use on a periodic or temporary basis. Across SE Asia, this function is commonly affiliated with rice mills at the village or district level.

Related Terms: food reserve, food storage

## ធនាគារស្បៀង

គឺជាយន្តកម្មមួយនៅថ្នាក់សហគមន៍ ដើម្បីនឹងរៀបចំទុកស្បៀងបំរុងសំរាប់ការប្រើប្រាស់នៅក្នុងសហគមន៍ ដោយផ្អែកលើមូលដ្ឋានរយៈពេលមួយកំនត់ ឬក៏ជាបណ្តោះអាសន្ន។ នៅទូទាំងអាស៊ីអាគ្នេយ៍ មុខងារនេះគឺមានសម្ព័ន្ធភាពជារួមជាមួយ នឹងរោងម៉ាស៊ីនកិនស្រូវនៅថ្នាក់ភូមិ ឬថ្នាក់ស្រុក ។

ពាក្យដែលទាក់ទងគ្នា :   ការត្រៀមបំរុងស្បៀងទុក  ការស្តុកស្បៀង។

*NOTES...*

# FOOD CONSUMPTION

Food consumption refers to the amount of food consumed by individuals, households, communities and nations. Indirect indicators associated with food availability or household expenditure are often used to estimate food consumption. Food consumption per person is the amount of food eaten, in terms of quantity, of each commodity. The dietary energy consumption per person is the amount of food, measured in Kcal (calories) per day, for each individual in the total population. This tells us whether people are getting enough food to eat, but does not tell us about the nutritional value (that is, the macro or micronutrients) of food consumed.

Related Terms: consumption, dietary energy consumption, food consumption distribution, food consumption gap, indicator, utilization

## ការប្រើប្រាស់ស្បៀង

ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ គឺចង់និយាយ សំដៅទៅដល់បរិមាណនៃចំណីអាហារដែលត្រូវបានបរិភោគ/ស្បៀងដែលត្រូវបានប្រើប្រាស់ដោយបុគ្គលម្នាក់ៗ គ្រួសារ សហគមន៍ និងប្រទេសជាតិនីមួយៗ។ សូចនាករប្រយោលដែល មានការរួមចំណែកជាមួយនឹងភាពមានស្បៀង ឬការចំណាយនៅក្នុងគ្រួសារ តែងតែត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃពីការប្រើប្រាស់ ស្បៀង/បរិភោគចំណីអាហារនេះ។ ការប្រើប្រាស់ស្បៀង/ បរិភោគចំណីអាហារក្នុងបុគ្គល ម្នាក់ៗ គឺជាបរិមាណនៃចំណីអាហារដែលបានបរិភោគ ក្នុងន័យសំដៅដល់បរិមាណរបស់មុខអាហារនិមួយៗ។ ការបរិភោគរបបអាហារដែលសំបូរថាមពលដោយបុគ្គលម្នាក់ៗ គឺជាបរិមាណនៃចំណីអាហារដែលវាស់វែងគិតជាគីឡូកាឡូរី ក្នុង ១ថ្ងៃ ដោយបុគ្គលម្នាក់ៗនៅក្នុងចំណោមប្រជាជនទាំងអស់ជាសរុប ។ ចំណុចនេះប្រាប់ឱ្យយើងដឹងថា តើប្រជាជនទាំងអស់កំពុង តែមានចំណីអាហារគ្រប់គ្រាន់សំរាប់បរិភោគដែរឬទេ ប៉ុន្តែចំណុចនេះមិនបានប្រាប់ឱ្យយើងដឹងពីតម្លៃអាហារូបត្ថម្ភ (គឺតម្លៃអាហារូបត្ថម្ភរបស់ម៉ាក្រូសារជាតិ ឬមីក្រូសារជាតិ) នៃចំណីអាហារដែលប្រជាជនទាំងអស់នោះបានបរិភោគទេ។

ពាក្យដែលទាក់ទងគ្នា : ការប្រើប្រាស់/ការបរិភោគ   ការបរិភោគរបបអាហារដែលសំបូរថាមពល  របាយនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ  ភាពខ្វះចន្លោះក្នុងការប្រើប្រាស់ស្បៀង  សូចនាករ ការបឹតស្រូប ។

*NOTES...*

# FOOD CONSUMPTION DISTRIBUTION

Food consumption distribution refers to the variation of consumption within a population. It reflects differences in consumption due to either socioeconomic factors (such as income, poverty) and/or biological factors (such as gender, age, body weight and physical activity levels).

Related Terms: consumption, dietary energy consumption, food consumption distribution, food consumption gap, indicator, utilization

## របាយនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ

របាយនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ គឺចង់និយាយសំដៅទៅដល់ការប្រែប្រួល/ការផ្លាស់ប្តូរ ក្នុងការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារនៅក្នុងស្រទាប់ប្រជាជន។ វាឆ្លុះបញ្ចាំងអំពីសភាពផ្សេងៗគ្នាក្នុងការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារដោយសារមកពីកត្តាសង្គមសេដ្ឋកិច្ច (ដូចជាប្រាក់ចំណូល ភាពក្រីក្រ) និង/ ឬ មួយមកពីកត្តាជីវសាស្ត្រ (ដូចជា ភេទ អាយុ កំរិតនៃទម្ងន់រាងកាយ និងកំរិតនៃសកម្មភាពរបស់រាងកាយ )។

ពាក្យដែលទាក់ទងគ្នា ៖ ការប្រើប្រាស់/ការបរិភោគ ការបរិភោគរបបអាហារដែលសំបូរថាមពល របាយនៃការប្រើ ប្រាស់ស្បៀង/បរិភោគចំណីអាហារ ភាពខ្វះចន្លោះក្នុងការប្រើប្រាស់ស្បៀង សូចនាករ ការបឹតស្រូប។

*NOTES...*

# FOOD CONSUMPTION GAP

The difference between the level of food consumption required to meet nutrition needs and actual food consumption.

Related Terms: consumption, dietary energy consumption, food access gap, food consumption distribution, food consumption gap.

## ភាពខ្វះចន្លោះ/គម្លាតក្នុងការប្រើប្រាស់ស្បៀង/ បរិភោគចំណីអាហារ

ភាពខុសៗគ្នារវាងកំរិតនៃការបរិភោគចំណីអាហារដែលត្រូវបានគេតំរូវឱ្យបរិភោគ ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការអាហារូបត្ថម្ភ និងឆ្លើយតបទៅនឹងការបរិភោគអាហារត្រឹមត្រូវជាក់ស្តែង។

ពាក្យដែលទាក់ទងគ្នា : ការប្រើប្រាស់/ការបរិភោគ ការបរិភោគរបបអាហារដែលសំបូរថាមពល ភាពខ្វះចន្លោះ/ គំលាតក្នុងការទទួលបានស្បៀង របាយនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ភាពខ្វះចន្លោះក្នុងការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ។

*NOTES...*

# FOOD CONSUMPTION PATTERN

The composition and frequency of food consumption within a given reference period, measured in grams or kcal/day.

Related Terms: consumption, food consumption, food consumption distribution, food consumption gap.

## គំរូនៃការប្រើប្រាស់ស្បៀង / ការបរិភោគចំណីអាហារ

សមាសភាព និងចំនួនដងនៃការបរិភោគចំណីអាហារ នៅក្នុងអំឡុងរយៈពេលយោងជាកំណត់មួយ  ដោយវាស់វែងគិតជា ក្រាម ឬគីឡូកាឡូរី/ក្នុងមួយថ្ងៃ ។

ពាក្យដែលទាក់ទងគ្នា :  ការប្រើប្រាស់/ការបរិភោគ  ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ  របាយនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ   គំលាតក្នុងការទទួលបានស្បៀង/ចំណីអាហារ ។

*NOTES...*

# FOOD CONSUMPTION SCORE

A proxy indicator of food consumption that considers both the energy (calories) and nutrient (macro- and micronutrient content) value of the food that households eat.  It is calculated based on the volume and type of foods eaten plus the frequency of consumption per food over a seven-day period.

Related Terms:  diet, dietary diversity, food consumption, food consumption gap.

## ពិន្ទុនៃការប្រើប្រាស់ស្បៀង

សូចនាករតំណាងនៃការប្រើប្រាស់ស្បៀង ដែលពិចារណាទាំងថាមពល (កាឡូរី) និងសារជាតិចិញ្ចឹម (ម៉ាក្រូ និងមីក្រូសារជាតិ) តំលៃនៃស្បៀងដែលគ្រួសារបរិភោគ។ វាត្រូវបានគណនាដោយផ្អែកទៅលើវ៉ូលូម និងប្រភេទនៃចំណីអាហារដែលបានបរិភោគ និងមុខចំណីអាហារមួយមុខក្នុងរយៈពេល៧ថ្ងៃ ។

ពាក្យដែលទាក់ទងគ្នា៖  របបអាហារ  ភាពសំបូរបែបនៃរបបអាហារ   ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ  គំលាតក្នុងការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ។

*NOTES...*

A B C D E **F** G H I J K L M N O P Q R S T U V W X Y Z

A
B
C
D
E
**F**
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# FOOD CONTAMINATION

Any and all factors in the production, processing, handling, preparation or disposal of food which compromises food safety, rendering it unfit for human consumption due to health risks.

Related Terms: food safety, hygiene, sanitation, unsafe food, utilization

## ភាពកខ្វក់នៃចំណីអាហារ

កត្តាណាមួយ និងកត្តាទាំងអស់នៅក្នុងព្រឹត្តិកម្ម ការកែច្នៃ ការរៀបចំ និងការបញ្ចេញចោលនៃអាហារ/ស្បៀង ដែលសំរបសំរួលដល់សុវត្ថិភាពស្បៀងដែលបណ្តាលឱ្យមានភាពមិនសក្តិសមសំរាប់មនុស្សបរិភោគ ឬ ប្រើប្រាស់ ដោយសារតែមានហានិភ័យប៉ះពាល់ទៅលើសុខភាព ។

ពាក្យដែលទាក់ទងគ្នា : សុវត្ថិភាពស្បៀង អនាម័យ ភាពស្អាត អសុវត្ថិភាពស្បៀង ការបឹតស្រូប។

*NOTES...*

# FOOD CULTURE

The shared knowledge, attitudes, practices, behaviours and traditions surrounding food specific to a particular cultural grouping.

Related Terms: food taboos

## វប្បធម៌ក្នុងការប្រើប្រាស់ស្បៀង/ផលិតស្បៀង

ការចែករំលែកចំណេះដឹង ឥរិយាបថ ការប្រព្រឹត្តអកប្បកិរិយា និងប្រពៃណីនៅជុំវិញរឿងចំណីអាហារជាក់លាក់ចំពោះក្រុមប្រពៃណីវប្បធម៌ពិសេស ។

ពាក្យដែលទាក់ទងគ្នា : តំណមអាហារ/ការតមអាហារ ។

*NOTES...*

# FOOD DATA

Any indicator(s) relevant to food.  May include data from sectors such as agriculture, economics, trade and industry, nutrition, public health, water and sanitation, and the environment.

Related Terms:  indicator, information needs, proxy indicator, situation analysis.

## ទិន្នន័យស្បៀង

សូចនាករណាមួយដែលពាក់ព័ន្ធទៅនឹងចំណីអាហារ ។ គេអាចរាប់បញ្ចូលទាំងទិន្នន័យមកពីផ្នែកផ្សេងៗដូចជា កសិកម្ម សេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម អាហារូបត្ថម្ភសុខភាព សាធារណៈ ទឹកស្អាត និង អនាម័យ ហើយនឹងបរិស្ថាន ។

ពាក្យដែលទាក់ទងគ្នា :  សូចនាករ  តំរូវការផ្នែកព័ត៌មាន  សូចនាករតំណាង  ការវិភាគពីស្ថានភាព ។

*NOTES...*

# FOOD DEPRIVATION

Food deprivation refers to the condition of people whose food consumption is continuously below what the body needs.  FAO's measure of food deprivation is based on the distribution of food consumption expressed in terms of dietary energy.  Deprivation is measured by a) the prevalence of undernourishment and b) the total number of undernourished in total population.

The intensity of food deprivation measure indicates how much food-deprived people fall short of minimum food needs in terms of dietary energy.  It is measured as the difference between the minimum dietary energy and the average dietary energy consumption of the undernourished population (the food-deprived).

Related Terms: food consumption, malnutrition, undernourishment,

## ការបង្អត់អាហារ

ការបង្អត់អាហារគឺចង់និយាយសំដៅទៅរកលក្ខខណ្ឌរបស់ប្រជាជន ដែលការបរិភោគចំណីអាហាររបស់គាត់គឺបន្តជាប់គ្នានៅក្រោមអ្វីដែលរាងកាយត្រូវការ ។ រង្វាស់របស់អង្គការ FAO ទៅលើភាពអត់ឃ្លានអាហារ គឺផ្អែកទៅលើរបាយនៃការបរិភោគចំណីអាហារដែលបញ្ជាក់ជាលក្ខខណ្ឌនៃ ថាមពលក្នុងរបបអាហារ ។ ភាពអត់ឃ្លានត្រូវបានវាស់វែងដោយ ក) អត្រាប្រេវ៉ាឡង់នៃភាពខ្សត់ខ្សោយនូវសារជាតិចិញ្ចឹម និង ខ) ចំនួនសរុបនៃកង្វះសារជាតិចិញ្ចឹមនៅក្នុងចំណោម ប្រជាជនសរុបទាំងអស់ ។

<u>អាំងតង់ស៊ីតេនៃភាពអត់ឃ្លានចំណីអាហារ</u> រង្វាស់ចង្អុលបង្ហាញអំពីតើចំនួនប្រជាជនប៉ុន្មាននាក់ ដែលទទួលរងនូវភាពអត់ឃ្លាន ធ្លាក់ទៅក្នុងតំរូវការស្បៀងក៏រិតអប្បបរមាក៏រិតរយៈពេលខ្លីក្នុងលក្ខខណ្ឌរបបអាហារថាមពល ។ វា ត្រូវបានវាស់វែង ជាភាពផ្សេងៗគ្នារវាងរបបអាហារថាមពលអប្បបរមា និងការបរិភោគរបបអាហារក៏រិតមធ្យមនៃប្រជាជនដែលមានបញ្ហាកង្វះសារជាតិចិញ្ចឹម ( អ្នកដែលអត់ឃ្លាន) ។

ពាក្យដែលទាក់ទងគ្នា :   ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ  កង្វះអាហារូបត្ថម្ភ   កង្វះសារជាតិចិញ្ចឹម ។

*NOTES...*

# FOOD DISTRIBUTION

1. The process through which food aid is provided to targeted recipients. Modalities of distribution will vary based on the local context (severity of situation, numbers of people affected, function of markets etc), commodities provided and supporting logistics required.

2. At the household level, can refer to the consumption patterns within a given family group, such that different members may consume food of different quality and quantity.

Related Terms: food culture, food consumption pattern

## ការចែកចាយស្បៀង

១) ជាដំណើរការដែលតាមរយៈដំណើរការនោះជំនួយ ជាស្បៀងត្រូវបានផ្តល់ដល់អ្នកទទួលដែលជាក្រុមគោលដៅ ។ គំរូនៃការចែកចាយនឹងប្រែប្រួលដោយផ្អែកទៅ លើបរិបទក្នុងមូលដ្ឋាន (ភាពធ្ងន់ធ្ងរនៃស្ថានភាពចំនួនប្រជាជនដែលទទួលរងនូវផលប៉ះពាល់តួនាទីរបស់ទីផ្សារ ។ល។) ទំនិញដែលត្រូវបានផ្តល់ និងការគាំទ្រផ្នែកភស្តុភារដែលជាតំរូវការ ។ ២) នៅថ្នាក់គ្រួសារអាចនិយាយ សំដៅទៅដល់គំរូនៃការប្រើប្រាស់ស្បៀងនៅក្នុងក្រុមគ្រួសារមួយដែលបានកំណត់ ដូចជា សមាជិកផ្សេងៗគ្នា អាចនឹងបរិភោគចំណីអាហារដែលមានគុណភាព និងបរិមាណខុសៗគ្នា ។

ពាក្យដែលទាក់ទងគ្នា : វប្បធម៌ក្នុងការប្រើប្រាស់ស្បៀង គំរូនៃការប្រើប្រាស់ស្បៀង/ការបរិភោគចំណីអាហារ ។

*NOTES...*

# FOOD DIVERSIFICATION

Relates to the overall variety of food consumed within an individual or household's diet. Those who consume fewer kinds of food items are generally less nourished than those who consume a more diversified diet.

Related Terms: diet, dietary diversity

## ភាពចម្រុះនៃអាហារចំរុះមុខ

ទាក់ទិនទៅនឹងភាពខុសៗគ្នាជាទូទៅនៃស្បៀងដែលបានបរិភោគនៅក្នុងរបបអាហាររបស់បុគ្គលម្នាក់ៗ ឬ របស់គ្រួសារនីមួយៗ។ អ្នកទាំងឡាយណាដែលបរិភោគអាហារប្រភេទតិចតួចជាងនៅមុខអាហារទាំងឡាយ ជាទូទៅគឺបានទទួលសារជាតិចិញ្ចឹមតិចជាងអ្នក ដែលបរិភោគអាហារដែលមានលក្ខណៈចំរុះជាង ។

ពាក្យដែលទាក់ទងគ្នា : របបអាហារ ភាពសំបូរបែបនៃរបបអាហារ។

*NOTES...*

# FOOD ECONOMY

How households obtain their food and income. The Food Economy Approach was developed by Save the Children to measure the impact of a shock to a household's food security. Combined with early warning information, it can help forecast the impact of different events.

Related Terms: food access, food consumption, livelihood, livelihood groups

## សេដ្ឋកិច្ចស្បៀង

របៀបដែលគ្រួសារនីមួយៗបានទទួលស្បៀងអាហារ និងចំណូលរបស់ពួកគេ ។ យុទ្ធសាស្ត្រសេដ្ឋកិច្ចស្បៀងអាហារត្រូវបានបង្កើតឡើងដោយអង្គការសង្គ្រោះកុមារ ដើម្បីវាស់វែងដល់ផលប៉ះពាល់នៃព្រឹត្តការណ៍ដឹតក់ស្លុតមួយទៅនឹងសន្តិសុខស្បៀងរបស់គ្រួសារ ។ ដោយបូកបញ្ចូលជាមួយនឹងការព្រមានភ្លាមៗ ព័ត៌មានអាចជួយធ្វើការទស្សន៍ទាយផលប៉ះពាល់នៃព្រឹត្តការណ៍ផ្សេងៗគ្នាដែលនឹងកើតឡើង ។

ពាក្យដែលទាក់ទងគ្នា : លទ្ធភាពទទួលបានស្បៀង ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ការចិញ្ចឹមជីវិត ក្រុមអ្នកមានមុខរបរ ។

*NOTES...*

# FOOD EXPENDITURE SHARE

The proportion of a household's total expenditure which is spent on food.  Also known as the Engel Ratio.

Related Terms:  food consumption gap, food poverty line

## ចំណែកដែលត្រូវចំណាយទៅលើស្បៀងអាហារ

សមាមាត្រនៃការចំណាយសរុបរបស់គ្រួសារនីមួយៗដែលត្រូវបានចំណាយទៅលើស្បៀងអាហារ ។   គេក៏ដឹងផងដែរថា ជាអត្រារ៉ាត្យូអែនជែល ។

ពាក្យដែលទាក់ទងគ្នា :  គម្លាតក្នុងការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារ ការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ។

*NOTES...*

A B C D E **F** G H I J K L M N O P Q R S T U V W X Y Z

# FOOD FOR WORK

A way to distribute food aid.  The payment of food as wages (in whole or in part) in return for labour-intensive work programs designed to create or rehabilitate community or public assets (called community or public works, respectively).

Related Terms:  food aid, food assistance

## ស្បៀងពលកម្ម

គឺជាវិធីមួយ៉ាងសម្រាប់ធ្វើការចែកចាយជំនួយជាស្បៀង ។

ពាក្យដែលទាក់ទងគ្នា :  ជំនួយជាស្បៀង  ជំនួយជាស្បៀង។

*NOTES...*

# FOOD INSECURITY

Food insecurity exists when people are at risk of, or actually are consuming food of inadequate quality, quantity (or both) to meet their nutritional requirements. This may be a result of the physical unavailability of food, a lack of social or economic access to adequate food, inadequate food utilization or a combination thereof. Food insecurity may be chronic, or acute, transitory, or cyclical. It may characterise individuals, households, groups, areas or an entire country.

Related Terms: chronic food insecurity, food security, household food security.

## អសន្តិសុខស្បៀង

កើតមានឡើងនៅពេលណាដែលប្រជាជនត្រូវប្រឈមនឹង ឬ ដោយជាក់ស្តែងកំពុងតែបរិភោគនូវចំណីអាហារដែលមានបរិមាណគុណភាពមិនគ្រប់គ្រាន់ (ឬទាំងពីរតែម្តង) ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការរបស់ពួកគេ។ នេះអាចជាលទ្ធផល នៃភាពគ្មានស្បៀងផ្នែករូបវន្ត កង្វះលទ្ធភាព ក្នុងការទទួលស្បៀងបានគ្រប់គ្រាន់តាមផ្នែកសង្គម និងសេដ្ឋកិច្ច ការប្រើប្រាស់ និងបឺតស្រូបស្បៀងមិនបានគ្រប់គ្រាន់ ឬក៏ជាការរួមផ្សំនូវចំណុចទាំងអស់ដែលបាននិយាយរួចមកហើយនេះ។ អសន្តិសុខស្បៀងអាចមាន លក្ខណៈរ៉ាំរ៉ៃ ឬស្រួចស្រាវបណ្តោះអាសន្ន ឬជាវដ្ត។ វាអាចមានលក្ខណៈជាបុគ្គល ជាគ្រួសារ ជាក្រុមតាមតំបន់ ឬក៏ប្រទេសទាំងមូល ។

ពាក្យដែលទាក់ទងគ្នា : អសន្តិសុខស្បៀងរ៉ាំរ៉ៃ សន្តិសុខស្បៀង សន្តិសុខស្បៀងនៅក្នុងគ្រួសារ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# FOOD INSUFFICIENCY

The experience of periodically or consistently not having enough food to eat. Pertains to food quantity, not quality, and is not a formal measurement, but rather a qualitative judgment.

Related Terms:  availability, food availability

## កង្វះខាតស្បៀងអាហារ

ការជួបប្រទះនឹងការពុំមានស្បៀងគ្រប់គ្រាន់សំរាប់បរិភោគនៅមួយដំណាក់កាលណានោះ ឬក៏ជាប់ជាបន្ត ។ ទាក់ទិនទៅនឹងបរិមាណស្បៀងអាហារមិនមានគុណភាព ហើយពុំមានជារង្វាស់ជាផ្លូវការ ប៉ុន្តែជាការវិនិច្ឆ័យតាមបែបបរិមាណច្រើនជាង ។

ពាក្យដែលទាក់ទងគ្នា :    លទ្ធភាពមាន/ភាពមាន   ភាពមានស្បៀង។

*NOTES...*

## FOOD INTAKE

The same as food consumption.  Refers to all foods consumed by an individual.

Related Terms:  consumption, food consumption

## ការបរិភោគអាហារ/ការបឺតស្រូបអាហារ

ដូចគ្នានឹងការប្រើប្រាស់ស្បៀងផងដែរ ។ គឺចង់និយាយសំដៅទៅដល់ស្បៀងអាហារទាំងអស់ដែលបរិភោគសម្រាប់បុគ្គលម្នាក់ៗ ។

ពាក្យដែលទាក់ទងគ្នា :  ការប្រើប្រាស់/ការបរិភោគ   ការប្រើប្រាស់ស្បៀង/ការបរិភោគចំណីអាហារ ។

*NOTES...*

# FOOD POVERTY

The inability of an individual or household to obtain the food it requires for basic health and nutrition as a result of poor availability, access or utilization.

Related Terms: critical food poverty, food poverty line.

## ភាពក្រីក្រស្បៀងអាហារ/កង្វះខាតស្បៀងអាហារ

ភាពអសមត្ថភាពរបស់បុគ្គល ឬគ្រួសារក្នុងការទទួលបានស្បៀង ដែលតំរូវឱ្យមានសំរាប់សុខភាព និងអាហារូបត្ថម្ភដែលជាលទ្ធផលនៃការមានស្បៀងខ្សត់ខ្សោយ លទ្ធភាពទទួលស្បៀង ឬក៏ការប្រើប្រាស់ និងបឺតស្រូបស្បៀង។

ពាក្យដែលទាក់ទងគ្នា : ភាពក្រីក្រស្បៀង/កង្វះខាតស្បៀងធ្ងន់ធ្ងរ បន្ទាត់នៃភាពកង្វះខាតស្បៀង។

*NOTES...*

# FOOD POVERTY LINE

The cost of purchasing a combination of foods that are adequate to meet minimum daily nutritional requirements.  This varies from country to country, based on consumption patterns, market prices and methodologies applied to determining the overall poverty line.

Related Terms:  critical food poverty, food poverty

## បន្ទាត់នៃភាពកង្វះខាតស្បៀងអាហារ

តំលៃនៃការទិញ ការរួមផ្សំនៃស្បៀង ដែលគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតំរូវការអាហារូបត្ថម្ភប្រចាំថ្ងៃក្នុងកំរិតអប្បបរមា ។ ចំណុចនេះប្រែប្រួលខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដោយផ្អែកទៅលើគំរូបរិភោគចំណីអាហារតំលៃនៅលើទីផ្សារ និងវិធីសាស្ត្រដែលបានអនុវត្តន៍ដើម្បីកំណត់អំពីបន្ទាត់ភាពក្រីក្រជាទូទៅ ។

ពាក្យដែលទាក់ទងគ្នា :  ភាពក្រីក្រស្បៀង/កង្វះខាតស្បៀងធ្ងន់ធ្ងរ   ភាពក្រីក្រស្បៀង/កង្វះខាតស្បៀង ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# FOOD PRODUCT

Any edible item which has undergone any form of processing prior to consumption.

## ផលិតផលស្បៀង

មុខអាហារណាមួយដែលអាចបរិភោគបានទទួលរងនូវការកែច្នៃអាហារក្នុងទម្រង់ណាមួយ នៅមុនពេលដែលអាហារនោះត្រូវបានបរិភោគ ។

*NOTES...*

# FOOD PRODUCTION

Food (crops, livestock, fisheries, horticulture, etc) that is purposely grown, cultivated or raised for own consumption or sale, as opposed to foods sourced from wild or commonly held areas (i.e.  forests, rivers, etc).

Related Terms:  food access, food availability, forest foods

## ផលិតកម្មស្បៀង

ស្បៀងដែលត្រូវបានគេដាំដុះ  ចិញ្ចឹមសម្រាប់ប្រើប្រាស់/បរិភោគខ្លួនឯង ឬទុកសម្រាប់លក់ ដែលផ្ទុយគ្នាទៅនឹងស្បៀងអាហារដែលមានប្រភពពីក្នុងព្រៃ (គឺមានន័យថា ព្រៃឈើ បឹង/ទន្លេ,,,,  ។ល។) ។

ពាក្យដែលទាក់ទងគ្នា :  លទ្ធភាពទទួលបានស្បៀង  ភាពមានស្បៀង  ស្បៀងដែលរកបានពីក្នុងព្រៃឈើ ។

*NOTES...*

# FOOD PRODUCTION INDICES

Food production indices are based on the sum of price-weighted quantities, after deducting similarly weighted quantities of seed and feed.  Production quantities of each commodity are weighted by 1999-2001 average international commodity prices and summed for each year.  In order to obtain the index, the aggregate for a given year is divided by the average aggregate of the base period 1999-2001.

Related Terms:  agriculture, agricultural production, agricultural productivity, crop production.

## សន្ទស្សន៍ផលិតកម្មស្បៀង

សន្ទស្សន៍ផលិតកម្មស្បៀង គឺផ្អែកទៅលើផលបូកសរុបនៃបរិមាណដែលបានថ្លឹងថ្លែងតម្លៃ បន្ទាប់ពីបានដកបរិមាណដែលបានថ្លឹងថ្លែងដូចគ្នានៃគ្រាប់ពូជ និងចំណីអាហារសត្វ ។ បរិមាណផលិតកម្មនៃមុខទំនិញ/អាហារនិមួយៗត្រូវបានគេធ្វើការថ្លឹងថ្លែងដោយតំលៃស្បៀង/អាហារអន្តរជាតិ គិតជាមធ្យម នៅឆ្នាំ១៩៩៩ - ២០០១ ហើយត្រូវបានគេបូកសរុបសំរាប់ មួយឆ្នាំៗ ។ ដើម្បីទទួលបាននូវសន្ទស្សន៍នេះ ចំនួនសរុបទាំងអស់សំរាប់ឆ្នាំមួយដែលបានកំណត់ ត្រូវយកទៅចែកជាមួយ នឹងចំនួនសរុបទាំងអស់គិតជាមធ្យមនៃរយៈពេលជាមូលដ្ឋាន ឆ្នាំ ១៩៩៩-២០០១ ។

ពាក្យដែលទាក់ទងគ្នា :   កសិកម្ម   ផលិតកម្មកសិកម្ម   ផលិតភាពកសិកម្ម  ផលិតកម្មដំណាំ ។

*NOTES...*

# FOOD PROCESSING

Any procedure used to convert edible raw materials into a different form for the purposes of consumption.  Advantages may include longer storage, easier consumption, simpler transport, and improved taste and palatability.  Methods are highly variable, including cooking, milling, drying, salting, and many more.

Related Terms:  food product, food production

## ការកែច្នៃស្បៀងអាហារ

វិធីណាមួយដែលគេប្រើដើម្បីបំលែងវត្ថុធាតុដើមដែលអាចបរិភោគបានឱ្យទៅជាទម្រង់មួយផ្សេងទៀត ក្នុងគោលបំណងប្រើប្រាស់/បរិភោគ។ អត្ថប្រយោជន៏អាចរួមមាន អាចស្តុកទុកបានយូរ ងាយប្រើប្រាស់/ងាយបរិភោគជាងមុន  ងាយ ស្រួលក្នុងការដឹកជញ្ជូនជាងមុន និងមានរសជាតិប្រសើរជាងមុន និងមានឱជារស។

វិធីកែច្នៃ គឺមានការផ្លាស់ប្តូរច្រើនបែប ច្រើនយ៉ាង រួមមាន ស្ងោរ ហាលសម្ងួត ប្រឡាក់អំបិល ហើយនិងនៅមានវិធីកែច្នៃជាច្រើនរបៀបថែមទៀត ។

*NOTES...*

# FOOD QUALITY

1. Refers to the overall safety and hygiene standards of a given food. Foods with high quality standards are those which pose no threat to human health.

2. May also refer to foods conferred with higher nutritional, cultural or economic value by virtue of how or where they were cultivated or produced.

3. In nutritional contexts, foods with great nutritional utility to the body are considered higher quality than foods with low nutritional content.

Related Terms: food contamination, food culture, food restrictions, food safety, unsafe food

## គុណភាពស្បៀងអាហារ

១) - និយាយយោងទៅរកស្តង់ដារផ្នែកអនាម័យ និងសុវត្ថិភាពជាទូទៅរបស់អាហារមួយដែលបានកំណត់ ។ អាហារដែលមានស្តង់ដារគុណភាពខ្ពស់ គឺជាអាហារដែលពុំមានគំរាមកំហែងដល់សុខភាពរបស់មនុស្សឡើយ ។

២) - ក៏អាចនិយាយយោងទៅរកស្បៀងដែលផ្តល់តំលៃអាហារូបត្ថម្ភ វប្បធម៌ ឬសេដ្ឋកិច្ចកំរិតខ្ពស់ជាង ដោយគុណសម្បត្តិនៃរបៀប និងទីកន្លែងដែលស្បៀងត្រូវបានដាំដុះ ឬ ផលិត ។

៣) - នៅក្នុងបរិបទអាហារូបត្ថម្ភ ចំណីអាហារដែលមានយ៉ាងធំធេង ចំពោះរាងកាយត្រូវបានគេចាត់ទុកថាមានគុណភាពខ្ពស់ជាងចំណីអាហារដែលមានចំណុះអាហារូបត្ថម្ភទាប ។

ពាក្យដែលទាក់ទងគ្នា : ភាពកខ្វក់នៃចំណីអាហារ ផលិតកម្ម ស្បៀង ការដាក់កំរិតចំណីអាហារ សុវត្ថិភាពស្បៀង ស្បៀងអាហារដែលមិនមានសុវត្ថិភាព ។

*NOTES...*

# FOOD RESTRICTION

Any limits placed on the sale or consumption of foods for any reason.  Rationale for such restrictions may be based on trade, public health or cultural concerns.

Related Terms:  food taboos

## ការដាក់កំរិតចំណីអាហារ

ការកំហិតណាមួយដែលដាក់ទៅលើការលក់ ឬការបរិភោគស្បៀងដោយហេតុផលណាមួយ ។ សន្និទានភាពចំពោះការដាក់កំហិតទៅលើចំណីអាហារបែបនេះ អាចនឹងផ្អែកទៅលើការបារម្ភពីផ្នែកជួញដូរសុខភាពសាធារណៈ ឬ វប្បធម៌ ប្រពៃណី ។

ពាក្យដែលទាក់ទងគ្នា :   តំណម/ការតមចំណីអាហារ ។

*NOTES...*

# FOOD SAFETY

All measures taken during food production, processing, transport and handling, cooking, consumption and disposal which limit the risks of food borne illness.  In food security contexts, food safety and food security are seen as separate and distinct topics, and care should be taken not to use the terms interchangeably.

Related Terms:  Food Contamination, Food Security, Food Quality, Food Restrictions

## សុវត្ថិភាពស្បៀងអាហារ

វង្វាស់ទាំងអស់ដែលត្រូវធ្វើក្នុងអំឡុងពេលផលិតកម្មស្បៀង កែច្នៃ ដឹកជញ្ជូន និងកាន់ប៉ះ ចំអិន បរិភោគ និង បញ្ចេញចោលដែលកំហិតចំពោះគ្រោះថ្នាក់ប្រឈមទៅនឹងការកើតជំងឺដែលបណ្តាលមកពីចំណីអាហារ ។ នៅក្នុង

បរិបទសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងសន្តិសុខស្បៀង ត្រូវបានគេចាត់ទុកថាជាប្រធានបទដាច់ដោយ ឡែក និងញែកខុសពីគ្នា ហើយគេគួរតែប្រុងប្រយ័ត្ន មិនត្រូវប្រើប្រាស់ពាក្យនេះ ជំនួសឱ្យគ្នាទៅវិញទៅមក ឡើយ ។

ពាក្យដែលទាក់ទងគ្នា :   ភាពកខ្វក់នៃចំណីអាហារ  សន្តិសុខស្បៀង  គុណភាពស្បៀង   ការដាក់កំរិតចំណី អាហារ ។

*NOTES...*

# FOOD SECURITY

A situation that exists when all people, at all times, have physical, social and economic access to sufficient, safe and nutritious food that meets their dietary needs and food preferences for an active and healthy life"(SOFI, 2001). However, direct measurement of food security is complex and problematic. Food security is most frequently based upon the absence of food insecurity.

Related Terms: access, availability, food insecurity, stability, utilization, food and nutrition security, nutrition security

## សន្តិសុខស្បៀង

ស្ថានភាពដែលកើតមាននៅពេលដែលប្រជាជនគ្រប់រូប គ្រប់ពេលវេលាមានលទ្ធភាពទទួលបានស្បៀងគ្រប់គ្រាន់ មានសុវត្ថិភាព និងមានសារជាតិចិញ្ចឹមតាមផ្នែករូបវន្តសង្គម សេដ្ឋកិច្ច ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការរបបអាហាររបស់ពួកគេ និងបរិភោគតាមចំណង់ចំណូលចិត្ត ដើម្បីមានជីវិតមួយដែលសកម្ម និងមានសុខភាពល្អ（SOFI, 2001） ។ ទោះជាយ៉ាងណាក៏ដោយ រង្វាស់ដោយផ្ទាល់ទៅលើសន្តិសុខស្បៀង គឺមានភាពស្មុគ្រស្មាញ និងមានបញ្ហា ។ សន្តិសុខស្បៀងជាញឹកញាប់បំផុត គឺផ្អែកទៅលើការគ្មានអសន្តិសុខស្បៀង ។

ពាក្យដែលទាក់ទងគ្នា ៖ លទ្ធភាពទទួលបាន លទ្ធភាពមាន/ភាពមាន អសន្តិសុខស្បៀង ស្ថេរភាព ការបឺតស្រូប សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ) ។

*NOTES...*

# FOOD STOCK

All foods held in reserve at the household, community, regional, or national level. An important component of food balance sheet calculations.

Related Terms: food balance sheet, food production

## ការស្តុកស្បៀង

អាហារទាំងអស់ដែលទុកបំរុងនៅតាមថ្នាក់គ្រួសារ សហគមន៍ តំបន់ ឬ ជាតិ ។ សមាសភាគនៃតារាងតុល្យភាពស្បៀងដ៏សំខាន់ក្នុងការគណនា ។

ពាក្យដែលទាក់ទងគ្នា ៖ តារាងតុល្យភាពស្បៀង ផលិតកម្មស្បៀង ។

*NOTES...*

# FOOD SUPPLEMENTATION

Also known as food fortification, refers to the practice of increasing the nutritional load of a food by adding of micronutrients (minerals and vitamins), amino acids, enzymes and/or other nutrients.  Iodized salt is the most common example.

Related Terms:  malnutrition, micronutrients, micronutrient deficiencies, food quality.

## ការផ្តល់បន្ថែមស្បៀងអាហារ

ក៏ត្រូវបានគេដឹងផងដែរថាជាការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ គឺសំដៅដល់ការអនុវត្តន៍ក្នុងការបង្កើនបន្ទុកអាហារូបត្ថម្ភនៃចំណីអាហារ ដោយបន្ថែមនូវពពួកមីក្រូសារជាតិផ្សេងៗ (រ៉ែខនិជ និងវីតាមីន) អាមីណូអាស៊ីត អង់ស៊ីម និង/ឬសារជាតិចិញ្ចឹមផ្សេងៗទៀត ។ អំបិលអ៊ីយ៉ូដគឺជាគំរូឧទាហរណ៍មួយសាមញ្ញបំផុត។

ពាក្យដែលទាក់ទងគ្នា :  កង្វះអាហារូបត្ថម្ភ  មីក្រូសារជាតិ  បញ្ហាកង្វះមីក្រូសារជាតិ  គុណភាពស្បៀង។

*NOTES...*

# FOOD TABOO

Religious, cultural, or hygienic restrictions against handling or eating particular foods.

Related Terms: food culture, food restrictions

## ការតម/តំណមអាហារ

ការតមតាមបែបសាសនា ប្រពៃណី ឬក៏អនាម័យប្រឆាំងទៅនឹងការកាន់ វាល់ ឬក៏បរិភោគស្បៀងជាក់លាក់ពិសេសណាមួយ ។

ពាក្យដែលទាក់ទងគ្នា : ផលិតកម្មស្បៀង ការដាក់ក៏រិតចំណីអាហារ ។

*NOTES...*

# FOOD UTILIZATION

1. A household's use of the food to which they have access.  Includes all food handling, preparation and consumption methods, hygiene and sanitation, and waste disposal.  It includes how food is distributed within a household.

2. Individuals' ability to absorb and metabolize the nutrients – the conversion efficiency of food by the body.  This often depends on the health of the individual.

Related Terms:  utilization

## ការបឺតស្រូបស្បៀង/អាហារ

១) ការប្រើប្រាស់ស្បៀងរបស់គ្រួសារដែលពួកគេមានលទ្ធភាពអាចទទួលស្បៀងបាន គឺរាប់បញ្ចូលទាំងស្បៀងទាំងអស់ដែលកាន់ រៀបចំ និងវិធីបរិភោគ អនាម័យរាងកាយ និងអនាម័យលំនៅស្ថានបរិស្ថាន និងការបញ្ចេញចោលកាកសំណល់ ។ វាក៏រាប់បញ្ចូលផងដែរអំពីរបៀបដែលស្បៀងត្រូវធ្វើការបែងចែកនៅក្នុងគ្រួសារមួយ ។
២) លទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការបឺតស្រូប និងធ្វើមេតាបូលីសសារជាតិចិញ្ចឹម សក្តិសិទ្ធភាពក្នុងការបំលែងស្បៀងដោយរាងកាយ ។ ចំនុចនេះជារឿយៗតែងតែត្រូវពឹងផ្អែករបស់បុគ្គលផ្ទាល់ ។

ពាក្យដែលទាក់ទងគ្នា :  ការបឺតស្រូប ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# FORECAST ANALYSIS

A forward looking assessment, based on available data, which contains predictions of future opportunities and shocks, and the ways in which a situation is likely to evolve.

Related Terms: indicators, situation analysis

## ការវិភាគលើការព្យាករណ៍

ការវាយតំលៃដោយសំលឹងមើលទៅខាងមុខ ដោយផ្អែកទៅលើទិន្នន័យដែលមាន ឬ អាចរកបាន ដែលទិន្នន័យមានការព្យាករណ៍អំពីឱកាសនាពេលអនាគត និងព្រឹត្តការណ៍តក់ស្លុត ដែលនៅក្នុងនោះស្ថានការណ៍ទំនងជាវិវត្តន៏ទៅរក។

ពាក្យដែលទាក់ទងគ្នា : សូចនាករ ការវិភាគពីស្ថានភាព។

*NOTES...*

# GINI COEFFICIENT

The Gini coefficient is a measure of the inequality of distribution, used to determine differences in income across society.  The coefficient ranges from 0 (perfect equality) to 1 (perfect inequality).

Related Terms:  dietary energy consumption, income inequality

## មេគុណតាមបែបហ្គីនី

មេគុណតាមបែបហ្គីនី គឺជាការវាស់វែងពីរបាយដែលពុំស្មើភាពគ្នា ដោយត្រូវបានគេប្រើដើម្បីកំណត់ពីភាពផ្សេងៗ/ខុសៗ គ្នានៃប្រាក់ចំណូលនៅទូទាំងសង្គម ។ មេគុណនេះ មានលំដាប់ពីលេខ 0 ( ស្មើភាពគ្នាឥតខ្ចោះ ) ទៅលេខ ១ ( ពុំស្មើភាព គ្នាទាល់តែសោះ/គំលាតឥតខ្ចោះ) ។

ពាក្យដែលទាក់ទងគ្នា :  ការបរិភោគរបបអាហារដែលសំបូរថាមពល   គំលាតនៃប្រាក់ចំណូល ។

*NOTES...*

# HOUSEHOLD FOOD CONSUMPTION EXPENDITURE

The total household spending on food consumed by all members during a specified period. This includes food that is consumed at home and outside the home, e.g. at restaurants, bars, work place, school, etc. It includes food from all sources, purchased or from garden or farm.

Related Terms: household consumption expenditure, household expenditure, household income

## ការចំណាយទៅលើការប្រើប្រាស់ស្បៀងអាហារនៅក្នុងគ្រួសារ

ការចំណាយជាសរុបនៅក្នុងគ្រួសារទៅលើស្បៀងអាហារដែលបានប្រើប្រាស់ ឬបរិភោគ ដោយសមាជិកនៅក្នុងគ្រួសារទាំងអស់គ្នានៅក្នុងអំឡុងរយៈពេលមួយដែលគេបានបញ្ជាក់យ៉ាងជាក់ច្បាស់លាស់ ។ ចំណាយនេះគឺរាប់បញ្ចូលទាំងចំណីអាហារដែលត្រូវបានបរិភោគនៅឯផ្ទះ និងទាំងនៅក្រៅផ្ទះផងដែរ ឧទាហរណ៍ នៅឯភោជនីយ-ដ្ឋាន នៅបារ នៅកន្លែងធ្វើការ នៅសាលារៀន,,, ។ល ។ រាប់បញ្ចូលទាំង ស្បៀងអាហារដែលបានមកពីគ្រប់ប្រភពទាំងអស់ ទិញ ឬក៏បេះពីសួន ដំណាំ ឬពីកសិដ្ឋាន ។

ពាក្យដែលទាក់ទងគ្នា ៖ ការចំណាយទៅលើការប្រើប្រាស់ ឬ បរិភោគ (ស្បៀងអាហារនៅក្នុងគ្រួសារ) ការចំណាយ នៅក្នុងគ្រួសារ ចំណូលនៅក្នុងគ្រួសារ ។

*NOTES...*

# HOUSEHOLD EXPENDITURE

Consumption plus non-consumption expenditure made by the household, including food. It is the total amount of money spent by a household in a specified period.

Related Terms: household consumption expenditure, household food consumption expenditure, household income

## ការចំណាយនៅក្នុងគ្រួសារ

ការចំណាយទៅលើការប្រើប្រាស់ ឬបរិភោគ (ស្បៀងអាហារ) នៅក្នុងគ្រួសារ បូកជាមួយនឹងការចំណាយដែលមិនចាយវាយទៅលើការប្រើប្រាស់ ឬបរិភោគ (ស្បៀងអាហារ) នៅក្នុងគ្រួសារដែលចាយវាយដោយគ្រួសាររួមទាំងស្បៀងអាហារផងដែរ ។ វាគឺជាបរិមាណសរុបនៃទឹកប្រាក់ដែលចាយវាយដោយគ្រួសារមួយនៅក្នុងរយៈពេលមួយ ដែលគេបានបញ្ជាក់យ៉ាងជាក់ច្បាស់ ។

ពាក្យដែលទាក់ទងគ្នា : ការចំណាយទៅលើការប្រើប្រាស់នៅក្នុងគ្រួសារ ការចំណាយទៅលើការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារនៅក្នុងគ្រួសារ ចំណូលនៅក្នុងគ្រួសារ ។

*NOTES...*

A B C D E F G **H** I J K L M N O P Q R S T U V W X Y Z

# HOUSEHOLD INCOME

Income is the sum of all receipts, in money or in kind, which as a rule are received regularly and are of
recurring nature, including food.  Income may be earned or unearned.

Related Terms:  household consumption expenditure, household food consumption expenditure, household expenditure.

## ចំណូលនៅក្នុងគ្រួសារ

គឺជាចំនួនបូកសរុបនៃអ្វីៗទាំងអស់ដែលយើងទទួលបានជាប្រាក់ ឬជារបស់របរដែលជាគោលការណ៍ គឺបានទទួលជាទៀងទាត់ ហើយនិងមានចរិកលក្ខណៈវិលជុំម្តងហើយម្តងទៀតៗ  រួមទាំងស្បៀងអាហារផងដែរ ។ ចំណូលអាចបានមកពីការប្រឹងរក ឬបានមកពីការមិនចាំបាច់ប្រឹងរក ( បានមកដោយឯកឯង) ។

ពាក្យដែលទាក់ទងគ្នា :  ការចំណាយទៅលើការប្រើប្រាស់នៅក្នុងគ្រួសារ  ការចំណាយទៅលើការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារនៅក្នុងគ្រួសារ  ការចំណាយនៅក្នុងគ្រួសារ ។

*NOTES...*

# HOUSEHOLD INCOME AND EXPENDITURE SURVEY

Any assessment process which collects information on household incomes and expenditure as outlined above.  Can be conducted at the household, community, provincial, regional or national level.

Related Terms:  household consumption expenditure, household food consumption expenditure, household income, household expenditure.

## ការអង្កេតលើចំណាយ និងចំណូលនៅក្នុងគ្រួសារ

គឺជាដំណើរការណាមួយនៃការចុះធ្វើការវាយតម្លៃ ដែលត្រូវធ្វើការប្រមូលព័ត៌មាន ស្តីពីចំណាយនិងចំណូលនៅក្នុងគ្រួសារ ដូចដែលបានបង្ហាញដោយត្រួសៗនៅខាងលើ។ ការអង្កេតវាយតម្លៃនេះ គេអាចធ្វើបាននៅតាមថ្នាក់គ្រួសារ  សហគមន៏  ខេត្ត  តំបន់ ឬថ្នាក់ជាតិ។

ពាក្យដែលទាក់ទងគ្នា :  ការចំណាយទៅលើការប្រើប្រាស់នៅក្នុងគ្រួសារ   ការចំណាយទៅលើការប្រើប្រាស់ស្បៀង/ បរិភោគចំណីអាហារនៅក្នុងគ្រួសារ  ចំណូលនៅក្នុងគ្រួសារ ការចំណាយនៅក្នុងគ្រួសារ។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# HOUSEHOLD FOOD INSECURITY

A household's inability to meet all of the food needs of all of its members at all times.

Related Terms:  household food security.

## អសន្តិសុខស្បៀងកំរិតគ្រួសារ

ការពុំមានលទ្ធភាពទទួលការផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់របស់គ្រួសារ ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការស្បៀងរបស់សមាជិកទាំងអស់នៅក្នុងគ្រួសារទាំងអស់សំរាប់រយៈពេលពេញមួយឆ្នាំ ។

ពាក្យដែលទាក់ទងគ្នា :  សន្តិសុខស្បៀងកំរិតគ្រួសារ ។

*NOTES...*

# HOUSEHOLD FOOD SECURITY

Year-round access to an adequate supply of nutritious and safe food to meet the needs of all household members.

Related Terms:  household food insecurity.

## សន្តិសុខស្បៀងកំរិតគ្រួសារ

លទ្ធភាពទទួលការផ្គត់ផ្គង់ស្បៀងប្រកបដោយសារជាតិចិញ្ចឹម និងមានសុវត្ថិភាពបានគ្រប់គ្រាន់សំរាប់រយៈពេលពេញមួយឆ្នាំ ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការរបស់សមាជិកនៅក្នុងគ្រួសារទាំងអស់ ។

ពាក្យដែលទាក់ទងគ្នា :  អសន្តិសុខស្បៀងកំរិតគ្រួសារ ។

*NOTES...*

A B C D E F G **H** I J K L M N O P Q R S T U V W X Y Z

# HUNGER

Nutritionists have estimated the amount of dietary energy that people of different ages and sex with different activity levels in different cultures require to maintain a healthy and active life. When people do not have access to the amount of dietary energy needed for their normal level of activity, they feel hungry. If the situation persists over a longer time, it leads to undernutrition. Chronic energy deficiency can lead to a reduction in physical activity, weight loss or both. In severe forms, chronic energy deficiency can lead to wasting and eventually death. Hunger is not synonymous with malnutrition or undernutrition, but there are overlaps between these two. (CFS 2012)

Related Terms: food deprivation, food and nutrition security, food security, food insecurity.

## ភាពស្រេកឃ្លាន/អត់ឃ្លាន

អ្នកជំនាញអាហារូបត្ថម្ភបានធ្វើការប៉ាន់ស្មានពីបរិមាណថាមពល ក្នុងរបបអាហារដែលប្រជាជនមានអាយុ និងភេទផ្សេងៗគ្នា ដោយមានកិរិតសកម្មភាពផ្សេងៗគ្នា វប្បធម៌ខុសៗគ្នា (បរិមាណថាមពលក្នុងរបបអាហារ) ដែលតំរូវឱ្យមាន ដើម្បីមានជីវិតមួយដ៏សកម្ម និងប្រកបដោយសុខភាពល្អ ។ នៅពេលណាដែលប្រជាជនទាំងនោះពុំមានលទ្ធភាពទទួលបានបរិមាណថាមពលក្នុងរបបអាហារ ដែលត្រូវការចាំបាច់សំរាប់ធ្វើសកម្មភាពក្នុងកិរិតធម្មតារបស់ខ្លួនទេ នោះគឺពួកគេនឹងមានអារម្មណ៏ស្រេកឃ្លាន ។ បើសិនជាស្ថានភាពនេះនៅតែបន្តក្នុងរយៈពេលមួយយូរទៅៗនោះវានឹងបណ្តាលឱ្យកើតមានបញ្ហាកង្វះអាហារូបត្ថម្ភ ។ កង្វះថាមពលរ៉ាំរ៉ៃអាចបណ្តាលឱ្យកើតមានការកាត់បន្ថយនូវសកម្មភាពរបស់រាងកាយស្រេក ទម្ងន់ខ្លួន ឬក៏កើតមានបញ្ហាទាំងពីរតែម្តង ។ នៅក្នុងទម្រង់ធ្ងន់ធ្ងរកង្វះថាមពលរ៉ាំរ៉ៃអាចបណ្តាលឱ្យបុគ្គលនោះ កើតមានភាពស្គមស្គាំង ហើយជាយថាហេតុអាចបណ្តាលឱ្យស្លាប់បាន ។ ភាពស្រេកឃ្លាន/អត់ឃ្លាន គឺពុំមែនជាពាក្យវេវចនៈស័ព្ទ (ន័យដូច) ជាមួយនឹងពាក្យកង្វះអាហារូបត្ថម្ភ ឬអាហារូបត្ថម្ភខ្សត់ខ្សោយនោះទេ ក៏ប៉ុន្តែវាន័យជាន់គ្នារវាងពាក្យទាំងពីរនេះ ។ (CFS 2012)

ពាក្យដែលទាក់ទងគ្នា : ការបង្អត់អាហារ/ភាពខ្វះខាតចំណីអាហារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សន្តិសុខស្បៀង អសន្តិសុខស្បៀង ។

*NOTES...*

# HYGIENE

Any and all practices related to limiting the spread of disease from any source. In a food security context, this is especially pertinent to food handling, preparation, consumption and disposal practices. It is also interlinked with issues around personal hygiene (i.e. hand washing), public health and disease prevalence.
Related Terms: food safety, hygiene education, sanitation, utilization

## អនាម័យ

ការអនុវត្តន៍ណាមួយ ឬការប្រតិបត្តិទាំងអស់ដែលទាក់ទងទៅនឹងការដាក់កំរិត ការសាយភាយនូវជម្ងឺពីប្រភពណាមួយ ។ នៅក្នុងបរិបទសន្តិសុខស្បៀងនេះគឺជាទំនាក់ទំនងជាពិសេសទៅនឹងការ ចាប់កាន់ចំណីអាហារ ការរៀបចំចំណីអាហារ ការបរិភោគចំណីអាហារ និងការប្រតិបត្តិផ្នែកការបញ្ចេញចោលនូវកាកសំណល់ ។ វាក៏មានទំនាក់ទំនងរវាងគ្នាទៅវិញ ទៅមកផងដែរ ជាមួយនឹងបញ្ហាជុំវិញអនាម័យនៃរាងកាយ ( ឧទាហរណ៍ៈ ការលាងដៃ) អត្រាប្រេវ៉ាឡង់នៃបញ្ហា សុខភាពសាធារណៈ និងអត្រាប្រេវ៉ាឡង់នៃជម្ងឺ ។

ពាក្យដែលទាក់ទងគ្នា ៖ សុវត្ថិភាពស្បៀង/ចំណីអាហារ ការអប់រំអំពីអនាម័យទូទៅ អនាម័យ ( លំនៅដ្ឋាន/បរិស្ថាន) ការបឺតស្រូប ។

*NOTES...*

A B C D E F G H **I** J K L M N O P Q R S T U V W X Y Z

# INCOME ELASTICITY OF FOOD DEMAND

The income elasticity of food demand measures the responsiveness of the amount of food demanded to a unit change of income. Simply put, this measures what happens when a unit of food becomes more (or less) expensive. Income elasticity can be measured in terms of quantity, money or nutrients.

Related Terms: access, food access gap, food poverty line, household consumption expenditure, household food consumption expenditure

## ទំនាក់ទំនងបំរែបំរួលចំណូលទៅនឹងតំរូវការស្បៀងអាហារ (ចំណូលមានការប្រែប្រួលទៅនឹងតំរូវការស្បៀងអាហារ)

ទំនាក់ទំនងបំរែបំរួលចំណូលទៅនឹងតំរូវការស្បៀងអាហារ វាស់វែងពីការឆ្លើយតបទៅនឹងបរិមាណនៃស្បៀងអាហារ ដែលតំរូវទៅនឹងការប្រែប្រួលឯកតានៃចំណូល ។ គឺងាយណាស់ដោយគ្រាន់តែដាក់ធម្មតាៗនូវរង្វាស់នេះទៅ នោះវានឹងវាស់ពីអ្វីដែលបានកើតឡើងនៅពេលដែលឯកតាមួយនៃស្បៀងបានកើនតំលៃខ្លាំងពេក (ឬ មិនសូវថ្លៃពេក) ។ ទំនាក់ទំនងបំរែបំរួលចំណូល គេអាចធ្វើការវាស់វែងបានក្នុងលក្ខខណ្ឌជាបរិមាណ ទឹកប្រាក់ ឬ ជាសារជាតិចិញ្ចឹម ។

ពាក្យដែលទាក់ទងគ្នា : លទ្ធភាពទទួលបាន គំលាតក្នុងការទទួលបានស្បៀង បន្ទាត់ភាពក្រីក្រស្បៀង ការចំណាយ ទៅលើការប្រើប្រាស់នៅក្នុងគ្រួសារ ការចំណាយទៅលើការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារនៅក្នុងគ្រួសារ ។

*NOTES...*

# INCOME INEQUALITY

Refers to differences in the distribution of income across a population.

Related Terms: Gini coefficient

## គំលាតនៃប្រាក់ចំណូល

គឺចង់និយាយសំដៅដល់ភាពផ្សេងៗគ្នានៃរបាយចំណូល នៅទូទាំងប្រជាជនទាំងអស់ ។

ពាក្យដែលទាក់ទងគ្នា :  មេគុណហ្គីនី ។

*NOTES...*

# INDICATORS

A specific variable, or combination of variables, that gives insight into a particular aspect of the situation. A value that can be used to evaluate or assess different types of impact.

Related Terms: information needs, primary indicator, proxy indicator, qualitative, quantitative

## សូចនាករ

តំលៃអថេរ (a variable) ឬការរួមផ្សំគ្នានៃតំលៃអថេរ ដែលផ្តល់នូវការយល់ធ្លុះជ្រៅទៅក្នុងទិដ្ឋភាពនៃស្ថានភាពមួយជាក់លាក់ពិសេស ។ គឺជាតំលៃមួយដែលគេអាចប្រើប្រាស់បានសម្រាប់ ធ្វើការវាយតំលៃ ឬក៏ធ្វើការប៉ាន់ស្មានពីប្រភេទ ផ្សេងៗគ្នានៃផលប៉ះពាល់ (ឥទ្ធិពល) ។

ពាក្យដែលទាក់ទងគ្នា : តំរូវការព័ត៌មាន សូចនាករដំបូង សូចនាករតំណាង តាមបែបគុណភាព តាមបែបបរិមាណ ។

*NOTES...*

# INFORMATION NEEDS

Information needs are usually a function of the requirements of the participants in the assessment process. Most commonly, needs are based on a critical review, often collaborative with many stakeholders involved, which determines those specific data that an assessment or survey sets out to address.

Related Terms: indicators, initial assessment, rapid assessment, risk assessment, secondary data, situation analysis

## តំរូវការព័ត៌មាន

តំរូវការព័ត៌មាន តាមធម្មតាគឺជាដំណើរការនៃការតំរូវរបស់អ្នកចូលរួមនៅក្នុងដំណើរការនៃការចុះធ្វើការវាយតំលៃ ប៉ាន់ស្មាន។ ជាទូទៅបំផុតតំរូវការ គឺផ្អែកទៅលើការពិនិត្យមើលឡើងវិញយ៉ាងដិតដល់បំផុត ហើយជារឿយៗ គឺត្រូវមានការសហការជាមួយនឹងអ្នកពាក់ព័ន្ធដែលត្រូវចូលរួមច្រើនផ្សេងទៀត ដែលនឹងកំណត់ពីទិន្នន័យជាក់លាក់ទាំងអស់នោះ ដែលការវាយតំលៃប៉ាន់ស្មាន ឬក៏ការអង្កេតបានដាក់កំណត់ចេញដើម្បីធ្វើការដោះស្រាយ ។

ពាក្យដែលទាក់ទងគ្នា ៖ សូចនាករ ការវាយតំលៃជំហានដំបូង ការវាយតំលៃរហ័ស ការវាយតំលៃហានិភ័យ ទិន្នន័យ ដែលអាចរកបាន ឬមានស្រាប់ ការវិភាគពីស្ថានភាព។

*NOTES...*

# INITIAL ASSESSMENT

An initial assessment is undertaken following: (i) a sudden crisis; (ii) reports of deterioration in a long-term crisis; or (iii) improved physical access to an area experiencing an ongoing crisis. The primary purpose of an initial assessment is to provide critical information for the formulation of emergency assistance plans, funding appeals and the design of more detailed follow-up assessments. All aspects of an initial assessment– from fieldwork to production of the final report – should be completed within six to ten days.

Related Terms: emergency, information needs, rapid assessment, situation analysis

## ការវាយតំលៃជំហានដំបូង

ការវាយតំលៃជំហានដំបូងត្រូវបានដឹកនាំធ្វើឡើងបន្ទាប់ពីមានៈ (១) វិបត្តិបន្ទាន់ភ្លាមៗ (២) របាយការណ៏ថា វិបត្តិនេះកាន់តែមានសភាពដុនដាបយ៉ាប់ទៅៗ រយៈពេលយូរអង្វែង ឬ (៣) ភាពល្អប្រសើរឡើងនូវលទ្ធភាពផ្នែករូបវ័ន្ត ក្នុងការចូលដល់តំបន់ដែលកំពុងតែឆ្លងកាត់វិបត្តិ ដែលកំពុងតែកើតមានជាបន្ត។ គោលបំណងបឋមនៃការវាយតំលៃជំហានដំបូង គឺដើម្បីផ្តល់នូវព័តិមានសំខាន់ៗបំផុតសម្រាប់ធ្វើការរៀបចំឱ្យបានជាក់លាក់នូវផែនការចុះជួយសង្គ្រោះស្ថានភាពបន្ទាន់ ការអំពាវនាវរកជំនួយថវិកា និងការរចនាថ្មៃការចុះវាយតំលៃជាបន្តឱ្យបានកាន់តែលំអិតថែមទៀត។ គ្រប់ទិដ្ឋភាពទាំងអស់នៃការចុះធ្វើការវាយតំលៃជំហានដំបូងពីការចុះតាមភូមិរហូតដល់ការផលិតរបាយការណ៏ជាបញ្ចប់ត្រូវតែ បំពេញឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ពី ៦ ទៅ១០ថ្ងៃ ។

ពាក្យដែលទាក់ទងគ្នា ៈ ស្ថានភាពបន្ទាន តំរូវការព័តិមាន ការវាយតំលៃរហ័ស ការវិភាគពីស្ថានភាព។

*NOTES...*

# INTEGRATED FOOD CHAIN APPROACH

An approach to food production which considered each and every link in the process of food reaching the consumer - from the way it is grown or raised, to how it is collected, processed, packaged, sold and consumed.  Stakeholders include input suppliers, farmers, food processors, transport operators, distributors (both retail and wholesale) and consumers, as well as governments obliged to protect public health.

Although it is often used in the context of hygiene and food safety benefits, food chain approaches may also improve economies of scale, support better horizontal or vertical integration along supply lines, and improve marketing and logistics of food produced.

Related Terms:  agricultural productivity, consumer, food safety, hygiene

## សមាហរណកម្មយុទ្ធវិធីខ្សែសង្វាក់ស្បៀង

ជាយុទ្ធវិធីមួយ សម្រាប់ផលិតកម្មស្បៀងដែលត្រូវធ្វើការពិនិត្យពិចារណាពីទំនាក់ទំនងនីមួយៗ ឬ គ្រប់ទំនាក់ទំនងទាំងអស់ទៅនឹងដំណើរការផលិតស្បៀងដែលនឹងធ្លាក់ទៅដល់ដៃអ្នកប្រើប្រាស់/អ្នកបរិភោគចាប់ពីរបៀបដែលស្បៀងត្រូវបានដាំដុះ ឬចិញ្ចឹម រហូតទៅដល់របៀបដែលស្បៀត្រូវបានគេធ្វើការប្រមូលផលទុកដាក់ កែឆ្នៃវេចខ្ចប់ ចេញលក់ និងប្រើប្រាស់/បរិភោគ ។ អ្នកពាក់ព័ន្ធរួមមានអ្នកផ្គត់ផ្គង់ ផ្នែកធាតុចូល កសិករ អ្នកកែឆ្នៃ

ស្បៀង អ្នកដឹកជញ្ជូន អ្នកចែកចាយ (រួមទាំងអ្នកលក់ដុំ និងអ្នកលក់រាយ) និង អ្នកប្រើប្រាស់/អ្នកបរិភោគ ព្រមទាំង រដ្ឋាភិបាលទាំងអស់ដែលមានកតព្វកិច្ចត្រូវការពារសុខភាពសាធារណៈ ។ តែទោះជាយ៉ាងណាក៏ដោយ ជារឿយៗវាត្រូវបានគេប្រើនៅក្នុងបរិបទនៃផលប្រយោជន៍ផ្នែកអនាម័យ និងសុវត្ថិភាពស្បៀង យុទ្ធវិធីខ្សែសង្វាក់ស្បៀង ក៏អាចធ្វើឱ្យប្រសើរឡើងនូវមាត្រដ្ឋានសេដ្ឋកិច្ច គាំទ្រដល់ការធ្វើសមាហរណកម្មទៅតាមខ្សែបន្ទាត់ផ្គត់ផ្គង់ តាមខ្សែបណ្តោយ និងខ្សែទទឹងបានកាន់តែល្អប្រសើរ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារ និងភ័ស្តុភារនៃស្បៀងដែលបានផលិត ។

ពាក្យដែលទាក់ទងគ្នា :  ផលិតភាពកសិកម្ម  អ្នកប្រើប្រាស់/អ្នកបរិភោគ  សុវត្ថិភាពស្បៀង  អនាម័យ ។

*NOTES...*

# KILOCALORIE (KCAL)

In scientific terms, refers to the amount of energy required to raise the temperature of one kilogram of water by one degree Celsius.  In food terms, refers to the dietary energy contained within a particular food.  For example, non-glutinous rice contains 360 Kcal per 100 grams.  As a general rule, adults require 2,100 Kcal per day in order to have the energy required for a sedentary lifestyle: more physically active livelihoods require higher Kcal intake.

Related Terms:  food consumption, indicators, malnutrition, nutrition security

## គីឡូកាឡូរី

ជាពាក្យផ្នែកវិទ្យាសាស្ត្រ គឺចង់និយាយសំដៅដល់បរិមាណនៃថាមពលដែលតំរូវឱ្យមានដើម្បីបង្កើននូវសីតុណ្ហ-ភាពក្នុងកិរិតទឹកមួយគីឡូក្រាមដោយមួយដឺក្រេសេ ។ ជាពាក្យប្រើក្នុងស្បៀង គឺចង់និយាយសំដៅដល់របបអាហារថាមពលដែលមាននៅក្នុងចំណីអាហារជាក់លាក់ពិសេស ។ ជាឧទាហរណ៍ អង្ករដំណើបមាន ៣៦០គីឡូកាឡូរី/១០០ក្រាម ។ ជាគោលការណ៍ទូទៅ មនុស្សពេញវ័យត្រូវការថាមពលកំរិត ២១០០គីឡូកាឡូរី/១ថ្ងៃ ដើម្បីនឹងមានថាមពលសម្រាប់ជីវិត រស់នៅ: ជីវិតរស់នៅសកម្មដោយប្រើប្រាស់កំលាំងកាយច្រើន តំរូវឱ្យមានការបរិភោគថាមពលជាគីឡូកាឡូរីកាន់តែ ខ្ពស់ច្រើនជាងមុន ។

ពាក្យដែលទាក់ទងគ្នា :  ការប្រើប្រាស់ស្បៀង/ការបរិភោគចំណីអាហារ  សូចនាករ  កង្វះអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ ។

*NOTES...*

# KITCHEN GARDENS

Refers to any small-scale agriculture conducted within proximate distance to the main dwelling of a household, producing crops for own consumption or sale. It is an indication the scale of cultivation, not the specific crops being grown. Also known as kitchen gardens.

Related Terms: agriculture, agricultural households

## សួនដំណាំគ្រួសារ

គឺចង់និយាយសំដៅទៅដល់កសិកម្មខ្នាតតូចណាមួយ ដែលធ្វើឡើងនៅក្នុងចំងាយជិតៗទៅនឹងលំនៅស្ថានរបស់គ្រួសារមួយ ដោយផលិតនូវដំណាំសំរាប់បរិភោគខ្លួនឯងផ្ទាល់ ឬទុកសំរាប់លក់ ។ វាគឺជាសញ្ញាបង្ហាញឱ្យដឹងអំពីកំរិតនៃការដាំដុះ មិនមែនបង្ហាញអំពីដំណាំជាក់លាក់ដែលកំពុងតែ ដាំដុះនោះទេ។ ក៏ដូចគ្នានេះដែរវាត្រូវបានគេដឹងថា ជាសួនដំណាំគ្រួសារ ។

ពាក្យដែលទាក់ទងគ្នា : កសិកម្ម គ្រួសារកសិករ ។

*NOTES...*



A B C D E F G H I J K L M N O P Q R S T U V W X Y Z

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# LEAN SEASON

A period during the calendar or agricultural year when food is in short supply, and as such is consumed in smaller quantities and/or with less frequency.  Most commonly occurs at the period just prior to the harvest, when food reserves are low and access is impeded by the rainy season.

Related Terms:  availability, access, consumption, chronic food insecurity, risk analysis, transitory (or seasonal) food insecurity

## រដូវខ្សត់ស្បៀង (នៅពេលជិតប្រមូលផល)

រយៈពេលមួយនៅក្នុងឆ្នាំប្រតិទិន ឬក៏ឆ្នាំកសិកម្ម នៅពេលដែលស្បៀងមានការផ្គត់ផ្គង់ខ្វះខាត ហើយហេតុនេះវាត្រូវបានបរិភោគនៅក្នុងបរិមាណមួយ កាន់តែតិចជាងមុន និង/ឬក៏មានចំនួនដងនៃអាហារពេលកាន់តែតិចជាងមុន ។ ជាទូទៅ ភាគច្រើនវាបានកើត ឡើងនៅក្នុងរយៈពេលមុនពេលនៃការប្រមូលផលតែបន្តិចប៉ុណ្ណោះ ពេលដែលស្បៀងបំរុងធ្លាក់ចុះ ហើយលទ្ធភាពក្នុងការទទួលស្បៀង គឺមានការរារាំងដោយរដូវភ្លៀង ។

ពាក្យដែលទាក់ទងគ្នា :  លទ្ធភាពមាន/ភាពមាន  ភាព/លទ្ធភាពទទួលបាន   ការប្រើប្រាស់ស្បៀង/ការបរិភោគចំណីអាហារ  អសន្តិសុខស្បៀងរ៉ាំរ៉ៃ  ការវិភាគពីហានិភ័យ   អសន្តិសុខស្បៀងជាបណ្តោះអាស័ន្ន (ឬតាមរដូវ) ។

*NOTES...*

# LIVELIHOOD

The capabilities, assets (natural, human, physical, social and financial) and activities required for present-day survival and future well-being.

Related Terms:  access, livelihood groups, vulnerability, vulnerable groups, food economy

## ការចិញ្ចឹមជីវិត ឬជីវភាពរស់នៅ

សមត្ថភាព ធនធាន ( ធម្មជាតិ មនុស្ស រាងកាយ សង្គម និង ហិរញ្ញវត្ថុ) និងសកម្មភាពដែលតំរូវឱ្យមានដើម្បីការរស់រានមានជីវិតក្នុងមួយថ្ងៃៗ និងមានសុខុមាលភាពល្អទៅពេលអនាគត ។

ពាក្យដែលទាក់ទងគ្នា :  ភាព/លទ្ធភាពទទួលបាន  ការចិញ្ចឹមជីវិត  ភាពងាយរងគ្រោះ  ក្រុមជនដែលងាយរងគ្រោះ  សេដ្ឋកិច្ចស្បៀង។

*NOTES...*

# LIVELIHOOD GROUP

A group of people or households who share common livelihood systems and strategies, access similar resources, and share similar social and cultural practices. As a function of shared and common practice, livelihood groups are generally vulnerable to similar risks.  It is common to see more than one livelihood group in a specific geographical area.  Livelihood Groups may undertake more than one livelihood activity in the course of a year (i.e.  rice planting, casual labour, fishing, etc).

Related Terms:  access, livelihoods, vulnerability, vulnerable groups

## ក្រុមអ្នកមានមុខរបរ

ក្រុមប្រជាជន ឬគ្រួសារដែលចែករំលែកនូវយុទ្ធសាស្ត្រ និងប្រព័ន្ធនៃជីវភាពរស់នៅទូទៅរបស់ខ្លួន មានលទ្ធភាពប្រើប្រាស់ធនធានបានស្រដៀងៗគ្នា និងចែករំលែកនូវការអនុវត្តន៏ផ្នែកសង្គម និងវប្បធម៌ស្រដៀងៗគ្នា។ ដោយជាដំណើរការនៃការអនុវត្តន៏ជាទូទៅ និងមានលក្ខណៈចែករំលែកនោះ ក្រុមដែលមានមុខរបរចិញ្ចឹមជីវិតជាទូទៅគឺជាអ្នកដែលងាយនឹងរង គ្រោះទៅនឹងហានិភ័យស្រដៀងៗគ្នា។ គឺវាត្រូវបានគេឃើញជាទូទៅថា មានក្រុមដែលមានរបរចិញ្ចឹមជីវិតលើសពីមួយក្រុម នៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ។ ក្រុមដែលមានរបរចិញ្ចឹមជីវិតទាំងនោះ អាចមានសកម្មភាពប្រកបរបរ ចិញ្ចឹមជីវិតលើសពីមួយនៅក្នុងអំឡុងពេលមួយឆ្នាំ ( មានន័យថាពួកគាត់ដាំដុះស្រូវ លក់កំលាំងពលកម្ម ( ធ្វើជាកម្មករ អណ្តែត) នេសាទត្រី ។ល។) ។

ពាក្យដែលទាក់ទងគ្នា :  ភាព/លទ្ធភាពទទួលបាន  ការចិញ្ចឹមជីវិត  ភាពងាយរងគ្រោះ   ក្រុមជនដែលងាយរងគ្រោះ ។

*NOTES...*

# LIFESTYLE PRACTICES

Any set of behaviours, practices and activities shared by a given social group. In a food security context, usage tends to apply to behaviours which result in overweight, obesity, or increased incidence on Non-Communicable Diseases such as Type II diabetes, heart disease and cancer.  Also applicable in public health contexts, such as HIV/AIDS prevention.

Related Terms:  overweight, obesity

## ការប្រតិបត្តិអំពីរបៀបរបបរស់នៅ

ឥរិយាបថ និងការអនុវត្តន៍ និងសកម្មភាពណា មួយដែលរួមចំណែកដោយក្រុមសង្គមមួយដែលបានកំនត់ ។ នៅក្នុងបរិបទនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការប្រើប្រាស់ដែលមានទំនោរចង់អនុវត្តន៏ចំពោះឥរិយាបថដែលបណ្តាលឱ្យកើតមានការលើសទំងន់ ជំងឺធាត់ ឬ បង្កើតអាំងស៊ីដង់នៃជំងឺមិនឆ្លង ដូចជា ជំងឺទឹកនោមផ្អែមប្រភេទទី២ ជំងឺបេះដូង និងជំងឺមហារីក ។ ក៏ដូចគ្នានេះដែរ វាត្រូវបានគេអនុវត្តន៏នៅក្នុងបរិបទសុខភាពសាធារណៈ ដូចជាការការពារជំងឺអេដស៏ ។

ពាក្យដែលទាក់ទងគ្នា :  ការលើសទម្ងន់  ជម្ងឺធាត់ ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# MACRONUTRIENT

Critical nutrients required in substantial amounts for humans to maintain their physical and cognitive growth and development. Refers to carbohydrates, proteins and fats, and are measured in kilocalories or grams. Macronutrients alone are inadequate for a balanced diet, and are complemented by micronutrients, which are required in much smaller quantities. Shortages of macronutrients generally lead to hunger and undernourishment.

Related Terms: balanced diet, dietary energy requirement, micronutrients

## ម៉ាក្រូសារជាតិ

សារជាតិចិញ្ចឹមដ៏សំខាន់ជាអាយុជីវិត ត្រូវឱ្យមានក្នុងបរិមាណមួយក្រាស់ក្រែលសំរាប់មនុស្ស ដើម្បីថែរក្សានូវការអភិវឌ្ឍន៏ និងការធំលូតលាស់ផ្នែករាងកាយ និងខួរក្បាល/សតិបញ្ញា ។ គឺចង់សំដៅដល់ពពួកកាបូអ៊ីដ្រាត ប្រូតេអ៊ីន និងខ្លាញ់ ហើយត្រូវបានវាស់វែងគិតជាគីឡូកាឡូរី ឬក្រាម ។ ម៉ាក្រូសារជាតិតែឯកឯង គឺមិនគ្រប់គ្រាន់សំរាប់របបអាហារមានតុល្យភាពមួយនោះទេ ហើយត្រូវបំពេញបន្ថែមដោយពពួកមីក្រូសារជាតិ ដែលជាត្រូវការមានក្នុងបរិមាណតិច តួចប៉ុណ្ណោះ ។ កង្វះពពួកម៉ាក្រូសារជាតិ ជាទូទៅនឹងបណ្តាលឱ្យកើតមានភាពស្រេកឃ្លាន និងកង្វះសារជាតិចិញ្ចឹម ។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព តម្រូវការរបបអាហារថាមពល/តម្រូវការបរិភោគរបបអាហារថាមពល មីក្រូសារជាតិ ។

*NOTES...*

# MALNUTRITION (MALNOURISHMENT)

Refers to all deviations from adequate nutrition, including undernutrition and over-nutrition, resulting from inadequacy of food (or excess food) relative to need and or disease.  Categories of malnutrition are as follows:

1. Acute Malnutrition (Wasting):Acute malnutrition results in low weight in relation to height/length and/or the presence of oedema.  It is often the result of a crisis or food emergency.
2. Chronic Malnutrition (Stunting): Food consumption is inadequate to support normal growth.  Reflected by growth retardation, meaning a height-for-age score below one, two or three Standard Deviations from the reference population (mild, moderate and severe stunting respectively).  It is due to chronic or temporary nutritional deficiencies during critical times (energy and/or micronutrients), and/or it also can be the result of repeated exposure to infections or even to generally poor living conditions.  It is often poverty related.
3. Growth retardation (Underweight): A combination of stunting and wasting, this indicator measures the prevalence of children that have a low weight in relation to other children of their age.  The same metric, the Z-score and cut-points -1, -2 and -3 are used to define mild, moderate and severe underweight status are used.
4. Micronutrient Deficiencies: Inadequate intake of critical micronutrients (minerals and vitamins) as a result of poor diet or food utilization.  Micronutrient deficiencies increase risks of infectious diseases and weaken immune systems.
5. Overnutrition: Excessive consumption of macronutrients, resulting in excess body weight and/or poor physical and metabolic function.  Obesity refers to an advanced form of Overnutrition.  Causes include dietary, economic, social and lifestyle related factors.

Related Terms:  balanced diet, macronutrient, micronutrient, nutrition, nutritional status, nutrition security, overweight, obesity, undernourishment, z-score

*NOTES...*

A B C D E F G H I J K L **M** N O P Q R S T U V W X Y Z

## បញ្ហាកង្វះអាហារូបត្ថម្ភ (កង្វះសារជាតិចិញ្ចឹម)

និយាយសំដៅ ដល់លំងាកទាំងអស់ដែលបណ្តាលមកពីអាហារូបត្ថម្ភមិនគ្រប់គ្រាន់ រួមមានខ្វះអាហារូបត្ថម្ភ (អាហារូបត្ថម្ភ ខ្សត់ខ្សោយ) និងលើសអាហារូបត្ថម្ភ ដែលបណ្តាលមកពីចំណីអាហារមិនគ្រប់គ្រាន់ (ឬ លើសអាហារ) ទាក់ទិនទៅនឹងតំរូវការ និង/ឬជំងឺ ។ ប្រភេទនៃកង្វះអាហារូបត្ថម្ភគឺមានដូចខាងក្រោម៖

១) កង្វះអាហារូបត្ថម្ភស្រួចស្រាវ (ស្គមស្គាំង)៖ កង្វះអាហារូបត្ថម្ភស្រួចស្រាវបណ្តាលអោយមានទំងន់ទាបធៀបទៅនឹងកំពស់/ប្រវែង និង/ឬមានចេញហើមមានស្នាមទ្រុឌនៅលើជើងទាំងសងខាង ។ ជាញឹកញាប់វាគឺជាលទ្ធផលនៃវិបត្តិមួយ ឬក៏ស្ថានភាពបន្ទាន់នៃស្បៀង ។

២) កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិន)៖ ការបរិភោគស្បៀង គឺមិនគ្រប់គ្រាន់ដើម្បីនឹងគាំទ្រដល់ការធំលូតលាស់ជាធម្មតា ។ វាត្រូវបានឆ្លុះបញ្ចាំងដោយឃើញមានការធំលូតលាស់យឺតយ៉ាវ មានន័យថាពិន្ទុកំពស់ធៀប នឹងអាយុស្ថិតនៅក្រោម -១ -២ ឬ -៣SD ពីប្រជាជនយោង (គឺ ក្រិនកំរិតស្រាល មធ្យម និងធ្ងន់ធ្ងរ តាមលេខរៀងខាងលើ) ។ វាគឺបណ្តាលមកអំពីកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ ឬបណ្តោះអាសន្ន នៅក្នុងអំឡុង ពេលស្រួចស្រាវណាមួយ (ថាមពល និង/ឬមីក្រូសារជាតិ) និង/ឬវាក៏អាចជាលទ្ធផលនៃការកើតមាន ផ្ទួនៗគ្នានូវការបង្ករោគផ្សេងៗ ឬជាងនេះទៅទៀត គឺបណ្តាលមកពីលក្ខខណ្ឌរស់នៅអន់ខ្សោយជាទូទៅ ។ ជារឿយៗវាគឺមានទំនាក់ទំនងទៅនឹងភាពក្រីក្រ ។

៣) ការយឺតយ៉ាវក្នុងការធំលូតលាស់ (ទំងន់ក្រោមស្តង់ដារ)៖ គឺជាការរួមផ្សំគ្នានៃភាពគ្រោះក្រិន និងស្គមស្គាំងរង្វាស់សូចនាករនេះ វាស់វែងពីអត្រាប្រេវ៉ាឡង់នៃកុមារដែលមានទំងន់ទាបធៀបទៅនឹងកុមារផ្សេងៗទៀតដែលមានអាយុប៉ុនគ្នា ។ មេទ្រិចតែមួយដូចគ្នា ពិន្ទុហ្សៃត និងខ្នាត់ពិន្ទុ -១ -២ និង -៣ ត្រូវបានប្រើដើម្បីកំនត់ពីស្ថានភាពទំងន់ក្រោមស្តង់ដារកំរិតស្រាល មធ្យម និងធ្ងន់ធ្ងរ ។

៤) កង្វះមីក្រូសារជាតិ ៖ ការបរិភោគមិនគ្រប់គ្រាន់នូវមីក្រូសារជាតិសំខាន់ៗជាអាយុជីវិត (រ៉ែខនិជ និងវីតាមីន) ជាលទ្ធផលនៃរបបអាហារ ឬក៏ការប្រើប្រាស់ និងបឺតស្រូបចំណីអាហារអន់ខ្សោយ ។ កង្វះមីក្រូសារជាតិបង្កើតឱ្យមានគ្រោះថ្នាក់ប្រឈមនឹងជំងឺបង្ករោគផ្សេងៗ និងធ្វើឱ្យប្រព័ន្ធភាពស៊ាំចុះអន់ថយ ។

៥) លើសអាហារូបត្ថម្ភ ៖ ការបរិភោគពួកម៉ាក្រូសារជាតិច្រើនហួសហេតុ បណ្តាលឱ្យទំងន់រាងកាយកើនជ្រុល និង/ឬ មុខងារមេតាបូលីស និងរាងកាយចុះខ្សោយ ។ ជំងឺធាត់គឺចង់សំដៅដល់ទំរង់ដែលលូតលាស់ផុត ទៅហើយនៃការលើសអាហារូបត្ថម្ភ ។ មូលហេតុផ្សេងៗរួមមាន កត្តាដែលទាក់ទងទៅនឹងរបបអាហារ សេដ្ឋកិច្ចសង្គម និងបែបបទនៃការរស់នៅ ។

ពាក្យដែលទាក់ទងគ្នា ៖ របបអាហារមានតុល្យភាព ម៉ាក្រូសារជាតិ មីក្រូសារជាតិ អាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ ការលើសទម្ងន់ ជម្ងឺធាត់ កង្វះសារជាតិចិញ្ចឹម ពិន្ទុ-ហ្សៃត ។

# MICRONUTRIENTS

Includes all vitamins and minerals required by humans for normal physical and cognitive development.  Vitamins are either water soluble, such as B-complex vitamins and vitamin C and generally not stored by the body, or fat-soluble (e.g., vitamins A and D), which can be stored by the body.

Related Terms:  balanced diet, macronutrient, micronutrient, nutrition, nutritional status, nutrition security, undernourishment

## មីក្រូសារជាតិ

រាប់បញ្ចូលជីវជាតិទាំងអស់ និងរ៉ែខនិជទាំងអស់ និងរ៉ែដែលតំរូវត្រូវការដោយមនុស្ស ដើម្បីអភិវឌ្ឍន៍ខួរក្បាល និងរាងកាយធម្មតា ។ វីតាមីនអាចជាវីតាមីនដែលរលាយក្នុងទឹកដូចជា វីតាមីនបេកំប្លេ និងវីតាមីនសេ ហើយជាទូទៅមិនបានស្តុក ទុកនៅក្នុងរាងកាយទេ ឬក៏វីតាមីនដែលរលាយនៅក្នុងខ្លាញ់ (ឧទាហរណ៍ វីតាមីនអា និងដេ ដែលអាចស្តុកទុកនៅក្នុង រាងកាយបាន) ។

ពាក្យដែលទាក់ទងគ្នា ៖ របបអាហារមានតុល្យភាព ម៉ាក្រូសារជាតិ មីក្រូសារជាតិ អាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ កង្វះសារជាតិចិញ្ចឹម ។

*NOTES...*

A B C D E F G H I J K L **M** N O P Q R S T U V W X Y Z

# MICRONUTRIENT DEFICIENCIES

Inadequate intake of critical micronutrients (most often including Vitamin A, D, iron, iodine, zinc) as a result of poor diet or food utilization. Micronutrient deficiencies increase risks of infectious diseases and weaken immune systems. Examples of how deficiencies are calculated by FAO are as follows :

1. Iron: Animal iron dietary availability is the sum of iron derived from animal products (i. e. meat, milk, fish, animal fats, eggs). The vegetal iron availability is derived from vegetable products (i. e. cereals, pulses, roots and tubers, vegetable oils, fruits, vegetables, etc.). Dietary availability of iron is calculated by converting the amount of food available for human consumption as estimated by the FAO Food Balance Sheets in equivalents of iron content.

2. Vitamin A: The dietary availability of vitamin A is calculated by converting the amount of food available for human consumption as estimated by the FAO Food Balance Sheets in equivalent of Vitamin A (micrograms of retinol activity equivalent - RAE).

Related Terms: balanced diet, macronutrient, micronutrient, nutrition, nutritional status, nutrition security, undernourishment

*NOTES...*

## បញ្ហាកង្វះពពួកមីក្រូសារជាតិ

ការបរិភោគមិនគ្រប់គ្រាន់នូវមីក្រូសារជាតិដ៏សំខាន់យ៉ាងខ្លាំង (ញឹកញាប់បំផុតនោះ រួមមាន វីតាមីនអា ដេ ជាតិដែក ជាតិអ៊ីយ៉ូដ ជាតិសង្កសី) ជាលទ្ធផលនៃរបបអាហារខ្សត់ខ្សោយ ឬក៏ការប្រើប្រាស់ និងបឺតស្រូបរបបអាហារខ្សត់ខ្សោយ ។ កង្វះមីក្រូសារជាតិបានបង្កើតឱ្យមានគ្រោះថ្នាក់ប្រឈមនឹងការកើតមានជំងឺបង្ករោគផ្សេងៗ និងធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំ ។ ឧទាហរណ៍នៃរបៀបដែលកង្វះអាហារូបត្ថម្ភត្រូវបានគណនាដោយអង្គការ FAO មានដូចខាងក្រោម[១] :

ក) ជាតិដែក : ការមានរបបអាហារសំបូរជាតិដែកដែលបានមកពីសត្វ គឺជាបរិមាណសរុបនៃជាតិដែកដែលបានមកអំពីផលិតផលសត្វ (គឺមានន័យថា សាច់ ទឹកដោះ ត្រី ខ្លាញ់សត្វ ស៊ុត) ។ ការមានជាតិដែកនៅក្នុងបន្លែ គឺត្រូវបានបំលែងចេញពីផលិតផលបន្លែបង្ការ (គឺមានន័យថា គ្រាប់ធញ្ញជាតិ គ្រាប់រុក្ខជាតិ ពពួកមើម ប្រេងរុក្ខជាតិ ផ្លែឈើបន្លែ ។ល ។) ។ ការមានជាតិដែកនៅក្នុងរបបអាហារ គឺត្រូវបានគណនា ដោយធ្វើការបំលែងបរិមាណស្បៀងដែលមានសំរាប់មនុស្សបរិភោគ ដោយប៉ាន់ស្មានដោយតារាងតុល្យភាពចំណីអាហាររបស់អង្គការ FAO គិតជាសមមូលនៃចំណុះជាតិដែក ។

ខ) ជីវជាតិអា : ការមានក្នុងរបបអាហារនូវជីវជាតិអា គឺត្រូវបានគណនាដោយបំលែងបរិមាណចំណីអាហារដែលមានសំរាប់មនុស្សបរិភោគ ដូចដែលត្រូវបានធ្វើការប៉ាន់ស្មានដោយតារាងតុល្យភាពចំណីអាហាររបស់អង្គការ FAO គិតជាសមមូលនៃចំនុះជីវិជាតិអា (ខ្នាតមីក្រូក្រាមនៃសមមូលសកម្មភាពរ៉េទីណុល-RAE)

[១] គេបានទទួលស្គាល់ថាមធ្យោបាយផ្សេងៗទៀតសំរាប់ឱ្យធ្វើការគណនារកបញ្ហាកង្វះមីក្រូសារជាតិ គឺមាននិងត្រូវបានគេដាក់ឱ្យធ្វើការអនុវត្តន៍ ។អ្នកអានដែលចាប់អារម្មណ៍ពីរឿងនេះ សូមអានយោងទៅរកផ្នែកពិគ្រោះពីធនធានរបស់ឯកសារនេះ,ឬសូមមើលគេហទំព័ររបស់អង្គការ WHO និង UNICEF ។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព ម៉ាក្រូសារជាតិ មីក្រូសារជាតិ អាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ កង្វះសារជាតិចិញ្ចឹម ។

*NOTES...*

# MONITORING

A process of checking the efficacy of action or activity.  Monitoring may consider the inputs, outputs and/or general operating context in order to determine whether plans and procedures are being followed, and will contribute to the achievement of a proposed outcome.

Related Terms:  situation analysis, qualitative data, quantitative data

## ការពិនិត្យតាមដាន

គឺជាដំណើរការនៃការផ្ទៀងផ្ទាត់ពីសក្តិសិទ្ធិភាពនៃសកម្មភាពមួយ ។ ការចុះពិនិត្យតាមដានអាចនឹងពិចារណាអំពីធាតុចូលលទ្ធផល និង/ឬបរិបទនៃប្រតិបត្តិការទូទៅ ដើម្បីនឹងកំនត់ថាតើផែនការ និងនិតិវិធីកំពុងតែត្រូវបានគេអនុវត្តន៍ដែរឬទេ ហើយតើវានឹងរួមចំនែកដល់ការសំរេចបាន នូវលទ្ធផលដែលបានលើកឡើងដែរឬទេ ។

ពាក្យដែលទាក់ទងគ្នា :  ការវិភាគពីស្ថានភាព  ទិន្នន័យតាមបែបគុណភាព   ទិន្នន័យតាមបែបបរិមាណ ។

*NOTES...*

# MORBIDITY RATE

The number of people in a population who have a disease at a given time (e.g., 20,000 cases of influenza in a population of 100,000 people equals a 20% morbidity rate).

Related Terms: mortality rate

## អត្រាឈឺ

ចំនួនប្រជាជនដៅក្នុងចំណោមប្រជាជនមួយក្រុម ដែលកើតមានជំងឺនៅពេលកំនត់មួយ (ឧទាហរណ៍ ២០.០០០ ករណី កើតមានជំងឺផ្តាសាយនៅក្នុងចំណោមប្រជាជន ១០០.០០០នាក់ ស្មើនឹងអត្រាឈឺ ២០%) ។

ពាក្យដែលទាក់ទងគ្នា : អត្រាឈឺ ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# MORTALITY RATE

Percentage of people who die from the illness over a specific period of time (e.g., 20 deaths per 100,000 people per year equals a 0.02% mortality rate).

Related Terms: morbidity rate

## អត្រាស្លាប់

ភាគរយនៃប្រជាជនដែលបានស្លាប់ដោយសារជំងឺ នៅក្នុងរយៈពេលមួយ ជាក់លាក់ (ឧទាហរណ៍ ២0នាក់ស្លាប់ក្នុង ១00.000នាក់/១ឆ្នាំ គឺមានអត្រាស្លាប់ស្មើនឹង 0.0២%) ។

ពាក្យដែលទាក់ទងគ្នា ៖ អត្រាឈឺ ។

*NOTES...*

# MULTI INDICATOR CLUSTER SURVEY (MICS)

A UNICEF-supported process which furthers national collection and analysis of household level data for the purposes of the monitoring the situation of children and women. The MICS process produces statistically sound and internationally comparable estimates of a range of indicators in the areas of health, education, nutrition, child protection and HIV/AIDS.

Related Terms: information needs, CFSVA.

## ការអង្កេតអំពីកម្រងសូចនាករចម្រុះ

ដំណើរការដែលគាំទ្រ ដោយអង្គការយូនីសេហ្វ ដែលជាបន្តប្រមូលដោយថ្នាក់ជាតិ និងធ្វើការវិភាគពីទិន្នន័យថ្នាក់គ្រួសារសំរាប់គោលបំណងនៃការចុះពិនិត្យតាមដានសកម្មភាពរបស់កុមារ និងស្ត្រី ។ ដំណើរការនៃការអង្កេតអំពីកម្រងសូចនាករ ចម្រុះបានផលិតនូវការប៉ាន់ស្មានមួយដែលត្រឹមត្រូវល្អិតល្អន់តាមបែបស្ថិតិ និងដែលអាចប្រៀបធៀបបានជាអន្តរជាតិនូវសូចនាករមួយលំដាប់ខាងវិស័យអប់រំ អាហារូបត្ថម្ភ ការគាំពារកុមារ និងជំងឺអេដស៍ ។

ពាក្យដែលទាក់ទងគ្នា : តំរូវការព័ត៌មាន CFSVA ។

*NOTES...*

# NET DOMESTIC AVAILABILITY

The total amount of food available from all sources, including domestic production, government reserves, commercial imports and food aid.  Food used for industrial purposes, animal feed and losses are excluded from this total.  Calculated at the national level.

Related Terms:  availability, agricultural production, food availability.

## បរិមាណស្បៀងដែលមាននៅក្នុងស្រុក

ចំនួនសរុបនៃស្បៀងដែលមានមកពីគ្រប់ប្រភពទាំងអស់ រួមមានផលិតកម្មក្នុងស្រុក ស្បៀងបំរុងរបស់រដ្ឋាភិបាល ស្បៀងនាំចូលតាមផ្នែកពាណិជ្ជកម្ម និងជំនួយជាស្បៀង ។ ស្បៀងអាហារដែលប្រើសំរាប់គោលបំនងឧស្សាហកម្ម ចំណីអាហារ សត្វ និងការបាត់បង់ ត្រូវបានដកចេញពីចំនួនសរុបនេះ ។ ត្រូវគណនានៅកំរិតថ្នាក់ជាតិ ។

ពាក្យដែលទាក់ទងគ្នា ៖  លទ្ធភាពមាន/ភាពមាន  ផលិតកម្មកសិកម្ម   លទ្ធភាពមាន/ភាពមានស្បៀង ។

*NOTES...*

# NON TIMBER FOREST PRODUCTS (NTFPS)

A broad category which refers to all food, fuel, fibre and medicinal products sourced from commonly held natural resources. This may include bamboo, birds, vegetables, animals, mushrooms, insects, honey and more. For rural populations in SE Asia, this can constitute a vital source of dietary diversity.

Related Terms: access, food access, food culture, food traditions

## អនុផលព្រៃឈើ

ប្រភេទដ៏ទូលំទូលាយដែលនិយាយទៅដល់ស្បៀងអាហារទាំងអស់ គ្រឿងដុតឆេះ ពពួកកាកសរសៃ និងផលិតផល ផ្នែកឱសថដែលមានប្រភពមកពីធនធានធម្មជាតិដែលដុះ និងមានជាទូទៅក្នុងធម្មជាតិ ។ នេះអាចនឹងរាប់បញ្ចូលពពួកឫស្សី បក្សាបក្សី បន្លែបង្កា សត្វពាហនៈ ផ្សិត សត្វល្អិត ឃ្មុំ ហើយនិងផ្សេងៗច្រើននេះទៀត ។ ចំពោះប្រជាជននៅតំបន់ជនបទក្នុងតំបន់អាស៊ីអាគ្នេយ៍ អ្វីទាំងអស់នេះអាចបង្កើតបានជាប្រភពនៃរបបអាហារសំបូរបែបដ៏មានសារៈសំខាន់ជាទីបំផុត ។

ពាក្យដែលទាក់ទងគ្នា : ភាព/ឬលទ្ធភាពទទួលបាន លទ្ធភាពទទួលបានស្បៀង វប្បធម៌ក្នុងការប្រើប្រាស់ស្បៀង ប្រពៃណីក្នុងការប្រើបាស់ស្បៀង។

*NOTES...*

A B C D E F G H I J K L M **N** O P Q R S T U V W X Y Z

# NOURISHMENT

The process through which a human body draws nutrients it requires from food intake. Also refers to foods that provide nutritive value to the body.

Related Terms: balanced diet, nutrition, macronutrient, micronutrients

## អាហារសំបូរសារជាតិចិញ្ចឹម

ដំណើរការដែលតាមរយៈដំណើរការនេះរាងកាយរបស់មនុស្ស បានទាញយកសារជាតិ ចិញ្ចឹមដែលវាត្រូវការពីការបរិភោគចំណីអាហារ ។ក៏ដូចគ្នានេះដែរ គឺចង់និយាយសំដៅ ដល់ចំណីអាហារដែលផ្តល់នូវតំលៃអាហារូបត្ថម្ភដល់រាងកាយ ។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព អាហារូត្ថម្ភ ម៉ាក្រូសារជាតិ មីក្រូសារជាតិ ។

*NOTES...*

# NUTRIENT

Any chemicals required by the body to maintain basic functions, including development, repair, growth
and metabolic balances.  Humans require both macro and micro nutrients.

Related Terms:  balanced diet, macronutrient, micronutrient, nourishment,

## សារជាតិចិញ្ចឹម

ជាតិគីមីណាមួយដែលតំរូវការដោយរាងកាយ ដើម្បីរក្សាមុខងារជាមូលដ្ឋាន រួមមានការអភិវឌ្ឍន៍សតិបញ្ញា ការជួសជុល ការធំលូតលាស់ និងតុល្យភាពមេតាបូលីស ។ មនុស្សត្រូវការទាំងពពួកម៉ាក្រូ និងមីក្រូសារជាតិ ។

ពាក្យដែលទាក់ទងគ្នា ៖  របបអាហារមានតុល្យភាព  ម៉ាក្រូសារជាតិ  មីក្រូសារជាតិ   អាហារសំបូរសារជាតិចិញ្ចឹម ។

*NOTES...*

# NUTRIENT INTAKE

The process through which a body absorbs nutrients, usually through consumption of food in solid and liquid form.  Also the total measure of all nutrients consumed by an individual.

Related Terms:  balanced diet, macronutrient, micronutrient, nourishment, nutrient

## ការបរិភោគ/ការទទួលបានសារជាតិចិញ្ចឹម

គឺជាដំណើរការដែលតាមរយៈដំណើរការនេះ រាងកាយបឺតស្រូបយកសារជាតិចិញ្ចឹមតាមធម្មតា តាមរយៈការបរិភោគចំណីអាហារនៅក្នុងទម្រង់ជារាវ ហើយនិងរឹង ។ ក៏ដូចគ្នានេះដែរវា គឺជារង្វាស់សរុបនៃសារជាតិចិញ្ចឹមទាំងអស់ដែលបាន បរិភោគដោយបុគ្គលម្នាក់ ។

ពាក្យដែលទាក់ទងគ្នា ៖  របបអាហារមានតុល្យភាព  ម៉ាក្រូសារជាតិ  មីក្រូសារជាតិ  អាហារសំបូរសារជាតិចិញ្ចឹម  សារជាតិ ចិញ្ចឹម ។

*NOTES...*

# NUTRITION

The provision of food and its utilization, with the purpose of supporting growth, maintenance and general wellbeing of the body. Nutritional status has demonstrable links with health status, and thus health and nutrition are often linked. Other important linkages include relationships between nutrition and: (1) physical activity, development and work capacity; (2) mental activity, development and educational performance; (3) social behaviour and cultural practices, etc.

Related Terms: balanced diet, malnutrition, macronutrient, micronutrient, nourishment, nutrient, nutritional status, nutrition security, undernourishment

## អាហារូបត្ថម្ភ

ការផ្តល់ចំណីអាហារ និងការប្រើប្រាស់ និងបឺតស្រូបចំណីអាហារទាំងអស់នោះ ដែលមានគោលបំណងផ្តល់ការគាំទ្រដល់ការធំលូតលាស់ ការថែរក្សា និងការមានសុខុមាលភាពរាងកាយល្អជាទូទៅ។ ស្ថានភាពអាហារូបត្ថម្ភមានទំនាក់ទំនង ជាមួយនឹងស្ថានភាពសុខភាព ដែលអាចបង្ហាញឱ្យឃើញ ហើយហេតុនេះសុខភាព និងអាហា-រូបត្ថម្ភតែងតែមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ។ ទំនាក់ទំនងសំខាន់ ផ្សេងៗទៀតរួមមាន ទំនាក់ទំនងរវាងអាហារូបត្ថម្ភ ហើយនិង : ១) សកម្មភាពរាងកាយ ការអភិវឌ្ឍន៍ និង សមត្ថភាពការងារ ២) សកម្មភាពខួរក្បាល ការអភិវឌ្ឍន៍ និងការសិក្សារៀនសូត្រ ៣) ឥរិយាបថសង្គម និង ការប្រតិបត្តិផ្នែកវប្បធម៌... ។ល។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព កង្វះអាហារូបត្ថម្ភ ម៉ាក្រូសារជាតិ មីក្រូសារជាតិ អាហារសំបូរ សារជាតិចិញ្ចឹម សារជាតិចិញ្ចឹម ស្ថានភាពអាហារូបត្ថម្ភ សន្តិសុខអាហារូបត្ថម្ភ កង្វះសារជាតិចិញ្ចឹម ។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# NUTRITION SECURITY

Nutrition security exists when all people at all times consume food of sufficient quantity and quality in terms of variety, diversity, nutrient content and safety to meet their dietary needs and food preferences for an active and healthy life, coupled with a sanitary environment, adequate health, education and care.(FAO/AGN 2012)

Related Terms: food security, food and nutrition security

## សន្តិសុខអាហារូបត្ថម្ភ

សន្តិសុខអាហារូបត្ថម្ភកើតមាននៅពេលណាដែលប្រជាជនគ្រប់ៗរូប នៅគ្រប់ពេលវេលាបានបរិភោគចំណីអាហារក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ក្នុងលក្ខខណ្ឌជាអាហារចំរុះ សំបូរបែបមានចំណុះសារជាតិចិញ្ចឹម និងមានសុវត្ថិភាព ដើម្បីឆ្លើយតបរបបចំណីអាហាររបស់ខ្លួន និងចំណង់ចំណូលចិត្តអាហាររបស់ខ្លួន ដើម្បីឱ្យមានជីវិតមួយដ៏សកម្មភាព និង សុខភាពល្អដោយគួបផ្សំជាជាមួយ នឹងការមានបរិស្ថានប្រកបដោយអនាម័យ សុខភាពគ្រប់គ្រាន់ ការអប់រំ និងការថែទាំ（FAO/AGN 2012）។

ពាក្យដែលទាក់ទងគ្នា ៖  សន្តិសុខស្បៀង  សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

*NOTES...*

# NUTRITION SURVEILLANCE

All systems related to the collection, analysis and dissemination of nutritional data, usually collected at the national and provincial level.  A standard component of monitoring and evaluation, planning processes, and development of baseline studies.  Focused on but not limited to anthropometric data.  Often conducted through national health service systems.

Related Terms:  information needs, malnutrition

## ការត្រួតពិនិត្យតាមដានស្ថានភាពអាហារូបត្ថម្ភ

គ្រប់ប្រព័ន្ធទាំងអស់ដែលទាក់ទងទៅនឹងការប្រមូលទិន្នន័យ ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យអាហារូបត្ថម្ភ តាមធម្មតាត្រូវបានប្រមូលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ សមាសភាគស្តង់ដារនៃការចុះពិនិត្យតាមដាន និងការវាយតំលៃ ដំណើរការធ្វើផែនការ និងការបង្កើតការសិក្សាគ្រឹះ ។ វាត្រូវបានផ្តោតទៅលើ ប៉ុន្តែមិនដាក់កំហិតឡើយ ចំពោះទិន្នន័យ មនុស្សមាត្រ ។ ជារឿយៗវាត្រូវបានធ្វើតាមរយៈប្រព័ន្ធសេវាកម្មសុខាភិបាលថ្នាក់ជាតិ ។

ពាក្យដែលទាក់ទងគ្នា :    តំរូវការព័ត៌មាន  កង្វះអាហារូបត្ថម្ភ ។

*NOTES...*

# NUTRITIONAL DIVERSITY

Synonymous with dietary diversity.  The sum of the number of different foods or food groups consumed by an individual or household over a specific time period. This is sometimes weighted by the frequency of consumption.

Related Terms:  dietary diversity, food consumption scores

## ភាពសំបូរបែបនៃអាហារូបត្ថម្ភ

ជាសទិសន័យជាមួយនឹងពាក្យ " ភាពសំបូរបែបនៃរបបអាហារ " ។ ចំនួនសរុបនៃស្បៀងអាហារផ្សេងៗគ្នា ឬក៏ក្រុមអាហារដែលបរិភោគដោយបុគ្គល ឬដោយគ្រួសារមួយនៅក្នុងអំឡុងរយៈពេលមួយជាក់លាក់ ។ ជួនកាលចំណុចនេះត្រូវថ្លឹងថ្លែង ដោយចំនួនដងនៃការបរិភោគអាហារ ។

ពាក្យដែលទាក់ទងគ្នា : ភាពសំបូរបែបនៃរបបអាហារ   ពិន្ទុនៃការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ ។

*NOTES...*

# NUTRITIONAL STATUS

The physiological state of an individual that results from the relationship between nutrient intake and requirements and from the body's ability to digest, absorb and use these nutrients.

A summary of key nutritional status issues for children and adults is as follows:

Children:

- Prevalence of underweight in children under five years: The proportion of children under-five with weight less than that of 2 standard deviations below the median of weight-for-age of the reference population as adopted by the World Health Organization.
- Prevalence of stunting in children under five years: The proportion of children under-five with height or stature less than that of 2 standard deviations below the median of height or stature-for-age of the reference population as adopted by the World Health Organization.
- Prevalence of wasting in children under five years: The proportion of children under-five with weight below the median of weight-for-height or stature of the reference population as adopted by the World Health Organization.
- Prevalence of overweight in children under five years: The proportion of children under-five with weight above the median of weight-for-height or stature of the reference population as adopted by the World Health Organization.

Adults:

- Prevalence of underweight in adults: The proportion of underweight in adults refers to the adult population falling below 18.5 Body Mass Index (BMI).
- Prevalence of overweight in adults: The proportion of overweight in adults refers to the adult population with BMI 25 and above.
- Prevalence of obesity in adults: The proportion of obesity in adults refers to the adult population with BMI 30 and above.

Related Terms: balanced diet, BMI, malnutrition, macronutrient, micronutrient, nourishment, nutrient, nutrition security, undernourishment, z-score

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

## ស្ថានភាពអាហារូបត្ថម្ភ

សភាពសរីរៈសាស្ត្រនៃបុគ្គលម្នាក់ដែលបណ្តាលមកពីទំនាក់ទំនងរវាងការបរិភោគសារជាតិចិញ្ចឹម និងតំរូវការ ហើយនឹងបណ្តាលមកពីលទ្ធភាពរបស់រាងកាយក្នុងការរំលាយអាហារ ការបឺតស្រូប និងការប្រើប្រាស់សារជាតិចិញ្ចឹមទាំងអស់នេះ ។

សេចក្តីសង្ខេបនៃបញ្ហាស្ថានភាពអាហារូបត្ថម្ភគន្លឹះចំពោះកុមារ និងមនុស្សពេញវ័យគឺមានដូចខាងក្រោមៈ

**កុមារៈ**

- អត្រាប្រេវ៉ាឡង់នៃទំងន់ក្រោមស្តង់ដាររបស់កុមារអាយុក្រោម៥ឆ្នាំ : សមាមាត្រនៃកុមារអាយុក្រោម៥ឆ្នាំដែលមានទម្ងន់តិចជាង -២SD ទាបជាងមេដ្យាននៃទំងន់ធៀបនឹងអាយុរបស់ប្រជាជន យោងដូចដែលសំរបតំរូវដោយអង្គការសុខភាពពិភពលោក ។
- អត្រាប្រេវ៉ាឡង់នៃភាពក្រេះក្រិនរបស់កុមារអាយុក្រោម៥ឆ្នាំ : សមាមាត្រនៃកុមារអាយុក្រោម ៥ឆ្នាំ ដែលមានកំពស់ទាបជាង-២SDក្រោមចំណុចមេដ្យាននៃកំពស់ធៀបនឹងអាយុរបស់ប្រជាជន យោងដូចដែលសំរបតំរូវដោយអង្គការសុខភាពពិភពលោក ។
- អត្រាប្រេវ៉ាឡង់នៃភាពស្គមស្គាំងរបស់កុមារអាយុក្រោម៥ឆ្នាំ : សមាមាត្រនៃកុមារអាយុក្រោម ៥ឆ្នាំ ដែលមានទំងន់ទាបជាងមេដ្យាននៃទំងន់ធៀបនឹងកំពស់ របស់ប្រជាជនយោងដែលសំរបតំរូវដោយអង្គការសុខភាពពិភពលោក ។
- អត្រាប្រេវ៉ាឡង់នៃភាពលើសទំងន់របស់កុមារអាយុក្រោម៥ឆ្នាំ : សមាមាត្រនៃកុមារអាយុក្រោម ៥ឆ្នាំ ដែលមានទំងន់លើសពីចំណុចមេដ្យាននៃកំពស់ធៀបនឹងកំពស់របស់ប្រជាជនយោង ដូចដែលសំរបតំរូវដោយអង្គការសុខភាពពិភពលោក ។

**មនុស្សពេញវ័យៈ**

- អត្រាប្រេវ៉ាឡង់នៃទំងន់ក្រោមស្តង់ដារ ចំពោះមនុស្សពេញវ័យៈ សមាមាត្រនៃទំងន់ក្រោមស្តង់ដារចំពោះមនុស្សពេញវ័យ គឺនិយាយយោងទៅរកក្រុមប្រជាជនដែលជាមនុស្សពេញវ័យ ធ្លាក់ចុះក្រោមចំណុច ១៨.៥ នៃសន្ទស្សន៍ម៉ាស់រាងកាយ ។
- អត្រាប្រេវ៉ាឡង់លើសទំងន់ ចំពោះមនុស្សពេញវ័យៈ សមាមាត្រនៃអ្នកលើសទំងន់ ក្នុងចំណោមមនុស្សពេញវ័យ គឺនិយាយយោងទៅរកក្រុមប្រជាជនដែលជាមនុស្សពេញវ័យ ដែលមានពិន្ទុសន្ទស្សន៍ម៉ាស់រាងកាយស្មើនឹង ២៥ ឬលើសពីនេះ ។

- <u>អត្រាប្រេវ៉ាឡង់ជម្ងឺធាត់ ចំពោះមនុស្សពេញវ័យ</u>: សមាមាត្រនៃជម្ងឺធាត់ ក្នុងចំណោមមនុស្សពេញវ័យ គឺនិយាយយោងទៅរកក្រុមប្រជាជនដែលជាមនុស្សពេញវ័យ ដែលមានពិន្ទុសន្ទស្សន៍ម៉ាស់រាងកាយស្មើ ៣០ ឬលើសពីនេះ ។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព សន្ទស្សន៍ម៉ាស់រាងកាយ កង្វះអាហារូបត្ថម្ភ ម៉ាក្រូសារ-ជាតិ មីក្រូសារជាតិ អាហារសំបូរសារជាតិចិញ្ចឹម សារជាតិចិញ្ចឹម សន្តិសុខអាហារូបត្ថម្ភ កង្វះសារជាតិចិញ្ចឹម ពិន្ទុ-ហ្សែត។

*NOTES...*

# OBESITY

For adults, obesity refers to populations with a Body Mass Index (BMI) score of 30 and above, compared to a normal range of 18.5 to 25.

Related Terms: balanced diet, BMI, lifestyle practices, malnutrition, macronutrient, micronutrient, nutrition security nutritional status, overnutrition

## ជម្ងឺធាត់

ចំពោះមនុស្សពេញវ័យ ជំងឺធាត់គឺចង់សំដៅទៅលើប្រជាជនដែលមានពិន្ទុសន្ទស្សន៍ម៉ាស់ រាងកាយចាប់ពី ៣០ និងលើសពីនេះ ដោយប្រៀបធៀបជាមួយនឹងលំដាប់ធម្មតាដែលមានត្រឹមតែ ១៨.៥-២៥។

ពាក្យដែលទាក់ទងគ្នា ៖ របបអាហារមានតុល្យភាព សន្ទស្សន៍ម៉ាស់រាងកាយ ការប្រតិបត្តិអំពីរបៀបរបបរស់នៅ កង្វះអាហារូបត្ថម្ភ ម៉ាក្រូសារជាតិ មីក្រូសារជាតិ សន្តិសុខ អាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ លើសអាហារូត្ថម្ភ។

*NOTES...*

# OVERNUTRITION

Individual food consumption in excess of requirements, resulting in adult Body Mass Index (BMI) scores of 25-30, compared to a normal range of 18.5 to 25.

Related Terms: balanced diet, BMI, lifestyle practices, malnutrition, macronutrient, micronutrient, nutrition security nutritional status, obesity

## ការលើសអាហារូបត្ថម្ភ

ការបរិភោគស្បៀងរបស់បុគ្គលម្នាក់ៗ ក្នុងបរិមាណច្រើនហួសពីតំរូវការ ដែលបណ្ដាលឱ្យកើតមានពិន្ទុសន្ទស្សន៍ម៉ាស់រាង កាយរបស់មនុស្សពេញវ័យមានពី ២៥-៣០ ប្រៀបធៀបទៅនឹងលំដាប់ធម្មតា ដែលមានតែ ១៨.៥-២៥ ។

ពាក្យដែលទាក់ទងគ្នា : របបអាហារមានតុល្យភាព សន្ទស្សន៍ម៉ាស់រាងកាយ ការប្រតិបត្តិអំពីរបៀបរបបរស់នៅ កង្វះអាហារូបត្ថម្ភ ម៉ាក្រូសារជាតិ មីក្រូសារជាតិ សន្តិសុខអាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ ជម្ងឺធាត់ ។

*NOTES...*

# POST-HARVEST RICE

The net harvest of rice that is fit human consumption, factoring losses accrued during threshing, drying and storage, and pest-related losses.  Also known as ‘recovery rate’.

Related Terms:  agricultural production, agricultural productivity.

## **ផលិតផលស្រូវនៅក្រោយពេលប្រមូលផល**

ការប្រមូលស្រូវសុទ្ធដែលវាសក្តិសមសំរាប់ការបរិភោគរបស់មនុស្ស ការបាត់បង់នៅកន្លែងរោងចក្រ ដែលកើតឡើងក្នុងអំឡុងពេលបោកបែនស្រូវ ការហាលសម្ងួត និងការស្តុក ហើយនិងការបាត់បង់ដែលទាក់ទងទៅនឹងសត្វល្អិតបំផ្លាញដំណាំ។ ក៏ដូចគ្នានេះដែរ គេក៏ដឹងថាជា ” អត្រានៃការហកងើបឡើងវិញ ” ។

ពាក្យដែលទាក់ទងគ្នា :  ផលិតកម្មកសិកម្ម  ផលិតភាពកសិកម្ម។

*NOTES...*

## POVERTY

Poverty encompasses different dimensions of deprivation that relate to human capabilities including consumption and food security, health, education, rights, voice, security, dignity and decent work.  It is commonly measured by income per capita.

Related Terms:  critical food poverty, food poverty line, food security, livelihoods

## ភាពក្រីក្រ

ភាពក្រីក្ររួមបញ្ចូលទាំង វិសាលភាពផ្សេងៗគ្នានៃភាពអត់ឃ្លាន ដែលទាក់ទងទៅនឹងសមត្ថភាពរបស់មនុស្ស រួមមាន ការប្រើប្រាស់ស្បៀង និងសន្តិសុខស្បៀង សុខភាព ការអប់រំ សិទ្ធិ សំលេង សន្តិសុខ ភាពថ្លៃថ្នូរ និងការងារត្រឹមត្រូវ ។ វាត្រូវបានគេវាស់វែងជាទូទៅដោយគិតពីចំណូលក្នុងមនុស្សម្នាក់ៗ ។

ពាក្យដែលទាក់ទងគ្នា ៖  ភាពកង្វះស្បៀងធ្ងន់ធ្ងរ   បន្ទាត់ភាពក្រីក្រស្បៀង  សន្តិសុខស្បៀង  ការចិញ្ចឹមជីវិត ។

*NOTES...*

## PREVALENCE

The extent to which a particular factor or experience is shared across a population. That is, the number of people within a total population who share the same circumstances.

Related Terms: indicators, primary data, proxy indicator, secondary data

## អត្រាប្រេវ៉ាឡង់

ទំហំដែលនៅក្នុងទំហំនោះ កត្តាជាក់លាក់ពិសេស ឬក៏ការឆ្លងកាត់ជួបប្រទះ ត្រូវបានរួមចំណែកជាមួយគ្នានៅទូទាំងប្រជាជនមួយក្រុម។ គឺថាចំនួននៃប្រជាជនដែលមាននៅក្នុងប្រជាជនសរុបទាំងអស់ ដែលបានរួមចំណែកនូវកាលៈទេសៈតែមួយជាមួយគ្នា ។

ពាក្យដែលទាក់ទងគ្នា ៖ សូចនាករ ទិន្នន័យបឋម/ដំបូង សូចនាករតំណាង ទិន្នន័យដែលមានស្រាប់/ដែលអាចរក បានស្រាប់ៗ។

*NOTES...*

# PRIMARY DATA

Data collected first hand from the target population.  Primary data may be collected using a variety of methods, including interviews and questionnaires involving key informants, focus groups, households and individuals.

Related Terms:  indicators, initial assessment, proxy indicator, secondary data, household income and expenditure survey.

## ទិន្នន័យបឋម/ដំបូង

ទិន្នន័យដែលប្រមូលបានដំបូងពីប្រជាជនគោលដៅ ។ ទិន្នន័យដំបូង អាចនឹងត្រូវបានគេប្រើប្រាស់វិធីសាស្ត្រចំរុះ រួមមាន ការសម្ភាសន៍ និងកម្រងសំនួរដែលពាក់ព័ន្ធទៅនឹងអ្នកផ្តល់ពតិមានគន្លឹះសំខាន់ៗ ក្រុមដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់ គ្រួសារ និងបុគ្គល ។

ពាក្យដែលទាក់ទងគ្នា : សូចនាករ  ការវាយតំលៃជំហានដំបូង  សូចនាករតំណាង   ទិន្នន័យដែលមានស្រាប់/ដែលអាចរកបានស្រាប់ៗ  ការអង្កេតពីចំណូល និងចំណាយនៅក្នុងគ្រួសារ ។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
**P**
Q
R
S
T
U
V
W
X
Y
Z

# PRIORITY

In policy and programming, the issue or issues which are most important or require most immediate attention.

Related Terms: situation analysis, initial assessment

## អាទិភាព

ក្នុងគោលនយោបាយ និងការធ្វើកម្មវិធី បញ្ហាមួយ ឬបញ្ហាច្រើនដែលមានសារៈសំខាន់ជាទីបំផុត ឬត្រូវឱ្យមានការយកចិត្តទុកដាក់ភ្លាមៗខ្លាំងបំផុត ។

ពាក្យដែលទាក់ទងគ្នា ៖  ការវិភាគពីស្ថានភាព  ការវាយតំលៃជំហានដំបូង។

*NOTES...*

# PROXY INDICATOR

An indirect means of measuring a variable that cannot be measured directly.  They provide information about a factor indirectly.  For example, expenditure on food may be a proxy for food consumption.

Related Terms:  indicator, information needs, primary data, quantitative

## សូចនាករតំណាង

មធ្យោបាយនៃការវាស់វែងដោយប្រយោលនូវតំលៃអថេរមួយ ដែលគេមិនអាចវាស់វែងបានដោយផ្ទាល់ ។វា បានផ្តល់នូវព័តិមានស្តីអំពីកត្តាមួយដោយប្រយោល ។ ឧទាហរណ៍ៈ ការចំណាយទៅលើចំណីអាហារ អាចជាសូចនាករតំណាងសំរាប់ ការប្រើប្រាស់ ។

ពាក្យដែលទាក់ទងគ្នា :  សូចនាករ  តំរូវការព័តិមាន  ទិន្នន័យបឋម/ដំបូងតាមបែបបរិមាណ។

*NOTES...*

# QUALITATIVE DATA

Observations that are categorical rather than numerical; they often involve attitudes, perceptions and intentions.  Qualitative data often helps understand the context of things.

Related Terms:  indicator, information needs, primary data, quantitative

## ទិន្នន័យតាមបែបគុណភាព

គឺជាការសង្កេតដើម្បីរកមើលពីប្រភេទលក្ខណៈជាជាងរកមើលពីចំនួន ។ ជាទូទៅវាពាក់ព័ន្ធទៅនឹងឥរិយាបថ/អាកប្បកិរិយា ការយល់ដឹង និងបំណងប្រាថ្នា ។ ទិន្នន័យតាមបែបគុណភាព ជារឿយៗអាចឱ្យជួយយល់ដឹងពីបរិបទនៃរឿងរ៉ាវសំខាន់ៗ ។

ពាក្យដែលទាក់ទងគ្នា :  សូចនាករ  តំរូវការព័តិមាន  ទិន្នន័យបឋម/ដំបូង  តាមបែបបរិមាណ ។

*NOTES...*

# QUANTITATIVE DATA

Measurements of quantities, amounts or ranges, expressed as numbers that can be analyzed using statistical methods and models. Quantitative data indicates the absolute number and percentage of people sharing common characteristics.

Related Terms: indicator, information needs, primary data, qualitative

## ទិន្នន័យតាមបែបបរិមាណ

គឺជាការវាស់វែងអំពីបរិមាណ ចំនួន ឬក៏លំដាប់ ដែលបញ្ជាក់ជាលេខដែលគេអាចនឹងវិភាគដោយប្រើប្រាស់វិធីសាស្ត្រ និង គំរូតាមបែបស្ថិតិ ។ ទិន្នន័យតាមបែបបរិមាណចង្អុលបង្ហាញអំពីចំនួនដាច់ខាត និងភាគរយនៃប្រជាជនដែលបានរួមចំណែក នូវលក្ខណៈជាក់លាក់ ពិសេសទូទៅ ។

ពាក្យដែលទាក់ទងគ្នា ៈ សូចនាករ តំរូវការព័ត៌មាន ទិន្នន័យបឋម/ដំបូង តាមបែបគុណភាព។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
S
T
U
V
W
X
Y
Z

# RANDOM SAMPLING

A sampling method used for sample surveys, in which each unit within the scope of the survey has a fixed, but not necessarily the same, probability of selection in the sample. It may contrast with “purposive sampling” in which populations are selected for a certain characteristics (e.g. poor households).

Related Terms: information needs, sample survey, sampling error, sampling frame

## ការជ្រើសរើសចំនួនសំណាកតាមវិធីរើសដោយចៃដន្យ

គឺជាវិធីជ្រើសរើសសំណាក ដោយប្រើសំរាប់ជ្រើសរើសចំនួនសំណាកសំរាប់ធ្វើការអង្កេត ដែលនៅក្នុងនោះឯកតានីមួយៗ នៅក្នុងទំហំនៃការអង្កេតមានប្រូបាប៊ីលីតេនៃការជ្រើសរើសចំនួនសំណាក គឺមានការកំណត់ ប៉ុន្តែមិនចាំបាច់អោយដូចគ្នានោះទេ។ វាអាចផ្ទុយគ្នាទៅនឹងការជ្រើសរើសសំណាកតាមគោលបំនង ដែលក្នុងនោះប្រជាជនទាំងអស់ត្រូវបានជ្រើសរើសសំរាប់លក្ខណៈជាក់លាក់ណាមួយ (ឧទាហរណ៏ គ្រួសារក្រីក្រ) ។

ពាក្យដែលទាក់ទងគ្នា : តំរូវការព័តិមាន ចំនួនសំណាកសំរាប់ធ្វើការអង្កេត កំហុស/លំអៀងក្នុងការជ្រើសរើសចំនួនសំណាក បញ្ជីចំនួនសំណាក។

*NOTES...*

# RAPID ASSESSMENT

A quick and incomplete assessment based on a combination of secondary and primary data.  Often undertaken following an initial assessment in a sudden crisis, or as a component of a reassessment.  Because of the short time-frame, rapid assessments most often focus on qualitative data collection.

Related Terms:  initial assessment, information needs, situation analysis, qualitative

## ការអង្កេតដោយត្រួសៗអំពីស្ថានភាពទូទៅ

ការអង្កេតរហ័ស និងមិនបានពេញលេញ ដោយផ្អែកទៅលើការរួមបញ្ចូលគ្នារវាងទិន្នន័យដែលមានស្រាប់ និងទិន្នន័យដំបូង (ពីការអង្កេត) ។ ជារឿយៗវាត្រូវបានធ្វើឡើងបន្ទាប់ពីមានការអង្កេតជំហានដំបូងមួយនៅក្នុងពេលមានវិបត្តិបន្ទាន់ភ្លាមៗ ឬក៏ជាសមាសភាគនៃការវាយតំលៃឡើងវិញ ។ ដោយសារតែក្របខ័ណ្ឌនៃពេលវេលារយៈពេលខ្លី ការវាយតំលៃ ឬការអង្កេត រហ័សជាញឹកញាប់បំផុត គឺផ្តោតទៅលើការប្រមូលទិន្នន័យតាមបែបគុណភាព ។

ពាក្យដែលទាក់ទងគ្នា :  ការវាយតំលៃជំហានដំបូង  តំរូវការព័ត៌មាន   ការវិភាគពីស្ថានភាព   តាមបែបគុណភាព ។

*NOTES...*

# RESPONSE ANALYSIS

Response analysis is the process of connecting needs assessment or situational analysis to program design. The process by which a set of actions is identified based on (a) the needs and livelihoods of the
affected population (b) the operating environment and (c) resources available.

Related Terms: emergency response, risk analysis, situation analysis, vulnerability analysis

## ការវិភាគពីវិធានការសម្រាប់ទប់ស្កាត់

ការវិភាគពីវិធានការសម្រាប់ទប់ស្កាត់គឺជ ដំណើរការនៃការអង្កេតពីតំរូវការដែលមានទំនាក់ទំនងរវាងគ្នា ឬក៏ការវិភាគអំពីសភាពការណ៍ទូទៅ ដើម្បីរចនារៀបចំកម្មវិធី ។ ដំណើរការនេះដែលជាសកម្មភាពមួយលំដាប់ត្រូវបានកំនត់ ដោយផ្អែកលើ ក) តំរូវការ និងជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ ខ) បរិស្ថានដែលកំពុងប្រតិបត្តិការ និង គ) ធនធានដែលមាន ។

ពាក្យដែលទាក់ទងគ្នា : ការឆ្លើយតបនឹងស្ថានភាពបន្ទាន់ ការវិភាគពីហានិភ័យ ការវិភាគពីស្ថានភាព ការវិភាគពីភាពងាយរងគ្រោះ ។

*NOTES...*

# RICE CONSUMPTION

The total quantity of rice consumed by the household or individual, measured in grams or less commonly, kilocalories.  In SE Asia, often erroneously applied as a proxy indicator for food security.

Related Terms:  consumption, food consumption, food security

## ការប្រើប្រាស់អង្ករ/ការបរិភោគបាយ

បរិមាណសរុបនៃអង្ករដែលបានបរិភោគ ដោយគ្រួសារ ឬបុគ្គលម្នាក់ៗដោយវាស់វែងជាក្រាម (gm.) ឬមិនសូវជាទូទៅទេ គឺមានការវាស់វែងជាគីឡូកាឡូរី (Kcal.) ផងដែរ ។ នៅតំបន់អាស៊ីអាគ្នេយ៍ ជារឿយៗការប្រើប្រាស់អង្ករ/ការ បរិភោគបាយត្រូវបានគេអនុវត្តដោយខុសឆ្គង ដោយយកធ្វើជាសូចនាករតំណាងសំរាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

ពាក្យដែលទាក់ទងគ្នា :   ការប្រើប្រាស់/ការបរិភោគ  ការប្រើប្រាស់ស្បៀង/ បរិភោគចំណីអាហារ  សន្តិសុខស្បៀង ។

*NOTES...*

# RICE DEFICIENCY

A qualitative and/or quantitative measure of overall rice availability at the household or community level. As a qualitative measure, measured in months without adequate rice, based on available stocks. As a quantitative measure, expressed in shortfall per household member in grams. As with rice consumption, care should be taken that rice deficiency not be used as a catch-all proxy indicator for food insecurity.

Related Terms: critical food poverty, degree of food deprivation, food consumption gap, food security, rice consumption, proxy indicator

## កង្វះខាតផលិតផលស្រូវ

រង្វាស់តាមបែបគុណភាព និង/ឬបែបបរិមាណនូវស្រូវ/អង្ករ ជាទូទៅដែលមាននៅថ្នាក់គ្រួសារ ឬនៅថ្នាក់សហគមន៍ ។ ជារង្វាស់តាមបែបគុណភាព គឺត្រូវបានគេវាស់វែង ដោយគិតជាខែ ដោយពុំគិតពីការមានស្រូវគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ទេ គឺផ្អែកទៅលើស្តុកស្រូវដែលមានតែប៉ុណ្ណោះ ។ ជារង្វាស់តាមបែបបរិមាណ គឺត្រូវបានគេវាស់វែងដោយគិតជាកង្វះខាត ក្នុងសមាជិកគ្រួសារម្នាក់ៗដោយគិតជាក្រាម ។ ជាមួយនឹងការប្រើប្រាស់ស្រូវ/អង្ករ ការប្រយ័ត្នប្រយែង គេគួរតែប្រកាន់យក ដោយបញ្ហាកង្វះស្រូវ/អង្ករមិនត្រូវបានគេយកមកប្រើប្រាស់ធ្វើជាសូចនាករតំណាង ដែលអាចក្តោបយកបញ្ហាទាំង អស់បាន (catch-all proxy indicator) សំរាប់អសន្តិសុខស្បៀងឡើយ ។

ពាក្យដែលទាក់ទងគ្នា : ភាពក្រីក្រនៃស្បៀងធ្ងន់ធ្ងរ កំរិតនៃការបង្អត់អាហារ/ភាពខ្វះខាតចំណីអាហារ ភាពខ្វះចន្លោះ ក្នុងការប្រើប្រាស់ស្បៀង/បរិភោគចំណីអាហារ សន្តិសុខស្បៀង ការប្រើប្រាស់អង្ករ/ការបរិភោគបាយ សូចនាករតំណាង ។

*NOTES...*

# RISK ANALYSIS

A methodology to analyze potential hazards and evaluating existing conditions of vulnerability that together could potentially harm exposed people, property, services, livelihoods and the environment on which they depend.

Risk assessments (and associated risk mapping) include: a review of the technical characteristics of hazards such as their location, intensity, frequency and probability; the analysis of exposure and vulnerability including the physical social, health, economic and environmental dimensions; and the evaluation of the effectiveness of prevailing and alternative coping capacities.  This series of activities is sometimes known as a risk analysis process.

Related Terms:  situation analysis, vulnerability analysis

## ការវិភាគពីហានិភ័យ

វិធីសាស្ត្រដើម្បីធ្វើការវិភាគពីហានិភ័យដ៏មានសក្តានុពល និងការវាយតំលៃចំពោះលក្ខខណ្ឌ ដែលមានស្រាប់នៃភាពងាយរងគ្រោះ ដែលជាមួយគ្នានេះអាចនឹងធ្វើឱ្យអន្តរាយយ៉ាងខ្លាំងក្លាទៅលើប្រជាជនដែលប្រឈមនឹងវាទ្រព្យសម្បត្តិ សេវាកម្មជីវភាពរស់នៅ និងបរិស្ថានដែលពួក គេអាស្រ័យទៅលើវា។

ការវាយតំលៃពីហានិភ័យ (និងការធ្វើផែនទីពីតំបន់ដែលមានការរួមចំណែកនឹងហានិភ័យនេះ) រួមមានការពិនិត្យឡើងវិញនូវលក្ខណៈជាបច្ចេកទេសនៃហានិភ័យដូចជា ទីតាំងរបស់វា អាំងតង់ស៊ីតេ ភាពញឹកញាប់ និងប្រូបាប៊ីលីតេ  ការវិភាគ អំពីការសំដិលទៅរកបញ្ហា និងភាពងាយរងគ្រោះ រួមមាន : វិសាលភាពផ្នែករូបវ័ន្តនៃសង្គម សុខភាព សេដ្ឋកិច្ច និង បរិស្ថាន  និងការវាយតំលៃពីប្រសិទ្ធិភាពនៃសមត្ថភាពក្នុងការដោះស្រាយបញ្ហាទូលំទូលាយទូទៅ និងតាមការជំរើស។ សកម្មភាពមួយស៊េរី៧ (មួយលំដាប់) នេះ ជួនកាលត្រូវបានគេដឹងថាជាដំណើរការនៃការវិភាគពីហានិភ័យ។

ពាក្យដែលទាក់ទងគ្នា :  ការវិភាគពីស្ថានភាព   ការវិភាគ ពីភាពងាយរងគ្រោះ។

*NOTES...*

# SAMPLE SURVEY

The collection of data from a limited set of units, rather than all units as in a census.

Related Terms: information needs, random sampling, sampling error, sampling frame

## ការអង្កេតអំពីចំនួនសំណាក

ការប្រមូលទិន្នន័យពីឯកត្តាមួយសើរី (១ឈុត) ដែលមានកំណត់ជាជាងពីឯកត្តាទាំងអស់ ដូចដែលមាននៅក្នុង ការធ្វើជំរឿន ។

ពាក្យដែលទាក់ទងគ្នា : តំរូវការព័តិមាន ការជ្រើសរើសសំណាកដោយចៃដន្យ កំហុស/លំអៀងក្នុងការជ្រើសរើសចំនួនសំណាក បញ្ជីចំនួនសំណាក។

*NOTES...*

# SAMPLING ERRORS

The errors in statistics obtained from a sample survey because data are collected from only a sample of units, rather than from the entire population.

Related Terms: information needs, random sampling, sample survey, sampling frame

## កំហុស/លំអៀងក្នុងការជ្រើសរើសចំនួនសំណាក

កំហុស/លំអៀងខាងផ្នែកស្ថិតិ ដែលទទួលបានពីសំណាកសំរាប់ធ្វើការអង្កេត ដោយសារតែទិន្នន័យត្រូវបានប្រមូលតែពីសំណាកមួយនៃឯកត្តាទាំងអស់ជាជាងពីប្រជាជនទាំងមូល ។

ពាក្យដែលទាក់ទងគ្នា ៖ តំរូវការព័ត៌មាន ការជ្រើសរើសសំណាកដោយចៃដន្យ សន្ទិសុខស្បៀង លទ្ធភាពទទួលបាន ។

*NOTES...*

# SAMPLING FRAME

The means by which all units within a projected area of interest (geographic, social, economic or other) are identified for a sample survey.

Related Terms:  information needs, random sampling, sampling error, sample survey

## បញ្ជីចំនួនសំណាក

ចំនួនក៏រិតមធ្យម ដែលតាមរយៈចំនួនក៏រិតមធ្យមនោះ ឯកត្តាទាំងអស់នៅក្នុងតំបន់ដែលមានការចាប់អារម្មណ៏របស់គំរោងកម្មវិធី (ភូមិសាស្រ្ត សង្គម សេដ្ឋកិច្ច ឬផ្សេងៗទៀត) ត្រូវបានកំណត់យកធ្វើជាសំណាកសំរាប់ចុះធ្វើការអង្កេត។

ពាក្យដែលទាក់ទងគ្នា :  តំរូវការព័តិមាន  លទ្ធភាព/ភាពមាន លទ្ធភាពទទួលបាន  សន្តិសុខស្បៀង។

*NOTES...*

# SANITATION

Refers to the provision of facilities and services for the safe disposal of human waste, such as urine and faeces. Inadequate sanitation is a major cause of disease world-wide and improving sanitation is known to have a significant beneficial impact on health and food security both in households and across communities. Also refers to the maintenance of hygienic conditions, through services such as garbage collection and wastewater disposal.

Related Terms: hygiene, sanitation service

## អនាម័យ( លំនៅដ្ឋាន/បរិស្ថាន)

និយាយសំដៅទៅរកការផ្តល់គ្រឿងប្រដាប់ប្រដារសំរាប់ធ្វើអនាម័យ និងសេវាសម្រាប់ការបញ្ចេញចោលប្រកបដោយសុវត្ថិភាព នូវកាកសំណល់ទាំងឡាយរបស់មនុស្ស ដូចជាទឹកនោម និងលាមក ។ កង្វះអនាម័យ ឬអនាម័យមិនគ្រប់គ្រាន់ គឺជាមូលហេតុចំបងដែលបណ្តាលឱ្យកើតមានជម្ងឺនៅទូទាំពិភពលោក ហើយការធ្វើឱ្យប្រសើរឡើងនូវបញ្ហាអនាម័យត្រូវបានគេដឹងថា មានផលប៉ះពាល់ជាគុណប្រយោជន៏ដ៏ធំធេងទៅលើសុខភាព និងសន្តិ-សុខស្បៀង ទាំងនៅតាមគ្រួសារ និង នៅតាមទូទាំងសហគមន៏ ។ ក៏ដូចគ្នានេះដែរ ពាក្យនេះក៏ត្រូវបាននិយាយសំដៅទៅរកការថែរក្សាលក្ខខណ្ឌអនាម័យ តាមរយៈសេវានានា ដូចជា សេវាប្រមូលសំរាម និង សេវាបញ្ចេញទឹកលូ/ទឹកសំអុយជាដើម ។

ពាក្យដែលទាក់ទងគ្នា : អនាម័យរាងកាយ សេវាអនាម័យ ។

*NOTES...*

A
B
C
D
E
F
G
H
I
J
K
L
M
N
O
P
Q
R
**S**
T
U
V
W
X
Y
Z

# SANITATION SERVICE

Those measures implemented to allow for hygienic disposal of wastes, such as sewerage systems, garbage collection, and public restroom facilities.

Related Terms: hygiene, sanitation

**សេវាអនាម័យ (លំនៅដ្ឋាន/បរិស្ថាន)**

វិធានការទាំងឡាយដែលត្រូវបានគេអនុវត្ត ដើម្បីធ្វើឱ្យការបញ្ចេញចោលកាកសំណល់ទាំងឡាយមានអនាម័យ ដូចជា ប្រព័ន្ធបង្ហូរទឹកលូ/ទឹកសំអុយ សេវាប្រមូលសំរាម និងបន្ទប់ទឹក/បង្គន់ សាធារណៈជាដើម ។

ពាក្យដែលទាក់ទងគ្នា : អនាម័យ (រាងកាយ) អនាម័យ (លំនៅដ្ឋាន/បរិស្ថាន) ។

*NOTES...*

# SECONDARY DATA

Data collected from outside the assessment process itself, usually from published or otherwise publicly available sources.

Related Terms: information needs, primary data

## ទិន្នន័យដែលមានស្រាប់/ដែលអាចរកបានស្រាប់ៗ

ទិន្នន័យដែលប្រមូលបាននៅខាងក្រៅពីដំណើរការនៃការចុះធ្វើការអង្កេត/ចុះវាយតំលៃដោយផ្ទាល់ តាមធម្មតាគឺទទួលបានពីការបោះពុម្ពផ្សាយ ឬបើមិនដូច្នេះទេ គឺបានពីប្រភពដែលអាចរកបានជាសាធារណៈ ។

ពាក្យដែលទាក់ទងគ្នា : តំរូវការព័ត៌មាន ទិន្នន័យបឋម/ដំបូង។

*NOTES...*

A B C D E F G H I J K L M N O P Q R **S** T U V W X Y Z

# SELF-SUFFICIENCY

In food security, refers to domestic production adequate to meet the food requirements of the total population without recourse to imports or food aid. Calculated at the national level.  Self-sufficiency in specific commodities, such as rice or fish, may also be calculated.

Related Terms:  agricultural production, agricultural productivity, availability.

## ភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯង

ចំពោះសន្តិសុខស្បៀង ពាក្យនេះ គឺចង់និយាយសំដៅទៅរកផលិតកម្មនៅក្នុងស្រុកដែលមានបរិមាណគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតំរូវការស្បៀងរបស់ប្រជាជនទាំងអស់ ដោយមិនចាំបាច់ពឹងផ្អែកទៅលើការជួយដោះបន្ទាល់ ដូចជាត្រូវនាំស្បៀងចូល ឬរកជំនួយជាស្បៀង។ គេត្រូវធ្វើការគណនានៅកំរិតថ្នាក់ជាតិ។ ភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់លើអ្នកដទៃ ចំពោះស្បៀងជាក់លាក់មួយចំនួន ដូចជា អង្ករ ឬត្រី ជាដើម គេក៏អាចនឹងត្រូវធ្វើការគណនា (នៅកំរិតថ្នាក់ ជាតិ) ផងដែរ។

ពាក្យដែលទាក់ទងគ្នា :  ផលិតកម្មកសិកម្ម  ផលិតភាពកសិកម្ម   លទ្ធភាពមាន/ភាពមាន។

*NOTES...*

# SITUATION ANALYSIS

Exploration of the current food security and nutrition status of the population and its risks to lives and livelihoods.

Related Terms: risk analysis, vulnerability analysis, initial assessment

## ការវិភាគពីស្ថានភាព

ដំណើរស្រាវជ្រាវអំពីស្ថានភាពសន្តិសុខស្បៀង និង អាហារូបត្ថម្ភនាពេលបច្ចុប្បន្នរបស់ប្រជាជន ហើយនឹងហានិភ័យរបស់វាចំពោះជីវិត និងជីវភាពរស់នៅ/ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ។

ពាក្យដែលទាក់ទងគ្នា : ការវិភាគពីហានិភ័យ ការវិភាគពីភាព ងាយរងគ្រោះ ការអង្កេត/ការចុះវាយតំលៃដំបូង ។

*NOTES...*

# STABILITY

The fourth pillar of food security, stability refers to the continuity of availability, access and utilization over time. It is emphasized in the World Food Summit definition of food security by the phrase 'all people, at all times'. Major factors that affect stability include climatic uncertainties, uneven income earning opportunities, crop disease, etc.

Related Terms: availability, access, food security, utilization

## ស្ថេរភាព

សរសរទី៤នៃសន្តិសុខស្បៀង ស្ថេរភាពគឺចង់សំដៅដល់ដំណើរការជាប់ជាបន្តនៃភាព/លទ្ធភាពមានលទ្ធភាពទទួលបាន និងការប្រើប្រាស់ និងបឺតស្រូបនៅក្នុងរយៈពេលមួយ ។ ចំណុចនេះត្រូវបានផ្តោតការយកចិត្តទុកដាក់នៅឯកិច្ចប្រជុំកំពូល ស្តីពីស្បៀងពិភពលោកក្នុងការកំណត់និយមន័យអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយឃ្លាដូចនេះថា: "   ប្រជាជនគ្រប់ៗរូប នៅគ្រប់ពេល  "   ។ កត្តាធំៗ ចំបងៗដែលប៉ះពាល់ដល់ស្ថេរភាព រួមមានភាពមិនប្រាកដប្រជានៃអាកាសធាតុ ឱកាសរកប្រាក់ចំណូលមិនទៀងទាត់ប្រែប្រួលចុះ ឡើងៗ ជម្ងឺដំណាំ ។ល ។

ពាក្យដែលទាក់ទងគ្នា :  លទ្ធភាព/ភាពមាន  លទ្ធភាពទទួលបាន  សន្តិសុខស្បៀង  ការបឺតស្រូប ។

*NOTES...*

# STABILITY OF FOOD STOCKS

The extent to which available reserves of key staple foods remain predictable over time.  This does not suggest that stock levels are constant, but rather that any/all fluctuations are within projections.

Related Terms:  availability, stability

## ស្ថេរភាពនៃការស្តុកស្បៀង

ទំហំដែលអាហារមូលដ្ឋានគន្លឹះសំខាន់ៗមានបំរុងទុក គឺនៅតែអាចព្យាករណ៍បាននៅក្នុងរយៈពេលមួយ ។ នេះគឺមិនបានផ្តល់ជាយោបល់ថា កំរិតស្តុកត្រូវតែមានជាប់ជាប្រចាំនោះទេ ក៏ប៉ុន្តែគ្រាន់តែផ្តល់ជាយោបល់ថា រាល់ការប្រែប្រួលណាមួយ គឺស្ថិតនៅក្នុងការប៉ាន់ស្មានទុកជាមុន ។

ពាក្យដែលទាក់ទងគ្នា :  លទ្ធភាព/ភាពមាន  ស្ថេរភាព ។

*NOTES...*

A B C D E F G H I J K L M N O P Q R **S** T U V W X Y Z

# STAPLE FOOD

Those food(s), usually carbohydrate-based, which form the basis for the culturally preferred diet within a nation or region.  Across Southeast Asia, rice is the dominant staple food.  In other societies, maize, wheat or root crops are important staples.

Related Terms:  food culture, nutrition

## អាហារមូលដ្ឋាន

អាហារទាំងអស់នោះ តាមធម្មតាជាអាហារនៅក្នុងក្រុមកាបូអ៊ីដ្រាត (ពពួកម្សៅ) ដែលបង្កើតជាមូលដ្ឋានរបបអាហារមួយទៅតាមចំណង់ចំណូលចិត្ត និងប្រពៃណីវប្បធម៌នៅក្នុងប្រជាជាតិមួយ ឬតំបន់មួយ ។ នៅទូទាំងអាស៊ីអាគ្នេយ៍ អង្ករ/បាយគឺជាអាហារមូលដ្ឋានមួយដ៏លើសលប់ ។ នៅសង្គមផ្សេងៗទៀត ពោត ស្រូវសាឡី ឬដំណាំជាមើម គឺជាអាហារមូលដ្ឋានមួយដ៏សំខាន់ផងដែរ ។

ពាក្យដែលទាក់ទងគ្នា :    ប្រពៃណីក្នុងការប្រើប្រាស់ស្បៀង  អាហារូបត្ថម្ភ ។

*NOTES...*

# STUNTING

Height-for-age scores below the reference population median, represented as growth retardation.  Evidence of chronic malnutrition.

Related Terms:  malnutrition, nutritional status.

## ក្រេះក្រិន

ពិន្ទុកំពស់ធៀបនឹងអាយុស្ថិតនៅក្រោមមេដ្យាន (ចំណុចកណ្តាល) នៃប្រជាជនយោង/សំអាង ដែលតំណាងឱ្យការធំលូតលាស់របស់រាងកាយមានការយឺតយ៉ាវ ។ គឺជាភ័ស្តុតាងនៃកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ ។

ពាក្យដែលទាក់ទងគ្នា ៖   កង្វះអាហារូបត្ថម្ភ  ស្ថានភាពអាហារូបត្ថម្ភ ។

*NOTES...*

A B C D E F G H I J K L M N O P Q R S T U V W X Y Z

# SUPPLEMENTARY FEEDING

Specialized feeding programs designed to address widespread prevalence of moderate acute malnutrition. Includes both in-patient and take home components of both dry and wet rations that are rich in proteins, carbohydrates and fats.

Related Terms: malnutrition, nutritional status, therapeutic feeding.

## ការផ្តល់អាហារបំប៉ន

កម្មវិធីពិសេសផ្តល់អាហារបំប៉ន ដែលត្រូវបានរចនាឡើង ដើម្បីដោះស្រាយអត្រាប្រេវ៉ាឡង់ដែលរីកសាយភាយនៃបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវមធ្យម ។ គឺរាប់បញ្ចូលទាំងសមាសភាគដែលត្រូវដេកសំរាកព្យាបាលថែទាំនៅក្នុងគ្រឹះស្ថាន សុខាភិបាល និងអ្នកដែលត្រូវទទួលអាហារបំប៉ន ហើយត្រូវវិលត្រលប់ទៅផ្ទះវិញ ដោយត្រូវទទួលរបបអាហារស្ងួត និងសើម (រាវ) ដែលសំបូរទៅដោយជាតិប្រូតេអ៊ីន (ជាតិសាច់) ពពួកកាបូអ៊ីដ្រាត (ពពួកម្សៅ) និងជាតិខ្លាញ់ ។

ពាក្យដែលទាក់ទងគ្នា : កង្វះអាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ ការផ្តល់អាហារព្យាបាល ។

*NOTES...*

# THERAPEUTIC FEEDING

Specialized emergency feeding programs designed to address severe malnutrition. Implemented for children under five years of age for whom malnutrition has become a medical emergency, reflected in excess mortality and increased incidence of malnutrition-associated diseases (kwashiorkor, oedema, etc.)

Related Terms: malnutrition, nutritional status, supplementary feeding.

## ការផ្តល់អាហារព្យាបាល

កម្មវិធីពិសេសផ្តល់អាហារព្យាបាលក្នុងស្ថានភាពសង្រ្គោះបន្ទាន់ ដែលត្រូវបានរចនាឡើងដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ។ ដោយត្រូវបានអនុវត្ត ចំពោះកុមារអាយុក្រោម៥ឆ្នាំ ដែលកុមារទាំងអស់នោះ បញ្ហាកង្វះអាហារូបត្ថម្ភរបស់ពួកគេបានប្រែក្លាយទៅជាស្ថានភាពដែលត្រូវជួយព្យាបាលសង្រ្គោះបន្ទាន់ ដែលឆ្លុះបញ្ចាំងអំពីការស្លាប់ដ៏ច្រើនហួសហេតុ និងបង្កើនអត្រាអាំងស៊ីដង់ជម្ងឺដែលរួមផ្សំជាមួយនឹងបញ្ហាកង្វះអាហារូប-ត្ថម្ភ ( ក្វាស្យូគ័រ, ហើម, ,,, ។ល ។) ។

ពាក្យដែលទាក់ទងគ្នា : កង្វះអាហារូបត្ថម្ភ ស្ថានភាពអាហារូបត្ថម្ភ ការផ្តល់អាហារបំប៉ន ។

*NOTES...*

# TRADITIONAL NUTRITION

Knowledge, attitudes and behaviours based on conventions embedded in local culture. These may pertain to infant weaning and nursing, meal composition, the attribution of positive properties to specific foods or combinations of foods and the avoidance of others.

Related Terms: food culture, food restriction, food taboos, nutrition

## អាហារូបត្ថម្ភតាមបែបបុរាណ

ចំណេះដឹង ឥរិយាបថ និងអកប្បកិរិយាដោយផ្អែក ទៅលើទំនៀមទំលាប់ដែលបង្កប់នៅក្នុងប្រពៃណី/វប្បធម៌នៅក្នុងស្រុក ។ ទាំងអស់នេះ អាចជាប់ទាក់ទងទៅនឹងការផ្តាច់ដោះ និងថែទាំទារក សមាសភាពរបស់អាហារពេលការធ្វើឱ្យរិចរិលបន្តិចម្តងៗនូវគុណភាពជាវិជ្ជមានចំពោះអាហារជាក់លាក់មួយចំនួន ឬក៏អាហាររួមផ្សំទាំងអស់នោះតែម្តង និងការជៀសវាងមិនបរិភោគ អាហារផ្សេងៗទៀត ។

ពាក្យដែលទាក់ទងគ្នា ៖ ប្រពៃណីក្នុងការប្រើប្រាស់ស្បៀង ការដាក់ក៏រិតចំណីអាហារ ការតមអាហារ អាហារូបត្ថម្ភ ។

*NOTES...*

# TRANSITORY FOOD INSECURITY

A short-term or temporary inability to meet minimum food requirements, indicating a capacity to recover. The state in which food insecurity affects people for a limited time due to temporary shocks or other factors. Seasonal food insecurity is one form of transitory food insecurity.

Related Terms: chronic food insecurity, food security, food insecurity, lean season, livelihoods, stability, vulnerability

## អសន្តិសុខស្បៀងក្នុងរយៈពេលមួយជាបណ្តោះអាសន្ន

អលទ្ធភាព ឬ អសមត្ថភាពរយៈពេលខ្លី ឬជាបណ្តោះអាសន្នក្នុងការឆ្លើយតបទៅនឹងតំរូវការស្បៀងកំរិតអប្បបរមា ដែលចង្អុលបង្ហាញឱ្យឃើញពីសមត្ថភាពក្នុងការស្តារខ្លួនងើបទៅរកសភាពដើមវិញបាន ។ សភាពដែលអសន្តិសុខស្បៀងប៉ះ ពាល់ទៅលើប្រជាជនក្នុងរយៈពេលមួយកំណត់ដោយសារតែមានព្រឹត្តិការណ៍ដ៏គួរឱ្យតក់ស្លុត ឬកត្តាផ្សេងៗទៀតក្នុងរយៈ ពេលមួយជាបណ្តោះអាសន្ន ។ អសន្តិសុខស្បៀងតាមរដូវកាល គឺជាទម្រង់មួយនៃអសន្តិសុខស្បៀងក្នុងរយៈពេលមួយជាបណ្តោះអាសន្ន ។

ពាក្យដែលទាក់ទងគ្នា ៖ អសន្តិសុខស្បៀងរ៉ាំរ៉ៃ សន្តិសុខស្បៀង អសន្តិសុខស្បៀង រដូវក្រខ្សត់ស្បៀង/រដូវទទួលទិន្នផលស្បៀងមិនល្អ ការចិញ្ចឹមជីវិត ស្ថេរភាព ភាពងាយរងគ្រោះ ។

*NOTES...*

# UNDERNOURISHMENT

Calculated on a per capita basis at the national level, undernourishment refers to the condition of people whose dietary energy consumption is continuously below a minimum dietary energy requirement (MDER) for maintaining a healthy life and carrying out a light physical activity.  Undernourishment is a key indicator for Millennium Development Goal 1.1.

Related Terms:  degree of food deprivation, food deprivation, dietary energy consumption, minimum dietary energy requirement, nutrition

## កង្វះសារជាតិចិញ្ចឹម/សារជាតិចិញ្ចឹមខ្សត់ខ្សោយ

ដោយត្រូវធ្វើការគណនាផ្អែកទៅលើតំរូវការក្នុងម្នាក់ៗនៅថ្នាក់ជាតិនោះ កង្វះសារជាតិចិញ្ចឹម/សារជាតិចិញ្ចឹមខ្សត់ខ្សោយ គឺចង់និយាយសំដៅដល់លក្ខខណ្ឌរបស់ប្រជាជន ដែលការបរិភោគរបបអាហារថាមពលរបស់ពួកគាត់គឺនៅតែបន្តស្ថិតនៅក្រោមតំរូវការរបបអាហារថាមពលកំរិតអប្បបរមាជាប់រហូត (MDER) ដែលជាតំរូវការដើម្បីរក្សាជីវិតឱ្យមានសុខភាពល្អ និងអាចធ្វើសកម្មភាពស្រាលៗផ្នែករាងកាយបាន ។ កង្វះសារជាតិចិញ្ចឹម/សារជាតិចិញ្ចឹមខ្សត់ខ្សោយ គឺជាសូចនាករគន្លឹះមួយសម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ចំណុចទី ១,១ ។

ពាក្យដែលទាក់ទងគ្នា :  កំរិតនៃការបង្អត់អាហារ/កំរិតនៃភាពខ្វះខាតចំណីអាហារ  ការបង្អត់អាហារ/ភាពខ្វះខាតចំណីអាហារ  ការប្រើប្រាស់របបអាហារថាមពល/ការបរិភោគរបបអាហារថាមពល  តំរូវការកំរិតអប្បបរមានូវថាមពលក្នុង របបអាហារ  អាហារូបត្ថម្ភ ។

*NOTES...*

# UNDERNUTRITION

An aggregate measure of all forms of inadequate food intake at the population level, arising from the deficiency of one or more nutrients, including both macro and micronutrients.  For children, undernutrition is assessed anthropometrically by measuring growth failure which encompasses stunting, wasting, and underweight, or combinations thereof.  Among adults, undernutrition is measured by weight loss.

Related Terms:  malnutrition, nutritional status

## កង្វះអាហារូបត្ថម្ភ/អាហារូបត្ថម្ភខ្សត់ខ្សោយ

គឺជារង្វាស់សរុបរួមនៃគ្រប់ទម្រង់នៃការបរិភោគចំណីអាហារចូលទៅក្នុងខ្លួនមិនបានគ្រប់គ្រាន់ (អាហារូបត្ថម្ភខ្សត់ខ្សោយ) នៅថ្នាក់ប្រជាជន ដោយកើតចេញពីកង្វះសារជាតិចិញ្ចឹមមួយមុខ ឬច្រើនមុខ ដោយរាប់បញ្ចូលទាំងពពួកម៉ាក្រូ សារជាតិផង និងពពួកមីក្រូសារជាតិផងដែរ ។ ចំពោះកុមារ កង្វះអាហារូបត្ថម្ភ/អាហារូបត្ថម្ភខ្សត់ខ្សោយ គឺត្រូវបានធ្វើការវាយតំលៃតាមរង្វាស់មនុស្សមាត្រ ដោយវាស់វែងពីភាពចុះអន់ខ្សោយខាងការលូតលាស់ដែលជារួមមានក្រេះក្រិន  ស្គម ស្គាំង និងទម្ងន់ក្រោមស្តង់ដារ  ឬក៏ការរួមផ្សំនៃបញ្ហាទាំងអស់នោះ ។ ចំពោះមនុស្សពេញវ័យវិញ កង្វះអាហារូបត្ថម្ភ /អាហារូបត្ថម្ភខ្សត់ខ្សោយ គឺត្រូវបានវាស់វែងដោយរកពីការបាត់ទម្ងន់ ឬស្រកទម្ងន់ ។

ពាក្យដែលទាក់ទងគ្នា :   កង្វះអាហារូបត្ថម្ភ  ស្ថានភាពអាហារូបត្ថម្ភ ។

*NOTES...*

# UTILIZATION

The third pillar of food security.  Refers to (a) physical utilization of food at the household level (including food storage, food preferences, food preparation, feeding practices, and water requirements), and (b) biological utilization of food at the individual level( health, hygiene, nutrition, sanitation).

Related Terms:  access, availability, food security, food utilization, stability

## ការប្រើប្រាស់ និងការបឺតស្រូបស្បៀង

សសរទី៣នៃសន្តិសុខស្បៀង  ការប្រើប្រាស់ និងការបឺតស្រូបស្បៀងគឺចង់សំដៅដល់  (ក) ការប្រើប្រាស់ផ្នែករូបវ័ន្តនូវស្បៀងនៅថ្នាក់គ្រួសារ (រួមមាន ការស្តុកស្បៀង ចំណង់ចំណូលចិត្ត ឬការជ្រើសរើសស្បៀង ការរៀបចំស្បៀង ការប្រតិបត្តិក្នុងការផ្តល់អាហារ និងតំរូវការទឹកស្អាត) និងការបឺតស្រូបស្បៀងតាមផ្នែកជីវសាស្ត្រ នៅថ្នាក់បុគ្គល (សុខភាព អនាម័យរាងកាយ អាហារូបត្ថម្ភ និងអនាម័យលំនៅដ្ឋាន/បរិស្ថាន) ។

ពាក្យដែលទាក់ទងគ្នា :  លទ្ធភាពទទួលបាន  លទ្ធភាពមាន/ភាពមាន  សន្តិសុខស្បៀង  ការបឺតស្រូបស្បៀង ស្ថេរភាព ។

*NOTES...*

# VISION

In the development and policy context, a concise declaration of the long-term goals of a policy or program.  An aspirational target which should be applicable to all aspects of a policy or program.  Also referred to as a vision statement.

## ទស្សនៈវិស័យ

នៅក្នុងបរិបទនៃការអភិវឌ្ឍន៍ និងគោលនយោបាយ សេចក្តីប្រកាសសង្ខេបអំពី គោលដៅរយៈពេលយូរអង្វែង របស់គោលនយោបាយ ឬកម្មវិធី ។ គោលដៅប្រកបដោយក្តីប៉ងប្រាថ្នាមួយដែល គេអាចអនុវត្តបានទៅតាមគ្រប់ទិដ្ឋភាពទាំងអស់នៃ គោលនយោបាយ ឬកម្មវិធី ។ ពាក្យនេះក៏ចង់និយាយសំដៅផងដែរថាជាសេចក្តីថ្លែងការពីទស្សនៈវិស័យ (របស់កម្មវិធី អ្វីមួយ) ។

*NOTES...*

# VULNERABILITY

Vulnerability is a function of exposure, susceptibility, and resilience to hazard/shock, leading to the possibility of negative outcomes.  In general terms, the level of vulnerability of a household and/or individual is determined by the inadequacy of their adaptive mechanisms, coping mechanisms or accumulated capital or food stocks to meet their daily needs.

Related Terms:  risk assessment, risk analysis, vulnerable groups

## ភាពងាយរងគ្រោះ

ភាពងាយរងគ្រោះ គឺជាដំណើរការនៃការសំដៅទៅរកការងាយ ឬ ឆាប់ទទួល និងការអាចប្រែប្រួលងើបឡើងវិញបាន យ៉ាងរហ័សទៅនឹងហានិភ័យ/ព្រឹត្តិការណ៍ដ៏គួរឱ្យតក់ស្លុតដែលនឹងបណ្តាលឱ្យមានលទ្ធភាពកើតមានលទ្ធផលជាអវិជ្ជមាន។ ប្រើក្នុងន័យទូទៅ ពាក្យនេះមានន័យថា កំរិតនៃភាពងាយរងគ្រោះរបស់គ្រួសារ និង/ឬ បុគ្គលម្នាក់ៗ គឺត្រូវបានកំណត់ ដោយភាពមិនគ្រប់គ្រាន់ (កង្វះខាត) នៃយន្តការសម្របតំរូវ យន្តការដោះស្រាយបញ្ហា ឬទុនដែលកើនឡើងជាបន្តបន្ទាប់ ឬស្តុកស្បៀង ដើម្បីឱ្យឆ្លើយតបទៅនឹងតំរូវការប្រចាំថ្ងៃរបស់ពួកគេ។

ពាក្យដែលទាក់ទងគ្នា :   ការវាយតំលៃហានិភ័យ  ការវិភាគពីហានិភ័យ   ក្រុមជនដែលងាយរងគ្រោះ។

*NOTES...*

# VULNERABLE GROUP(S)

Populations who are vulnerable to similar risk factors as a result of common livelihoods, assets and coping mechanisms.  Identification of key vulnerable groups is usually a main component of assessments.

Related Terms:  initial assessment, rapid assessment, vulnerability

## ក្រុមជនងាយរងគ្រោះ

ប្រជាជនដែលងាយរងគ្រោះ ទៅនឹងកត្តាហានិភ័យស្រដៀងៗគ្នា ដែលជាលទ្ធផលនៃ ជីវភាពរស់នៅ/ការប្រកបរបរចិញ្ចឹមជីវិតធម្មតាៗ ទ្រព្យសម្បត្តិ និងយន្តការដោះស្រាយ (ស្ថានភាពបន្ទាន់) ។ ការកំណត់នូវក្រុមជនដែលងាយរងគ្រោះ គន្លឹះ តាមធម្មតា គឺជាសមាសភាគមួយដ៏សំខាន់នៃការវាយតំលៃ ឬ ការអង្កេត ។

ពាក្យដែលទាក់ទងគ្នា :   ការវាយតំលៃជំហានដំបូង  ការវាយ តំលៃរហ័ស  ភាពងាយរងគ្រោះ ។

*NOTES...*

# WASTING

Physical manifestation of advanced acute malnutrition, the point at which malnutrition is a medical emergency.  Visible loss of subcutaneous fat and skeletal muscles.  Anthropometric wasting may not be observed in cases of malnutrition related diseases where wasting is masked.  Treated by therapeutic feeding programmes.

Related Terms:  Acute Malnutrition, Malnutrition, Nutritional Status, Therapeutic Feeding

## ស្គមស្គាំង

ការស្តែងចេញនៅលើរាងកាយរបស់បញ្ហាកង្វះអាហារូបត្ថម្ភ ដែលមានការវិវឌ្ឍន៍ទៅមុខ ជាចំណុចដែលបញ្ហាកង្វះអាហារូបត្ថម្ភ គឺជាចំណុចដែលត្រូវធ្វើការព្យាបាលសង្គ្រោះបន្ទាន់ ។ មានការបាត់បង់ខ្លាញ់នៅក្រោមស្បែក និងបាត់បង់ សាច់ដុំដែលនៅព័ទ្ធជុំវិញឆ្អឹងដែលគេអាចមើលឃើញច្បាស់ ។
ស្គមស្គាំងដែលទាក់ទងទៅនឹងរង្វាស់មនុស្សមាត្រ អាចនឹង មិនអាចសង្កេតឃើញដឹងបានឡើយ ក្នុងករណីដែលមានទំនាក់ទំនងទៅនឹងការកើតមានជម្ងឺផ្សេងៗ ដែលនៅពេលនោះ ភាពស្គមស្គាំងត្រូវបានលាក់បំបាំងមិនឱ្យឃើញ ។ បញ្ហានេះត្រូវព្យាបាលដោយកម្មវិធីផ្តល់អាហារព្យាបាល ។

ពាក្យដែលទាក់ទងគ្នា :   កង្វះអាហារូបត្ថម្ភស្រួចស្រាវ   កង្វះអាហារូបត្ថម្ភ   ស្ថានភាពអាហារូបត្ថម្ភ   ការផ្តល់អាហារព្យាបាល ។

*NOTES...*

# Z-SCORE

The deviation of the value for an individual from the mean value of the reference value, divided by the standard deviation for the reference population. Can only be determined if the reference population is known and an assumption about 'normality' is made. Also known as standard deviations.

Related Terms: Indicator, Quantitative Data, Severe Stunting, Stunting, Wasting

## ពិន្ទុ-ហ្សេត

លំងាកនៃតំលៃរបស់បុគ្គលម្នាក់ងាកចេញពីតំលៃមធ្យម (កណ្តាល) នៃតំលៃយោង ដោយចែកនឹងលំងាកស្តង់ដារតំណាង ឱ្យប្រជាជនយោង (សំអាង)។ គេអាចកំណត់បានតែនៅពេលណាប្រជាជនយោង (សំអាង) ត្រូវបានគេដឹង ហើយការប៉ាន់ស្មានអំពី " លក្ខណៈធម្មតា" ត្រូវបានធ្វើ។ ដូចគ្នានេះដែរ ពិន្ទុ-ហ្សេតនេះក៏ត្រូវបានគេក៏ដឹងថាជាលំងាកស្តង់ដារផងដែរ (SD)។

ពាក្យដែលទាក់ទងគ្នា : សូចនាករ ទិន្នន័យបែបបរិមាណ ក្រេះក្រិនធ្ងន់ធ្ងរ ក្រេះក្រិន ស្គមស្គាំង។

*NOTES...*

# ប្រភព ៖

បន្ថែមទៅនឹងប្រភពដូចដែលមានរាយឈ្មោះនៅខាងក្រោមនេះ មានពាក្យគន្លឹះជាច្រើនទៀតដែលមាននៅទីនេះ ត្រូវបាន ដាក់បញ្ចូលទៅក្នុង Wikipedia ដែលអាចនឹងមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ ។


គណៈកម្មការសន្តិសុខស្បៀងពិភពលោក (ឆ្នាំ ២០១២) ពាក្យដែលមានលក្ខណៈជាពាក្យបច្ចេកទេស

អង្គការស្បៀង និងកសិកម្ម (FAO) (ឆ្នាំ ២០០៨)៖ សៀវភៅបច្ចេកទេសី ភជ ១.១ ទីក្រុងរ៉ូម ៖ FAO

អង្គការស្បៀង និងកសិកម្ម (FAO) (ឆ្នាំ ២០១១)៖សៀវភៅបច្ចេកទេស IPC ២.០ ទីក្រុងរ៉ូម ៖ FAO

អង្គការស្បៀង និងកសិកម្ម (FAO) (ឆ្នាំ ២០១១)៖ " សុវត្ថិភាពស្បៀង និងគុណភាពស្បៀង " មាន ឬអាចរកបាននៅតាម Online: http://www.fao.org/ag/agn/agns/foodsafety_chain_en.asp [7 January 2012]

អង្គការស្បៀងអាហារពិភពលោក (WFP) (ឆ្នាំ២០០៩)៖កូនសៀវភៅស្តីពីការវាយតម្លៃពីស្ថានភាពសង្គ្រោះបន្ទាន់នូវសន្តិសុខស្បៀង បោះពុម្ពលើទី២ ។ ទីក្រុងរ៉ូម ៖ WFP

អង្គការសុខភាពពិភពលោក (WHO) (ឆ្នាំ ២០០៧)៖ ការការពារ និងទប់ស្កាត់បញ្ហាកង្វះមីក្រូសារជាតិចំពោះប្រជាជនដែលទទួលរងការប៉ះពាល់ដោយស្ថានភាពដែលត្រូវសង្គ្រោះបន្ទាន់ ឥឡូវនេះគឺមាន ឬអាចរកបាននៅតាម Online: http://www.who.int/nutrition/publications/WHO_WFP_UNICEFstatement.pdf [7 January 2012].

របាយការណ៍នេះត្រូវបានផលិតឡើងក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ។ ខ្លឹមសារនៃឯកសារនេះ
គឺជាការទទួលខុសត្រូវតែមួយគត់របស់ក្រុមការងារគម្រោងនេះ ហើយដែលមិនអាចយកចំណុចណាមួយដែលមាននៅ
ក្នុងរបាយការណ៍នេះ ទៅធ្វើការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬ ក៏ទស្សនៈរបស់អង្គការស្បៀង និង
កសិកម្មនៃសហប្រជាជាតិឡើយ ។

This glossary has been produced with financial assistance from the European Union. The contents of this publication are the sole responsibility of the project team and can in no way be taken to reflect the views of the European Union or of the Food and Agriculture Organization of the United Nations.

EC-FAO Food Security Programme

# Linking Information and Decision-Making to Improve Food Security

CAMBODIA LAO PDR MYANMAR

**The project aims to enhance the utility and use of food security-related information and analysis to more effectively meet the needs of decision-makers and decision-making processes at all levels.**

Better informed decisions will lead to better action.



**The project focuses on three main types of information, and on strengthening communication, networking and capacity.**




### Market Information and Intelligence

Building on existing structures, the project supports efforts to monitor, analyse and report on staple food prices and other market variables, and to link national efforts with regional and international food market information systems.




### Climate Information

The project works to improve understanding and analysis of climate information and potential impacts on agriculture, food security and livelihoods to better understand seasonal agricultural disaster risks and those associated with climate change.




### Chronic Food Insecurity, Livelihoods and Vulnerability

The project supports assessments and analysis that helps identify and profile food insecure households and communities, and to enhance understanding of livelihoods to guide both emergency response and long-term policy and programming.



### Cross-Cutting Activities

The project strengthens communication, networking and capacity building to enhance the utility and use of food security information, to identify and share lessons learned and best practices, and to add value and synergy to related initiatives.




កម្មវិធីសន្តិសុខស្បៀងនៃអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប

# ការផ្សារភ្ជាប់ពត៌មានទៅនឹងការធ្វើសេចក្តីសំរេចចិត្តដើម្បីកែលំអរសន្តិសុខស្បៀង

គំរោងមានគោលបំណងដើម្បីលើកកំពស់ពត៌មានស្តីពីការប្រើប្រាស់និងបឹតស្រូបពាក់ព័ន្ធនិងសន្តិសុខស្បៀង និងវិភាគពត៌មានអោយត្រឹមត្រូវដើម្បីឆ្លើយតបអោយកាន់តែមានប្រសិទ្ធភាពទៅនឹងតម្រូវការនៃអ្នកធ្វើសេចក្តីសំរេចចិត្ត និងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនានានៅគ្រប់កំរិតទាំងអស់

ការធ្វើសេចក្តីសំរេចចិត្តត្រឹមត្រូវ នឹងនាំមកនូវសកម្មភាពដែលមានប្រសិទ្ធភាពសំរាប់ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ, អសន្តិសុខស្បៀង និងភាពកង្វះអាហារូបត្ថម្ភ



គំរោងផ្តោតជាសំខាន់លើពត៌មានបីប្រភេទ ព្រមទាំងផ្តោតលើការពង្រឹងការធ្វើទំនាក់ទំនង ការកសាងបណ្តាញការងារ និងការពង្រឹងសមត្ថភាព



### ពត៌មានទីផ្សារ និងការអង្កេត

ដើម្បីធ្វើអោយការត្រួតពិនិត្យ, ការវិភាគ និងការធ្វើរបាយការណ៏ស្តីពីតំលៃស្បៀងមូលដ្ឋាន និង តំលៃទីផ្សារដ៏ទៃទៀតកាន់តែមានប្រសិទ្ធិភាព និងប្រសើរឡើង



### ពត៌មានអាកាសធាតុ

ដើម្បីកែលំអរការយល់ដឹងពត៌មានអាកាសធាតុសំរាប់រយៈពេលយូរ និងពត៌មានតាមរដូវកាលអោយបានកាន់តែប្រសើរឡើង



### ភាពអសន្តិសុខស្បៀងរ៉ាំរ៉ៃ របបចិញ្ចឹមជីវិត និងភាពងាយទទួលរងគ្រោះ

ដើម្បីជួយកំណត់ និងស្វែងយល់ពីគ្រួសារនិងសហគមន៏ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ដើម្បីផ្សព្វផ្សាយ និងរៀបចំសកម្មភាពអន្តរាគមន៏នៅគ្រប់កំរិតទាំងអស់



### សកម្មភាពចម្រុះពហុវិស័យ

ដើម្បីពង្រឹងការធ្វើទំនាក់ទំនង ការកសាងបណ្តាញការងារ និងការកសាងសមត្ថភាព និងដើម្បីចែករំលែកមេរៀន និងបទពិសោធន៏ល្អៗ

